ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jul-2013, 15:37
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី២១២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី

*(Ms. Faiza ZOUAKRI)*

លោកស្រី សែ កុលវុឌ្ឍី

លោកស្រី មីរាម ម៉ាហ្វេសសាន់ទិ

*(Ms.Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ*(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

| | |
|---|---|
| លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)* | *(Ms. Elisabeth SIMONNEAU-FORT)* |
| **មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖** | លោក ឡោ ជុនធី |
| លោក  គង់ សំអុន | លោក ហុង គីមសួន |
| កញ្ញា អង់តា ហ្គីសសេ*(Ms. Anta GUISSÉ)* | លោក វ៉ែន ពៅ |
| **មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖** | **ផ្នែកគ្រប់គ្រងតុលាការ៖** |
| លោក ពេជ អង្គ | លោក អ៊ុច អរុណ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | លោកស្រី សួ សុទ្ធាវី |

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ស្ទីវ ហេដឌ័រ (TCE-33) | អង់គ្លេស |
| លោក នួន ជា | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស្អឹង ហេងឌុំ** (TCE-33)

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី..............................................................ទំព័រ ៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស្ទីវ ហេដឌ័រ ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួន ដែលនៅពីខាងក្រោមបន្ទប់សវនាការនេះ តាមសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាព។ ចំណែកឯសាក្សី ស្ទីវិន ហេដឌ័រ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ និងបានត្រៀមខ្លួនជាស្រេចសម្រាប់បន្តផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៤:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមផ្អាកបន្តិចសិនលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

សូមអញ្ជើញលោកសាក្សីមុន។ បាទសូមអញ្ជើញលោក ស្ទីវ ហេដឌ័រ!

**លោក ស្ទីវ ហេដឌ័រ៖**

លោកប្រធាន ខ្ញុំបញ្ជាក់ -- សូមពេលបន្តិចទេ គឺថាខ្ញុំស្នើសុំថា ប្រសិនបើចង់ឲ្យខ្ញុំបញ្ចប់ការផ្តល់សក្ខីកម្មទាក់ទងទៅនឹងអង្គហេតុ នៅលើអ្វីដែលខ្ញុំសរសេរទាក់ទងនឹងផ្នែកកុម្មុយនីស្តរបស់ប្រទេស

វៀតណាម ក៏ដូចកុម្មុយនីស្តរបស់អ្នកដែលកំពុងតែជំនុំជម្រះនៅពេលនេះ ខ្ញុំអាចផ្តល់ជូនបាន។ ទី២ គឺថានៅក្នុង ហ្សាយឡេប គឺយើងអាចទាញយកនូវឯកសារច្បាប់ដើមនូវឯកសារដើមដែលជាសម្រង់ដែលមានបង្ហាញនៅក្នុងជើងទំព័ររបស់សៀវភៅ ប៉ែន យៀរនិន។

ដូច្នេះប្រសិនបើលោកប្រធានអនុញ្ញាត គឺខ្ញុំអាចនឹងបញ្ជាក់បន្ថែមទៅលើចំណុចទាំងអស់នេះបាន ហើយជាពិសេសគឺទៅលើមូលដ្ឋាននៃអង្គហេតុ គឺអង្គហេតុដែលខ្ញុំទទួលបាននៅពេលនោះ គឺអង្គហេតុទាក់ទងទៅនឹងការសម្ភាស ក៏ដូចជាការដកស្រង់នានាដែលខ្ញុំបានធ្វើ។ គឺជាការដែលខ្ញុំស្នើ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំនឹងធ្វើ។ ប្រសិនបើលោកប្រធានគិតថាមិនចាំបាច់ទេ អាហ្នឹងគឺជាការសម្រេចរបស់អង្គជំនុំជម្រះ។

[០៩:០៦:១៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៨:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់លោក ស្ទីវ ហេដឌ័រ ហើយអង្គជំនុំជម្រះសូមជម្រាបលោក ស្ទីវ ហេដឌ័រ ថា អង្គជំនុំជម្រះមិនចាំបាច់ត្រូវការស្តាប់បន្ថែមលើបញ្ហាដែលលោកចង់សុំបញ្ជាក់នេះទៀតទេ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបរំឭកលោក ស្ទីវ ហេដឌ័រ ថាក្នុងនាមលោកជាសាក្សី លោករៀបចំនូវការចូលរួមនូវការផ្តល់សក្ខីកម្មនេះ ធ្វើយ៉ាងណាឆ្លើយឲ្យចំទៅនឹងសំណួរដែលសួរ ហើយនិងកម្រិតត្រឹមតែភាពចាំបាច់ទៅនឹង -- តបទៅនឹងសំណួរបានហើយ។ ភាពចាំបាច់គ្រប់គ្រាន់តបនឹងសំណួរបានហើយ វាជៀសវាងការឆ្លើយវែងអន្លាយ វាអាចធ្វើឲ្យបាត់បង់ពេលវេលាភាគីដែលអង្គជំនុំជម្រះបានកំណត់ពេលវេលាយ៉ាងតឹងរ៉ឹងក្នុងការសួរដេញដោលចំពោះសាក្សី ក៏ដូចជាសួរចំពោះលោកដែរ។ ហើយបើកាន់តែខ្លី ហើយឲ្យចំនឹងសំណួរនោះ កាន់តែល្អហើយ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:០៩:២៥]

**លោក ឃីត រេយ៍នឺរ៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរដល់លោកមេធាវី។ លោកប្រធាន ខ្ញុំងើបឈរនៅពេលនេះ គឺដើម្បីបញ្ជាក់ថា យើងបានធ្វើការត្រួតពិនិត្យទៅលើចម្លើយ

របស់សាក្សី ដែលបានបង្ហាញថា ក្រុមមេធាវីការពារក្ដី ខៀវ សំផន អាចនឹងប្រើប្រាស់នៅពេលព្រឹកនេះគឺចម្លើយរបស់សាក្សី។

ហេតុដូច្នេះយើងខ្ញុំចង់ធ្វើការកែសម្រួលដោយលើកជាឧទាហរណ៍ E3/392, E3/393, ហើយនិងឧបសម្ព័ន្ធ១២ ដែលត្រូវបានធ្វើការកែសម្រួល។ ដូចដែលតុលាការបានលើក ឡើងជាច្រើនដងរួចមកហើយនូវឯកសារនានាដែលត្រូវយោង។ ឯកសារដែលត្រូវយោង ត្រូវដាក់នៅក្នុងសំណើយោងតាមវិធាន៨២របស់ខ្លួន ឬក៏បញ្ជីឯកសារដែលត្រូវបង្ហាញ។ ដូច្នេះ ឯកសារដែលមិនស្ថិតនៅក្នុងបញ្ជីឧបសម្ព័ន្ធ១២ ដែលបានកែសម្រួលមិនគួរត្រូវបានប្រើប្រាស់ឡើយ។

ដូច្នេះ ខ្ញុំឱ្យមានការណែនាំទៅដល់មេធាវីការពារក្ដី ដើម្បីឱ្យមេធាវីការពារក្ដីដឹងថា ចម្លើយរបស់សាក្សីមុនពេលដែលដាក់ចម្លើយសាក្សីនីមួយៗត្រូវតែមានការបញ្ជាក់ជាមួយតុលាការ។ គឺថាឱ្យមានការពិភាក្សាជាមួយអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាភាគីនានាដើម្បីបញ្ជាក់ថាឯកសារដែលខ្លួនចង់ប្រើប្រាស់ស្ថិតនៅក្នុងសំណើបញ្ជីដែលអនុលោមតាមវិធាន៨២។ សូមអរគុណលោកប្រធាន។

[០៩:១១:១០]

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។

ខ្ញុំគិតថា ការកត់សម្គាល់របស់សហព្រះរាជអាជ្ញានៅពេលនេះ គឺថាវាដូចជាឆាប់ពេក។ លោកប្រធាន ខ្ញុំនឹងធ្វើយ៉ាងណាដែលបញ្ជាក់ថាតើឯកសារខ្ញុំហ្នឹងយ៉ាងម៉េច? ហើយលេខឯកសារលេខដែលលោកសហព្រះរាជអាជ្ញាសួត្រអំមិញនេះ ដូចជាអត់មានទេ ដូចជាខ្ញុំមិនដឹងទេ។ ដូច្នេះ ខ្ញុំជឿជាក់ទៅលើការប្រុងប្រយ័ត្នរបស់សហព្រះរាជអាជ្ញាដើម្បីកាត់ផ្ដាច់ខ្ញុំ បើសិនជាមានករណីបែបនេះមែន។

ដូច្នេះ ខ្ញុំសូមការអនុញ្ញាតសួរសំណួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបាទ!

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ស៊ីវ ហេងឆ័រ។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិ

ការពារក្ដីលោក ខៀវ សំផន។ ហើយក្នុងឋានៈខ្ញុំជាមេធាវីនេះហើយ ដែលខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកនៅថ្ងៃនេះ។ ក្នុងរយៈពេលប៉ុន្មាននេះ លោកយល់ឃើញថា លោកមកបង្ហាញខ្លួននេះក្នុងឋានៈជាសាក្សីប៉ុណ្ណោះ លោកមិនមែនជាអ្នកជំនាញទេ។ ដូច្នេះ យើងនឹងកម្រិតសំណួររបស់យើងត្រឹមតែសួរលោកជាអ្នកសាក្សី។ ដូច្នេះ ខ្ញុំព្យាយាមឲ្យលោកបំភ្លឺមួយចំនួន ហើយនិងពិនិត្យមើលឯកសារមួយចំនួនជាមួយលោក។

[០៩:១២:៥៣]

ខ្ញុំនឹងព្យាយាមបញ្ជាក់សំណួរនីមួយៗរបស់ខ្ញុំ ហើយជាទូទៅនោះ ខ្ញុំនិយាយមុនៗនឹងសួរលោកពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍នីមួយៗនោះ។ ដូច្នេះ ខ្ញុំសូមឲ្យលោកឆ្លើយទៅតាមអ្វីដែលលោកបានជួបប្រទះ បានឃើញ បានឮដោយផ្ទាល់នៅប្រទេសកម្ពុជា ឬក៏អ្វីដែលលោកបានទទួលបានជាព័ត៌មានក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតរបស់លោក ក៏ដូចជាក្នុងក្របខ័ណ្ឌក្នុងការស្រាវជ្រាវដើម្បីសរសេរអត្ថបទរបស់លោក ឬក៏នៅក្នុងក្របខ័ណ្ឌការងាររបស់លោកនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ឬការិយា-ល័យសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ សូមឲ្យលោកនិយាយតែផ្អែកទៅលើអង្គហេតុពិតប្រាកដ សូមកុំឲ្យលោកបញ្ចេញមតិយោបល់ បញ្ចេញទស្សនៈផ្ទាល់ខ្លួន គឺឲ្យលោកនិយាយតែអ្វីដែលលោកបានដឹង។ ខ្ញុំសូមឲ្យលោកយល់បែបនេះ ថាគោលការណ៍នៃការសួរសំណួររបស់ខ្ញុំគឺបែបហ្នឹងឯង។

សំណួរដំបូងរបស់ខ្ញុំនោះ គឺពាក់ព័ន្ធទៅនឹងរយៈពេលដែលលោកនៅកម្ពុជា គឺនៅខែឧសភា ឆ្នាំ៧៣ រហូតទៅដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៥។ លោកបានបញ្ជាក់ថា លោកមានវត្តមាននៅភ្នំពេញនៅពេលនោះ។ ហើយកាលពីសវនាការថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ មុនម៉ោង១៣:៤៦នាទីបន្តិចលោកបានឆ្លើយថា៖ “លោកនៅពេលនោះ គេមានការប្រកាសជាផ្លូវការអំពីការបញ្ចប់ការទម្លាក់គ្រាប់បែកអាមេរិក គឺនៅខែសីហា ឆ្នាំ៧៣”។ តើខ្ញុំស្ដាប់អ៊ីចឹងត្រូវទេ ថាលោកមកដល់ភ្នំពេញនេះ គឺនៅខែឧសភា ឆ្នាំ៧៣ គឺមុនពេលបញ្ចប់ការទម្លាក់គ្រាប់បែក?

[០៩:១៤:៥៥]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ គឺខ្ញុំមានការបញ្ជាក់បន្ថែមមួយទៀត នៅពេលដែលខ្ញុំមកដល់ភ្នំពេញ គឺគេនៅបន្តទម្លាក់គ្រាប់បែកនៅឡើយ។ គឺថាតាមដែលខ្ញុំថា គឺនៅពេលនោះគឺនៅមាននៅឡើយ គឺក្រោយពីសភាអាមេរិកបានឯកភាពបញ្ចប់បន្តិច ប៉ុន្តែការបន្តទម្លាក់គ្រាប់បែកហ្នឹងរហូតដល់ថ្ងៃ១៥ ខែ៨ នៅពេលនោះ។

**ស៖** ខ្ញុំយល់តាមចម្លើយរបស់លោក ថាលោកបានឃើញការទម្លាក់គ្រាប់បែកហ្នឹងដោយផ្ទាល់មែនទេ?

**ឆ៖** ខ្ញុំអាចឆ្លើយបានថា នៅពេលនុ៎ងគឺខ្ញុំស្ថិតនៅក្នុងចម្ងាយមួយដែលជិតនៅកន្លែងទម្លាក់គ្រាប់បែកនៅពេលដែលកប៉ាល់ហោះអាមេរិកមកទម្លាក់គម្រប់ គឺមុនខែ៨ ឆ្នាំ៧៣ នោះ។ ប៉ុន្តែប្រសិនបើលោកស្រីគិតអំពីអ្វីដែលខ្ញុំបានពណ៌នា គឺដូចជានៅភាគនិរតីនៃប្រទេសកម្ពុជាដែលមានការទម្លាក់គ្រាប់បែកយ៉ាងច្រើននោះ គឺវាមានការរន្ធត់យ៉ាងខ្លាំង ដែលទាក់ទងទៅនឹងការទម្លាក់គ្រាប់បែក។ គឺថាកម្លាំងគ្រាប់បែកវាអាចធ្វើឲ្យផ្ទះបើង ឬក៏ឲ្យផ្ទះដួលបាន សូម្បីតែសំឡេងក៏វាខ្លាំងក្លាដែរ។ ទាំងនៅខាងនិរតី ក៏ដូចជាខាងត្បូង ក៏ដូចជាខាងលិច ខាងលិចហ្នឹងគឺថាវាមានសំឡេងខ្លាំង។ ប្រសិនបើយើងនៅលើត្រឹមតែនៅលើអូតែលមនោរម្យ ឬក៏នៅតាមផ្លូវមនោរម្យហ្នឹងក៏ឮស្គរសំឡេងដែរ។ ប្រសិនបើយើងនៅលើដំបូល ក៏យើងមើលឃើញកម្ទេចគ្រាប់បែក ឬក៏អាផ្សែងគ្រាប់បែកទម្លាក់បានដែរ កុំថាទៅដល់កន្លែងផ្សេង។

[០៩:១៧:០៩]

**ស៖** សូមអរគុណចំពោះការចម្លើយបញ្ជាក់របស់លោក។ ក្រោយពីដឹងថាគ្រាប់បែកត្រូវបានទម្លាក់នៅកន្លែងនេះកន្លែងនោះៗ នៅក្នុងក្របខ័ណ្ឌរបស់លោក -- ក្នុងក្របខ័ណ្ឌការងារជាអ្នកកាសែតនោះ តើលោកត្រូវផ្លាស់ទី ឬក៏ធ្វើដំណើរទៅកន្លែងណាមួយក្រោយពីមានការទម្លាក់គ្រាប់បែកទេ? ហើយលោកបានសង្កេតឃើញអំពីស្ថានភាពនៃកន្លែង ដែលទទួលរងនូវការទម្លាក់គ្រាប់បែកបេ-៥២ ទេ?

**ឆ៖** ដោយសារតែការទម្លាក់គ្រាប់បែកភាគច្រើន គឺធ្វើឡើងនៅតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ខ្ញុំអត់ដែលបានទៅទីនោះទេ ហើយខ្ញុំសង្ឃឹមថាខ្ញុំអាចទៅបាន ប៉ុន្តែខ្ញុំអត់អាចទៅបានទេ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ដោយសារតែការយកចិត្តទុកដាក់របស់ក្រុមខ្ញុំនោះ ខ្ញុំអាចបញ្ជាក់ជូនសហព្រះរាជអាជ្ញាថា ឯកសារពីរដែលគាត់បានលើកឡើងនោះគឺ E3/392 និង E3/393 គឺស្ថិតនៅក្នុងបញ្ជីរបស់ឯកសារព្រះរាជអាជ្ញាយោងតាមវិធាន៨៣(ឃ) ហើយនៅទំព័រ៧៩ នៃឯកសារ E109/4.12។ នេះដើម្បីឲ្យសហព្រះរាជអាជ្ញាគាត់អាចពិនិត្យមើលបានក្នុងករណី ដែលគាត់បានលើកឡើងអម្បាញ់មិញនេះ។

[០៩:១៨:៥៦]

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធានដើម្បីបញ្ជាក់ឲ្យច្បាស់ នេះគឺជា -- នេះមិនមែនជាបញ្ជីត្រឹមត្រូវទេ។ បញ្ជីដែលនិយាយហ្នឹងគឺជាបញ្ជីដើម មិនមែនជាបញ្ជីដែលត្រូវបានកែសម្រួលនោះឡើយ។ ខ្ញុំចង់និយាយពីបញ្ជីដែលបានកែសម្រួល មិនមែនបញ្ជីដើមនោះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

ចំណុចទី២ នៃការបញ្ជាក់ ខ្ញុំត្រឡប់មកនិយាយជាមួយសាក្សី។ យុត្តិសាស្ត្ររបស់តុលាការនោះបញ្ជាក់យ៉ាងច្បាស់ថា ក្នុងក្របខ័ណ្ឌនៃការសួរសំណួរលោក ស្ទីវ ហេដឌ័រ នោះ យើងអាចប្រើឯកសារ E3 បានទាំងអស់។ ហើយឯកសារដែលមិនមានលេខ E3 នោះត្រូវតែដាក់ទៅក្នុងបញ្ជីឯកសាររបស់ភាគី។ ដូច្នេះខ្ញុំដាក់សំណួរនេះជូនអង្គជំនុំជម្រះ ហើយក៏ប៉ុន្តែនៅថ្ងៃនេះផ្នែកដំបូងនៃសំណួរ នៃការសួរសំណួររបស់ខ្ញុំនោះ ខ្ញុំមិនប្រើឯកសារនុ៎ងទេ។ ដូច្នេះ អង្គជំនុំជម្រះអាចមានពេលពិនិត្យមើលនៅក្នុងពេលឈប់សម្រាក ថាតើអនុញ្ញាតឲ្យខ្ញុំប្រើឯកសារឬក៏អត់? អាចលោកប្រធានសម្រេចឥឡូវនេះ ឬក៏ក្រោយពេលសម្រាកក៏បាន។

[០៩:២០:១៥]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក ហេដឌ័រ! សូមអភ័យទោស ឥឡូវនេះខ្ញុំត្រឡប់មកចំណុចយើងវិញ។ កាលពីសវនាការថ្ងៃទី១១ ខែកក្កដា ក្រោយពីម៉ោង១៤:១០នាទីបន្តិច លោកបានឆ្លើយថា៖ “លោកមានប្រភពយោធា ហើយលោកបានលើកឡើងអំពីសេនានុព័ន្ធជប៉ុន”។ សំណួររបស់ខ្ញុំៗចង់ដឹងថា ក្រោយពីការបញ្ចប់ការទម្លាក់គ្រាប់បែករបស់អាមេរិក តើលោកដឹងទេថា កម្លាំង លន់ នល់ និងកម្លាំងរបស់សាធារណរដ្ឋខ្មែរមានមូលដ្ឋានទ័ពអាកាសទេ? តើលោកមានបានទទួលព័ត៌មានពីអនុព័ន្ធយោធានេះទេថា ឬក៏មានប្រភពពីផ្សេង កន្លែងផ្សេងទៀតថា ពួកខាងទាហាន លន់ នល់ ហ្នឹងមានមូលដ្ឋានទ័ពអាកាស?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:២១:២០]

**លោក ឃីត វេយ្ន័រ៖**

លោកប្រធាន ខ្ញុំគិតថាជាសំណួរជាន់គ្នា សំណួរដដែលៗ ដោយសារតែមានការសួរពីរដង ហើយក្នុងពេលដែលលោក ហេដឌ័រ មកទីនេះដើម្បីផ្តល់សក្ខីកម្មទាក់ទងទៅនឹងកម្លាំងទ័ពអាកាសរបស់ លន់ នល់។ ខ្ញុំសូមជំទាស់ដោយសារតែវាជាសំណួរច្រំដែល។ ព្រោះលោក ហេដឌ័រ បាននិយាយច្រើនដងហើយអំពីចំណុចទាំងអស់នេះ។ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណ។ បើសិនជាគាត់ឆ្លើយហើយ មិនអីទេ។ ក៏ប៉ុន្តែខ្ញុំចង់ឲ្យគាត់បញ្ជាក់ថាប្រភពយោធាអ្វីខ្លះដែលបានប្រាប់លោកពាក់ព័ន្ធទៅនឹងទ័ពអាកាសរបស់ លន់ នល់ នេះ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ជាដំបូងគឺថាខ្ញុំទទួលបានមន្ត្រីពីកងទ័ពអាកាសខ្មែរក្រហមខ្លួនឯងផ្ទាល់។ ទី២ ប្រភពចម្បងរបស់ខ្ញុំ គឺសេនានុព័ន្ធអាមេរិកប្រចាំស្ថានទូតសហរដ្ឋអាមេរិក ហើយព្រមទាំងសេនានុព័ន្ធជប៉ុនប្រចាំស្ថានទូតជប៉ុន។ ជាពិសេសគឺអនុព័ន្ធយោធារបស់ថៃ សាំងហ្គាពួរ និងម៉ាឡេ ដែលខ្ញុំធ្លាប់ជួបជាញឹកញាប់ផងដែរ។ បើតាមតែខ្ញុំចាំគឺថាខាងជប៉ុន ហើយនិងខាងអាមេរិក គឺផ្តល់ព័ត៌មានលម្អិតទៅដល់អ្នកដែលចង់ដឹង។ សូមអរគុណ។

[០៩:២៣:០៧]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកបានលើកឡើងជាមួយនឹងមេធាវី កូប៉េ ដែលលើកឡើងជាឈ្មោះ ស៊ីដនី ស្កេនប៊ឺក។ ហើយលោកបានឆ្លើយថា លោកមិនបានទាក់ទងជិតស្និទ្ធជាមួយគាត់ទេ ប៉ុន្តែលោកស្គាល់គាត់។ គាត់ជាអ្នកកាសែត។ លោក ស៊ីដនី ស្កេនប៊ឺក គាត់បានមកផ្តល់សវនាការកាលពីថ្ងៃទី០៧ ខែមិថុនា ហើយគាត់បានលើកឡើងអំពីការទម្លាក់គ្រាប់បែកដែលធ្វើឡើងដោយកងទ័ព លន់ នល់ នៅពេលដែលគាត់មកឆ្លើយនៅទីនេះ ហើយនិងនៅក្នុងអត្ថបទកាសែតរបស់គាត់ ដែលគាត់បានផ្តល់ជូនអង្គជំនុំជម្រះ និងភាគីហើយឯកសារនោះ គឺឯកសារ D226/1/4/3.1 គឺថ្ងៃទី០១ ខែមីនា នៅក្នុងកាសែតរបស់គាត់។ លោកៗនៅភ្នំពេញកាលពីថ្ងៃទី១ ខែមីនា។ ដូច្នេះលោកចាំទេថាមានការទម្លាក់គ្រាប់បែកនៅថ្ងៃនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:២៤:២៤]

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន ខ្ញុំមើលទៅហាក់ដូចមានការប្រែប្រួលបន្តិចបន្តួចនៅលើអ្វីដែលមេធាវីការពារក្ដីបានធ្វើ។ ប្រសិនបើគេបាននិយាយអំពីសក្ខីកម្មរបស់ ស៊ីដនី ស្កេនប៊ឺក ដូច្នេះយើងសូមស្នើសុំផ្ដល់ជាទំព័រក៏ដូចជាលេខ ERN ឬក៏ពេលវេលាដែលបាននិយាយនៅក្នុងឯកសារនេះ ព្រមទាំងឃ្លាជាក់លាក់ដែលត្រូវដកស្រង់ឲ្យសាក្សីស្ដាប់។

ទី២ ប្រសិនបើយើងនិយាយយោងទៅលើឯកសារ ដូច្នេះសូមមេត្តាផ្ដល់ឲ្យនូវឃ្លាជាក់លាក់នៅក្នុងឯកសារដែលត្រូវលើកយកមកបង្ហាញជូនសាក្សី។ ខ្ញុំគិតថា នេះជាវិធីសាស្ត្រធម្មតា វិធីសាស្ត្រទូទៅដែលយើងតែងតែធ្វើនៅក្នុងការដកស្រង់។ ពួកមេធាវីការពារក្ដីបានលើកយកនូវប្រភពជាច្រើនដោយមិនមានជាលេខយោង ឬក៏ឯកសារយោងយកមកសួរ។ ខ្ញុំគិតថា ជាការដែលមិនត្រឹមត្រូវ មិនល្អនោះទេ។ វាជាការមិនជួយសម្របសម្រួលទៅដល់អ្នកដទៃ ហើយវាមិនមែនជាបទដ្ឋានដ៏ល្អដែលយើងត្រូវធ្វើនោះទេ។

ខ្ញុំនិយាយដូច្នេះ ដើម្បីឲ្យមានលក្ខណៈជាអាជីពខ្លាំងជាងនេះបន្តិចនៅក្នុងការអនុវត្តការងារ។ ខ្ញុំធ្វើដូច្នេះមិនមែនចង់ឲ្យមានការដែលធ្វើការដាក់សំណួរមក ហើយលើកនូវប្រភពជាច្រើនសួរថាមានយ៉ាងម៉េចៗអីយ៉ាងនោះ។ ដូច្នេះខ្ញុំគិតថាវាហាក់ដូចជារញ៉េរញ៉ៃ ហើយជាច្របូកច្របល់បន្តិច។ ខ្ញុំចង់ឲ្យមានលក្ខណៈជាអាជីពបន្តិចនៅពេលនេះ។

[០៩:២៦:០១]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំឃើញថា សហព្រះរាជអាជ្ញាគាត់មានភារកិច្ចជំទាស់ទៅនឹងគ្រប់សំណួររបស់ខ្ញុំ ល្អណាស់អ៊ីចឹង។ ប្រសិនបើយើងបន្តអ៊ីចឹងទៀត ធ្វើអ៊ីចឹងទៀតទៅ។ ខ្ញុំយល់ថាអង្គជំនុំជម្រះផ្ដល់ពេលឲ្យខ្ញុំតិចតួចណាស់។ ដូច្នេះខ្ញុំព្យាយាមធ្វើឲ្យល្អ ដើម្បីកុំឲ្យមានការជំទាស់។ ចំពោះការជំទាស់មុននេះ ពិតណាស់ខ្ញុំត្រូវតែផ្ដល់លេខយោង ហើយខ្ញុំបានផ្ដល់ឯក -- លេខយោងហើយ គឺសវនាការថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ គឺប្រតិចារឹកស្ដាប់កំណត់ហេតុ -- ស្ដាប់ចម្លើយរបស់ ស៊ីដនី ស្កេនប៊ឺក គឺលេខ E1/201 ហើយអម្បាញ់មិញនេះ គឺខ្ញុំនិយាយអំពីឯកសារ D226/1/1/4/3.1។ ហើយលេខ ERN នោះគឺថា មានតែជា

អង់គ្លេសទេ ពីព្រោះថាឯកសារនេះជាកំណត់ត្រាដែលផ្តល់មកយឺតពេលបន្តិចហើយ ដែលលោក ស៊ីដនី ស្កេនប៊ឺក ហើយជាភាសអង់គ្លេសនោះគឺ 00898227 ។

[០៩:២៧:០៨]

មូលហេតុដែលខ្ញុំមិនបង្ហាញ ERN ហ្នឹងដោយសារតែខ្ញុំមិនចង់បង្ហាញឯកសារហ្នឹងជូនសាក្សី។ ខ្ញុំគ្រាន់តែបង្ហាញលេខឯកសារទៅដើម្បីឲ្យភាគី និងអង្គជំនុំជម្រះដឹងអំពីថា ខ្ញុំនិយាយពីអ្វី ហើយខ្ញុំនិយាយអំពីសម័យកាលមួយណា។

ដូច្នេះសំណួររបស់ខ្ញុំនោះ គឺដើម្បីបង្កើតជាបរិបទ ដើម្បីឲ្យភាគី និងអង្គជំនុំជម្រះក៏ដូចជាសាក្សីយល់អំពីអ្វីដែលខ្ញុំចង់សួរ។ ដូច្នេះកាលពីថ្ងៃ០១ ខែមីនា ឆ្នាំ១៩៧៥ នោះ លោកនៅភ្នំពេញ។ ដូច្នេះតើលោកនៅចាំទេថា មានការទម្លាក់គ្រាប់បែកនោះ? ដូច្នេះសំណួរខ្ញុំនៅតែមានសុពលភាពដដែល។ ខ្ញុំសូមផ្តល់ការបញ្ជាក់បន្ថែម។ ខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះថា ខ្ញុំមានឯកសារយោងច្រើន ហើយវាត្រូវការពេលច្រើនណាស់ ហើយប្រសិនបើសហព្រះរាជអាជ្ញាចង់ឲ្យខ្ញុំផ្តល់ឯកសារយោងក្នុងគ្រប់តែសំណួរនោះ គឺថាខ្ញុំមិនអាចធ្វើបានទេ ខ្ញុំមិនអាចបញ្ចប់នៅថ្ងៃនេះបានទេ ព្រោះថាឯកសារយោងនោះច្រើនណាស់ ហើយបើផ្តល់លេខគ្រាប់តែលេខយោងទាំងអស់នុំងធ្វើមិនទាន់ទេ។ ដូច្នេះ តើអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំបន្តទៀត ឬក៏យ៉ាងម៉េច?

[០៩:២៨:២៣]

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន អ្វីដែលខ្ញុំស្នើសុំ គឺជាការនិយាយយោងទៅលើពេលវេលានៅក្នុងប្រតិចារឹករបស់លោក ស៊ីដនី ស្កេនប៊ឺក នៅខែ៥ -- ខែ៦ តែប៉ុណ្ណោះ។ ដូច្នេះខ្ញុំគិតថា គាត់ដឹងថាខ្ញុំចង់និយាយអំពីអ្វី។ ខ្ញុំចង់ដឹងអំពីពេលវេលានៅក្នុងប្រតិចារឹករបស់លោក ស៊ីដនី ស្កេនប៊ឺក តែប៉ុណ្ណោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំអត់ទាន់ អត់មានម៉ោងពេលទេ ក៏ប៉ុន្តែអម្បាញ់មិញនេះ ខ្ញុំផ្តល់លេខ ERN ជាភាសាអង់គ្លេស ហើយលោកសហព្រះរាជអាជ្ញាអាចមើលឃើញហើយ គឺឯកសារលេខ D226/1/4/3.1 ERN ជាភាសាអង់គ្លេសគឺ 00898227។

ដូច្នេះនេះ ខ្ញុំនិយាយអំពីថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៥ ហើយថ្ងៃនុំងហើយដែលលោក ស៊ីដនី ស្កេនប៊ឺក គាត់បាននិយាយថា មានការទម្លាក់គ្រាប់បែកនោះ។

**លោក ឃីត រេយ៍ន័រ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា គួរតែត្រូវបានសរុបហើយ ដើម្បីឱ្យអង្គជំនុំជម្រះដោះស្រាយលើបញ្ហានេះឱ្យបានច្បាស់លាស់ ហើយប្រសិនបើពុំដូច្នោះទេ ហាក់ការដេញដោលនេះអត់អាចទៅមុខបានទេ ហើយប្រហែលជាមួយព្រឹកនេះទល់នឹងពេលសម្រាកទំនងជាគ្រាន់តែតំណាងសហព្រះរាជអាជ្ញាងើបឈរហើយនិងភាគីម្ខាងទៀតងើបឈរប៉ុណ្ណោះ មិនអាចដោះស្រាយបញ្ហានេះបានទេ។

សូមលោកនិយាយឱ្យបានច្បាស់លាស់ ហើយឱ្យបានសព្វគ្រប់ទៅ ហើយភាគីម្ខាងទៀតតបទៅអង្គជំនុំជម្រះនឹងសម្រេចលើបញ្ហានេះឱ្យបានច្បាស់លាស់តែម្តង។ ពុំដូច្នោះទេ យើងឃើញថាវាបីបួនដងហើយ គ្រាន់តែងើបឈរចុះឡើងៗនេះ មិនទាន់បានលទ្ធផលអ្វីទាល់តែសោះ។

[០៩:៣០:១៣]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ប្រសិនបើជាឯកសារ D226/1/4/3.1 ថាតើឯកសារនេះនៅក្នុងបញ្ជីដែលបានតម្រូវនោះហើយឬនៅ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមទោស យើងបានប្រើឯកសារហ្នឹងច្រើនលើកច្រើនសាមកហើយ ហើយនៅពេលដែលលោក ស្តេនប៊ីក មកផ្តល់សក្ខីកម្មនោះ។ ហើយប្រសិនបើសហព្រះរាជអាជ្ញាយល់ឃើញថា ឯកសារហ្នឹងមិនដឹងនៅឯណានោះ ខ្ញុំសូមអភ័យទោសផង។ ឯកសារនោះ គឺថាយើងប្រើច្រើនហើយ នៅពេលសួរសំណួរសាក្សីនោះ។ ដូច្នេះ ខ្ញុំដឹងថាអង្គជំនុំជម្រះ និងភាគីនឹកឃើញអំពីឯកសារនេះ។

ដូច្នេះ តើខ្ញុំបន្តទៅទៀត ឬក៏យ៉ាងម៉េចលោកប្រធាន? ព្រោះថាខ្ញុំចាប់ផ្តើមបានបន្តិចទេ គឺមានជំទាស់រហូត។ ហើយជំទាស់ហ្នឹងគឺថាកាន់តែច្រើនឡើងៗជាបន្តបន្ទាប់គ្នារហូត ពីសំណាក់សហព្រះរាជអាជ្ញា។ តាមរយៈក្រុមរបស់ខ្ញុំនោះ គាត់ប្រាប់ថាគឺនៅម៉ោង ១១:៣២នាទី ដែលយើងនិយាយអំពីបញ្ហានេះជាមួយលោក ស៊ុងនី ស្តេនប៊ីក។ ដូច្នេះ កាលណាខ្ញុំសួរនេះ គឺថាដើម្បីឱ្យបានលឿន ហើយបើសិនជាកាន់តែឱ្យលេខទៅ កាន់តែមានបញ្ហាទៅវិញ។ ដូច្នេះ ខ្ញុំគួរតែទទួលបានការអនុញ្ញាតឱ្យបន្តការសួរសំណួរតទៅទៀត។

[០៩:៣១:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបាទ!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោក ហេងឌ័រ សូមអភ័យទោសដែលកាត់ផ្ដាច់នូវការឆ្លើយចម្លើយរបស់លោក។ ខ្ញុំដូចជាភ្លេចហើយ មិនដឹងថាលោកឆ្លើយហើយនៅទេ។ កាលខ្ញុំសួរនោះ គឺថាសួរលោកថា តើលោកបាននៅថ្ងៃ០១ ខែមីនា ឬក៏ថ្ងៃផ្សេងទៀតនោះ លោកបានឃើញការទម្លាក់គ្រាប់បែកពីកងទ័ព លន់ នល់ ទេ?

**លោក ស៊ីវ ហេងឌ័រ៖**

**ឆ៖** គឺខ្ញុំបានឃើញការទម្លាក់គ្រាប់បែកពីយន្តហោះ ក៏ប៉ុន្តែសំខាន់នោះគឺទម្លាក់មកពី តេ-២៨។

[០៩:៣២:៥២]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់។ ឥឡូវនេះ ខ្ញុំចូលទៅចំណុចផ្សេងទៀត កាលពីថ្ងៃទី១១ ខែកក្កដា លោកបានឆ្លើយជូនសហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងរបាយការណ៍ព័ត៌មានសាធារណរដ្ឋខ្មែរ គឺប្រតិចារឹកបណ្ដោះអាសន្ន គឺជាភាសាអង់គ្លេស គឺនៅម៉ោង១៤:១៥:១៤ ជាភាសាអង់គ្លេស ដោយសារតែពេលហ្នឹង គឺថាការបកប្រែជាភាសាបារាំងមានបញ្ហា។ ដូច្នេះហើយបានជាខ្ញុំលើកយកនូវឯកសារភាសាអង់គ្លេសទៅវិញនោះ។

លោកសាក្សី លោកបានលើកឡើងអំពីរបាយការណ៍ព័ត៌មានសាធារណរដ្ឋខ្មែរ ដែលបង្ហាញអំពីអង្គការលេខនៃចលនាកុម្មុយនីស្ត និងជាពិសេសអង្គការលេខយោធា។ ខ្ញុំរកឃ្លាទាំងស្រុង អ៊ីចឹងខ្ញុំត្រូវតែដកស្រង់ជាភាសាអង់គ្លេស ដើម្បីឲ្យភាគីទាំងអស់តាមដានទាន់នូវអ្វីដែលខ្ញុំចង់លើកឡើង។

នៅប្រតិចារឹកសវនាការបណ្ដោះអាសន្នជាភាសាអង់គ្លេស គឺទំព័រ៨២ ក្រោយម៉ោង១៤:១៥ នាទីបន្តិច។ សហព្រះរាជអាជ្ញាបានសួរសំណួរទៅកាន់លោក ថាតើលោកចាំអំពីរចនាសម្ព័ន្ធយោធាដែរឬទេ? នៅថ្ងៃនោះ លោកឆ្លើយដូចតទៅ។

សូមឲ្យអ្នកបកប្រែជួយអាន្យាស្រ័យផង ព្រោះថាខ្ញុំនិយាយជាភាសាអង់គ្លេសហើយ។

[០៩:៣៤:៥៩]

(អានជាភាសាអង់គ្លេស៖) “ជាការពិត យ៉ាងហោចណាស់នៅក្នុងសម្ភាសឯកសារទាំងអស់នេះ សាឡុត ស គឺនៅថ្នាក់លើគេ។ គឺជាចំណុចដែលវាមានការខ្ចាស់គ្នានៅក្នុងសហគមន៍ ក៏ប៉ុន្តែយើងគិតថា វាត្រឹមត្រូវ។ របាយការណ៍ធ្វើឡើងដោយ អ៊ុក សំ ដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធបក្ស ក្រោយមករត់ចូល ទៅខាងសាធារណរដ្ឋខ្មែរ ធ្វើរបាយការណ៍ពីក្រុមស៊ើបអង្កេតរបស់សាធារណរដ្ឋខ្មែរ ហើយក្រោយមក បោះពុម្ពសៀវភៅ ហើយគាត់បានលើកឡើងថា សាឡុត ស គឺជាប្រធានកំពូលរបស់ចលនាកុម្មុយ-នីស្ត។ នៅក្នុងសហគមន៍កុម្មុយនីស្តនោះ គឺគេបានលើកឡើងបញ្ហាទាំងអស់នេះ។ តាមខ្ញុំចាំគឺថានៅថ្ងៃ នោះគឺមាន វន វ៉េត គឺជាប្រធាននៅភូមិភាគពិសេស។ ហើយចំពោះមានឈ្មោះមួយចំនួនទៀតត្រូវបាន ប្រើប្រាស់នៅក្នុងឯកសារនោះ។ ចំណុចទី២ ក៏មានលើកឡើងអំពី តាម៉ុក ផងដែរ។ នៅភូមិភាគបូព៌ាគេ ថា សោ ភឹម ជាប្រធានភូមិភាគ។ ហើយខ្ញុំគិតថា សូ វណ្ណា ហើយនិងលេខាភូមិភាគជាច្រើនទៀត ក៏ត្រូវបានគេដាក់ឈ្មោះទៅក្នុងនោះផងដែរ។ នៅយើងឃើញមានការលើកឡើងអំពីលេខាខាងពាយ័ព្យ ខាងបស្ចិមផងដែរ”។ សូមបញ្ចប់ការដកស្រង់។

[០៩:៣៦:៥១]

លោកសាក្សីជាបឋមនោះ ខ្ញុំចង់ដឹងថាតើលោកចាំឃ្លាហ្នឹងទេ កាលនុំងគេអត់មានបកប្រែជា ភាសាបារាំងទេ។ ដូច្នេះសូមឲ្យលោកនិយាយពីចំណុចនេះឡើងវិញ ហើយខ្ញុំនឹងត្រឡប់មកនិយាយអំពីអ្វី ដែលលោកបានឆ្លើយនៅក្នុងចម្លើយនោះ គឺថា សាឡុត ស គឺថានៅកំពូលនៃអង្គការលេខ។ អ៊ីចឹងតើ ឈ្មោះបដិវត្តន៍គាត់ឈ្មោះអ្វី?

**ឆ៖** នៅក្នុងឯកសារនោះ ខ្ញុំមិនគិតថាមានការលើកឡើងឈ្មោះរហស្សនាមនោះទេ។ គឺមិន មែនឈ្មោះក្រៅដែលគេបានស្គាល់ជាទូទៅថាជា ប៉ុល ពត នោះទេ។ គេអត់បានប្រើឈ្មោះហ្នឹងទេ។ ខ្ញុំ អាចបញ្ជាក់ -- ខ្ញុំមិនអាចបញ្ជាក់ថា ខ្ញុំមិនដែលធ្លាប់ឮឈ្មោះរហស្សនាមនោះទេ។ លើកលែងតែក្រោយ មកឈ្មោះហ្នឹងត្រូវបានគេហៅជាសាធារណៈក្រោយពេលកាន់អំណាច។ ហើយមុនឆ្នាំ៧៥នោះ ខ្ញុំមិន ដែលធ្លាប់ឮគេហៅឈ្មោះហៅក្រៅ ដូច្នោះដោយអ្នកណាម្នាក់នោះទេ។

[០៩:៣៨:១១]

**ស៖** ហើយលោកក៏បានឆ្លើយផងដែរថា មានការពិភាក្សាគ្នាអំពីការពិត ឬក៏អត់ ដែលថា សូ មេ *(តាមសូរស័ព្ទ)* នោះគឺជាប្រធានចលនា ជាអ្នកដឹកនាំចលនា។ តើហេតុអ្វីបានជាមានការពិភាក្សា បែបនេះ? តើអ្វីដែលរារាំង ឬក៏រំខានដល់ភ្នាក់ងារទទួលព័ត៌មាននៅពេលនោះៗ បើតាមអ្វីដែលលោក

ទទួលបាននោះ?

**ឆ៖** ការព្យាយាមធ្វើការវិភាគ ឬក៏ការប្រមូលការវិភាគអំពីបញ្ហាព័ត៌មានស៊ើបការណ៍របស់ថ្នាក់ដឹកនាំខ្មែរក្រហម គឺគេបានធ្វើឡើងក្នុងដំណាក់កាលមួយចំនួន ហើយគេបានរៀបរាប់មកកាន់ខ្ញុំឲ្យបានដឹង។ បុគ្គលនៅក្នុងស្ថានទូតនោះ គឺថាគាត់បានមានសិទ្ធិមើលទិន្នន័យព័ត៌មានស៊ើបការណ៍។ ពីដំបូងស្ថានទូតបារាំង គឺថាទទូច ដែលគេហៅថា “ខ្មោចទាំងបី” នោះ ដែលក្នុងនោះរួមមាន ខៀវ សំផន ផងដែរ គឺគេគិតពួកទាំងបីនាក់នេះស្លាប់ហើយ។ ហេតុដូច្នេះហើយរូបថតគេបានផលិតឡើងនៅក្នុងខែមីនា ឆ្នាំ៧០ ហើយគេហៅពួកគេថា ជាមេដឹកនាំរបស់ហ្រ្គុង និងហ្វុង តែព័ត៌មាននោះជាព័ត៌មានក្លែងក្លាយ។

[០៩:៣៩:៤៧]

ក្រោយពីពេលនោះមកនៅចុងក្រោយ គឺគេទទួលស្គាល់ថាអ្នកទាំងបីនាក់នោះអត់ស្លាប់ទេ តាមពិតនៅរស់។ ហើយមានការពិភាក្សាចំណុចហ្នឹង ហើយគេបានរាយការណ៍ប្រាប់ចំណុចហ្នឹងឲ្យខ្ញុំបានដឹងផងដែរ។ ហើយគេបានពិភាក្សាផងថា អ្នកទាំងបីនុំងកាន់កាប់អំណាចជាក់ស្តែង ឬក៏យ៉ាងម៉េច។ ហើយមានចំណុចដែលគេលើកឡើងប្រាកដថា ខ្ញុំបានលើកឡើងបញ្ហាហ្នឹងនៅក្នុងចំណោមក្រុមរបស់ខ្ញុំ ហើយក៏មានការជជែកគ្នាច្រើនដែរទៅលើបញ្ហាហ្នឹង ពាក់ព័ន្ធទៅនឹងថា តើនរណាគេជាអ្នកនៅថ្នាក់កំពូល ហើយក៏ពិភាក្សាអំពីឥទ្ធិពលរបស់វៀតណាម និងចិនផងដែរ។

ការជជែកក្តៅគគុកនាពេលនោះគឺថា តើខ្មែរក្រហមមានភាពឯករាជ្យដាច់ចេញពីថ្នាក់ដឹកនាំរបស់វៀតណាមដែរឬទេ។ ជាពេលនោះជាយូរមកហើយ គឺគេបានប្រាប់ខ្ញុំថា ភ្នាក់ងារ សេ.អ៊ី.អា នៅតែវ៉ាន់ គឺបានបន្តចង់ទទូចឡើងថាចលនាខ្មែរក្រហមគឺស្ថិតនៅក្រោមការគ្រប់គ្រងកុម្មុយនីស្តរបស់វៀត-ណាម។ ការយល់ឃើញដូច្នោះតាមខ្ញុំចាំ នៅពេលដែលគេប្រាប់ខ្ញុំ គឺអ្នកវិភាគមួយចំនួន គាត់បានជំទាស់ទៅលើការយល់ឃើញដូច្នេះ។ ហើយជាទូទៅព័ត៌មានជំទាស់ទាំងអស់ហ្នឹង វាមានលើកឡើងនៅក្នុងរបាយការណ៍ស៊ើបការណ៍ ហើយគេបានប្រាប់ខ្ញុំផងដែរ។ ហើយគេមានការខ្វាស់គ្នាទៅលើអ្នកដែលធ្វើការវិភាគនៅទីតាំងមូលដ្ឋានជាក់លាក់ និងអ្នកនៅថ្នាក់ៗលើ។

[០៩:៤១:៣០]

ហើយនៅតាមសក្ខីកម្ម និងកិច្ចសម្ភាសន៍របស់ខ្ញុំមួយចំនួន គឺគេបានទទួល --គឺអាចទទួលស្គាល់ថាខ្មោចទាំងបីនោះគឺមិនមែនស្ថិតនៅជួរថ្នាក់ដឹកនាំកំពូលនោះទេ។

ចំណុចទី២ គឺអ្នកដែលនៅខាងលើនោះ គេលើកឡើងថាមាន សាឡុត ស, នួន ជា, តាម៉ុក, វន វ៉េត, កុយ ធួន ហើយជាញឹកញាប់នោះ គឺគេបានលើកឡើងឈ្មោះតែប៉ុណ្ណឹងទេ។ ហើយក្រោយមកគឺគេបានប្រាប់ខ្ញុំនៅក្នុងចំណោមភ្នាក់ងារស៊ើបការណ៍របស់ស្ថានទូតអាមេរិកនោះ គេប្រាប់ថា គេជឿជាក់ថាខ្មែរក្រហមមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាមនោះទេ។ ដូច្នេះហើយវាមានទ្រឹស្តីដែលថា អៀង សារី នោះគាត់ជាខ្មែរក្រហម។ ហេតុដូច្នេះហើយ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀត-ណាម។ ដូច សុន សេន ក៏ជាខ្មែរក្រហម។ ដូច្នេះទើបគេយល់ថា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម។ ក៏ប៉ុន្តែគ្មានអ្នកណាដឹងថា តើ សាឡុត ស ជាអ្នកនោះទេ។ គេមានការលើកឡើងពិភាក្សាអំពីលោក នួន ជា ផងដែរ ក៏ប៉ុន្តែតាមអ្វីដែលខ្ញុំបានស្តាប់ឮនាពេលនោះ គឺវាបានបង្ហាញថា វាគ្រាន់តែជាការនិយាយការទាយស្មានគ្រប់ៗគ្នា។

[០៩:៤២:៤៨]

ខ្ញុំចាំថាចំណុចទាំងអស់ហ្នឹង គឺពិភាក្សាជជែកគ្នានៅពេលនោះ។ ខ្ញុំចាំជាក់លាក់ហ្នឹងដោយសារថាតែ ខ្ញុំមិនដឹងថាសក្ខីកម្មមុនខ្ញុំបានឆ្លើយរួចហើយ ឬនៅនោះទេ។ គឺខ្ញុំចាំច្បាស់ដោយសារតែគេស្នើសុំឱ្យខ្ញុំធ្វើការងារនេះ គឺក្រោយ១៧ មេសា ឆ្នាំ៧៥ ភ្លាមៗ នៅពេលដែលខ្ញុំទៅធ្វើជានិពន្ធនាយកនៅហុងកុង។ ហើយឱ្យខ្ញុំធ្វើការងារវិភាគទៅលើមេដឹកនាំខ្មែរក្រហម។ ហើយខ្ញុំទទួលមុខតំណែងហ្នឹងៗ គឺថាមានភស្តុតាង ព័ត៌មានច្រើនណាស់ឱ្យខ្ញុំបានដឹង។ ហើយគេបានប្រាប់ខ្ញុំថា មេដឹកនាំខ្មែរក្រហមមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាមនោះទេ គឺឯករាជ្យជាសម្ព័ន្ធនយោបាយមួយឯករាជ្យ។ គេប្រាប់ខ្ញុំដូច្នេះ។ ក៏ប៉ុន្តែរឿងរ៉ាវហ្នឹងមិនដែលលេចចេញមកក្នុងកាសែតនោះទេ។ អ្នកដែលនៅញូវយ៉កនោះ គឺថាគេប្រាប់ខ្ញុំ ហើយគេស្ថិតនៅក្នុងសហគមន៍ស៊ើបការណ៍ ហើយគេនិយាយថា អ្វីដែលខ្ញុំយល់ដូច្នេះគឺខុស។

ក៏ប៉ុន្តែចំណុចទាំងអស់ហ្នឹង គឺថាខ្ញុំធ្វើការងារហ្នឹង ដូច្នេះហើយទើបខ្ញុំមានព័ត៌មានលម្អិត។ ខ្ញុំបានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ សួរគេថាតើមានអ្វីកើតឡើង ហើយមានព័ត៌មានអ្វីខ្លះនៅក្នុងសហគមន៍ស៊ើបការណ៍របស់បរទេសនោះ? ដូច្នេះហើយទើបខ្ញុំចាំបានច្បាស់ណាស់ទៅលើរឿងរ៉ាវទាំងអស់នេះ។

[០៩:៤៤:២៥]

**ស៖** ខ្ញុំចូលទៅប្រធានបទផ្សេងទៀត។ ឥឡូវនេះ ខ្ញុំនិយាយអំពីបញ្ហាដែលលោកបានដឹងនៅ

ពេលនោះ ហើយនិងដឹងនៅពេលក្រោយៗទៀត នៅពេលដែលលោកធ្វើការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងភាពជាអ្នកដឹកនាំ។ កាលពីសវនាការនៅថ្ងៃទី១០ ខែកក្កដា ប្រហែលជាម៉ោង ១៤:០៨នាទី សហព្រះរាជអាជ្ញាបានសួរលោកអំពីកិច្ចសម្ភាសន៍របស់លោកជាមួយ ជួន ប្រសិទ្ធិ។ ហើយនៅពេលដែលលើកឡើងអំពីឯកសារ E3/22 ដែលមានចំណងជើងថា "លទ្ធិកុម្មុយនីស្តកម្ពុជា និងគំរូវៀតណាម"។ នៅពេលដែល នៅម៉ោង១៤:០៨នាទីនោះ លោកសហព្រះរាជអាជ្ញាបានលើកឡើងអំពីកំណត់សម្គាល់ជើងទំព័រលេខ៦៩ ហើយនៅក្នុងនោះលោកបានលើកឡើងអំពីកិច្ចសម្ភាសន៍ជាមួយ ជួន ប្រសិទ្ធិ ថ្ងៃទី៨-៩ វិច្ឆិកា ឆ្នាំ១៩៩៩ -- (សូមទោស) ៧៩ នៅញូវយ៉ក។ ហើយនៅម៉ោង១៤:១០នាទី ខ្ញុំមើលទៅលោកដូចជាមិនដឹងឃើញ។ ដូច្នេះខ្ញុំរំឭកឡើងវិញគឺថា នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង១៤:០៨នាទី លោកបានលើកឡើងអំពីកិច្ចសម្ភាសន៍ជាមួយ ជួន ប្រសិទ្ធិ នៅពេលដែលលោកឆ្លើយជាមួយសហព្រះរាជអាជ្ញាអន្តរជាតិនោះ។ តើលោកចាំពីចំណុចនេះទេ?

[០៩:៤៦:០៩]

**ឆ៖** មានកិច្ចសម្ភាសន៍មួយចំនួនដែរ ដែលខ្ញុំធ្វើឡើងជាមួយ ជួន ប្រសិទ្ធិ ក៏ប៉ុន្តែអ្វីដែលខ្ញុំគ្រវីក្បាលអម្បាញ់មិញនេះ ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទដែលលោកស្រីបានលើកឡើង។ ខ្ញុំគិតថា ខ្ញុំសម្ភាសឆ្នាំ៧៨ទេ មិនមែន៧៩ នោះឡើយ។ ខ្ញុំមិនដឹងថា តើគាត់ស្ថិតនៅក្នុងគណៈប្រតិភូរបស់ អៀង សារី នៅពេលដែលខ្ញុំជួបនៅញូវយ៉ក ឆ្នាំ៧៨ ឬក៏អត់នោះឡើយ។ ប្រសិនបើគាត់ស្ថិតនៅក្នុងហ្នឹង ខ្ញុំមិនអាចនឹកឃើញតាមការចងចាំថា ខ្ញុំបានសម្ភាសដូចដែលលោកស្រីបានលើកឡើងនៅពេលនោះៗទេ។ ក៏ប៉ុន្តែគឺថា ឆ្នាំ៧៨ ដែលខ្ញុំបានសម្ភាសគាត់ គឺគេមានវ៉ៃនៅក្នុងលេខយោងចំណុចដកស្រង់ច្បាស់ណាស់ទៅលើថ្ងៃខែនេះ។

**ស៖** ប្រហែលជាអ៊ីចឹងមើលទៅ ព្រោះថាជាភាសាបារាំង គឺថាញូវយ៉កឆ្នាំ១៩៧៧ ដូច្នេះខ្ញុំនឹងពិនិត្យមើលឡើងវិញនូវឯក -- កាលបរិច្ឆេទនេះ។ បើតាមការចងចាំរបស់លោកនោះ លោកបានជួបលោក ជួន ប្រសិទ្ធិ គឺថានៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំនឹងពិនិត្យមើលឯកសារឲ្យបានច្បាស់ ហើយខ្ញុំនឹងត្រឡប់មកសួរលោកពាក់ព័ន្ធនឹងចំណុចនេះវិញ។

[០៩:៤៧:៣២]

ដូច្នេះខ្ញុំសូមរំឭកនៅអ្វីដែលលោកបានឆ្លើយកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣ គឺនៅចម្លោះម៉ោង១៤:០៨នាទី និង ១៤:១០នាទី។ ចំពោះកិច្ចកាលបរិច្ឆេទសម្ភាសនេះ យើងនឹងកំណត់នៅពេល

ក្រោយ។ ក៏ប៉ុន្តែលោកបានឆ្លើយថាលោកបានជួប ប្រសិទ្ធ នៅពេលដែលលោកនិយាយអំពី ខៀវ សំផន ហើយលោកថា គាត់ហ្នឹងជាលេខាផ្ទាល់របស់ នួន។ គាត់បាននិយាយអំពីរឿងរ៉ាវស្រដៀងគ្នា ក៏ប៉ុន្តែខ្ញុំមិនចាំអំពីពាក្យដែលគាត់និយាយឲ្យច្បាស់នោះទេ។ ខ្ញុំចង់សួរលោកថា ខ្ញុំមិននិយាយអំពីកិច្ចសម្ភាសន៍របស់លោកជាមួយគាត់ក្នុងក្របខ័ណ្ឌនៃការងារ -- នៃស្រាវជ្រាវរបស់លោកនៅសាលាទេ គឺថាខ្ញុំចង់និយាយអំពីកិច្ចសម្ភាសន៍ក្នុងក្របខ័ណ្ឌការងាររបស់លោកនៅការិយាល័យរបស់សហព្រះរាជអាជ្ញា ឬការិយាល័យសហចៅក្រមស៊ើបអង្កេត។ តើលោកមានកំណត់ហេតុស្តាប់ចម្លើយ ជួន ប្រសិទ្ធិ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ -- មិថុនា ឆ្នាំ២០០៩? តើលោកចាំថា លោកបានសម្ភាសគាត់ទេ ហើយតើលោកមានឯកសារនេះទេ?

[០៩:៤៩:១០]

**ឆ៖** ខ្ញុំមាន។ ខ្ញុំបានដឹងថា ខ្ញុំដឹងមានឯកសារនេះ។ ខ្ញុំមិនសម្ភាសដោយខ្លួនឯងផ្ទាល់ទេ គឺថាកិច្ចសម្ភាសន៍ហ្នឹង គឺថាធ្វើឡើងដោយមន្ត្រីនៅក្នុងការិយាល័យនេះដែលទទួលការចាត់តាំងនៅប្រទេសបារាំង។ ហើយខ្ញុំប្រហែលជាចូលរួមនៅក្នុងការជួយជ្រោមជ្រែងការងាររៀបចំឯកសារសម្រាប់អ្នកស៊ើបអង្កេត ក៏ប៉ុន្តែខ្ញុំមានកំណត់ហេតុ -- ខ្ញុំមិនមានកំណត់ហេតុចំពោះការងារទាំងអស់នេះទេ។ ហើយអ្នកស៊ើបអង្កេតហ្នឹង គាត់ទៅស្តាប់ចម្លើយ ហើយបានដាក់បញ្ចូលកំណត់ហេតុហ្នឹងនៅក្នុងសំណុំរឿង ខ្ញុំក៏នៅពេលនោះមានសិទ្ធិមើលសំណុំរឿងផងដែរ។ ខ្ញុំមិនប្រាកដ ហើយខ្ញុំក៏មិនដឹងថាខ្ញុំមានព័ត៌មានទៀតនិយាយនោះទេ ប្រហែលជាខ្ញុំមាន ហើយប្រហែលជាខ្ញុំមិនមាន ហើយខ្ញុំបានចូលរួមការងារ និងការងារស៊ើបអង្កេតហ្នឹង ខ្ញុំគិតថាគឺគេបានធ្វើដូច្នោះម្តងមែន--

**ស៖** ខ្ញុំសូមកាត់លោក ពេលដែលខ្ញុំសួរលោករាល់ដងនោះ គឺថាមិនមែនដើម្បីសុំឲ្យលោកផ្តល់ជាក់លាក់ទេ គ្រាន់តែថាចង់ដឹង ឬមិនដឹងប៉ុណ្ណឹងទេ។ អ៊ីចឹងលោកគ្រាន់តែឲ្យមូលដ្ឋាននៃការប្រើប្រាស់ហ្នឹងទៅបានហើយ។ អ៊ីចឹងលោកបានឆ្លើយថា លោកបានធ្វើការជាមួយសម្ភារៈនេះ។

**កញ្ញា អង់តា ហ្គីសសេះ**

ហើយលោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះ ទៅលើអេក្រង់ គឺឯកសារ E3/96 គឺជាកិច្ចសម្ភាសន៍របស់លោក ជួន ប្រសិទ្ធិ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០៩ នៅទីក្រុងបារីស។ ERN គឺ 00342220, ERN ជាភាសាអង់គ្លេសគឺ 00346945, ERN ជាភាសាខ្មែរគឺ 00348329។ ដើម្បីភាគីទាំងអស់ គឺកថាខណ្ឌដែលខ្ញុំចង់លើកឡើងមកនោះ គឺនៅទំព័រចុងក្រោយជាភាសាបារាំង។

[០៩:៥១:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៍ន័រ៖**

ឯកសារនេះ លោកប្រធាន មិនបានត្រូវទាញយកចេញមកនោះឡើយ។ មិនមែននៅក្នុងអ៊ីម៉ែលផ្ញើចេញមកពីក្រុមបញ្ជីរបស់លោក ខៀវ សំផន ដែលផ្ញើកាលពីម្សិលមិញនោះឡើយ។ ហើយអ៊ីម៉ែលក្រោយៗក៏មិនមានអំពីឯកសារនេះដែរ។ ខ្ញុំមិនមានព័ត៌មានអំពីឯកសារនេះទេ ខ្ញុំសូមជំទាស់ចំពោះការបង្ហាញនូវឯកសារនេះ មិនមានការទាញយកឯកសារដាក់ចូលក្នុងប្រព័ន្ធឡើយ ហើយខ្ញុំក៏មិនទទួលបានឯកសារនោះដែរ។ ដូច្នេះ ខ្ញុំសូមជំទាស់។

**កញ្ញា អង់តា ហ្គីសសេ៖**

នេះការភ្លេចភ្លាំងរបស់ខ្ញុំហើយ ខ្ញុំសោកស្ដាយណាស់។ អ៊ីចឹងខ្ញុំសូមឲ្យអង្គជំនុំជម្រះមានការបត់បែន អង្កាល់ពីខែកក្កដាហ្នឹង អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបង្ហាញឯកសារមួយដែលមិនបានដាក់ចូលទៅក្នុងអ៊ីនធីហ្វេស ក៏ប៉ុន្តែពេលក្រោយ ខ្ញុំនឹងត្រឡប់មកដាក់ឯកសារនេះចូលវិញ គឺថាឯកសារ ប្រភេទឯកសារ E3 ហើយដែលនិយាយអំពីកិច្ចសម្ភាសន៍របស់ ជួន ប្រសិទ្ធិ ដោយលោកសាក្សីនេះ។ ហើយក៏ក្នុងឯកសារហ្នឹងនិយាយពីលោក ខៀវ សំផន ផងដែរ។

[០៩:៥៣:០៦]

អ៊ីចឹងការដែលភ្លេចភ្លាំងមិនដាក់ចូលទៅក្នុងអ៊ីនធីហ្វេសនេះ ខ្ញុំសូមអភ័យទោសពីសំណាកអង្គជំនុំជម្រះ។ ដូចដែលលោកចៅក្រម ខាតវ៉ាយថ៍ បានលើកឡើងកាលនៅថ្ងៃទី៣ កក្កដា កន្លងមកនេះ គឺថាយើងត្រូវតែមានការបត់បែន ហើយខ្ញុំសូមអភ័យទោស ព្រោះថាឯកសារមានច្រើន ជាច្រើនណាស់ដែលត្រូវបង្ហាញជូនលោក ស្ទីវ ហេដឌ័រ។

អ៊ីចឹងបើសិនជាអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំសូមបង្ហាញតែកថាខណ្ឌមួយទេ ដែលជាពាក្យពេចន៍របស់លោក ជួន ប្រសិទ្ធិ ការដឹងឮអំពីមុខងាររបស់កូនក្ដីរបស់ខ្ញុំ។ ពាក្យពេចន៍ដែលលោក ជួន ប្រសិទ្ធិ បានលើកឡើងនៅពេលនោះ។ អ៊ីចឹងជាការសំខាន់ណាស់ សូមតុលាការមេត្តាពិចារណា។

[០៩:៥៣:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៤:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ដោយសារបញ្ហាឯកសារនេះ គឺមានកំណត់លេខ *អ៊ីស្រី* -- E3 រួចហើយ ហើយបញ្ហានេះក៏ធ្លាប់មានបញ្ហាម្តងរួចហើយ ហើយអង្គជំនុំជម្រះក៏បានមានការបត់បែនអនុញ្ញាតឲ្យភាគីយកមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះដែរ។

ដូច្នេះអង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញលោកស្រីមេធាវី!

មានបញ្ហាអីទៅលោក ស្មីរ ហេងឆ័រ?

**លោក ស្មីរ ហេងឆ័រ៖**

ខ្ញុំមានជាភាសាខ្មែរ ក៏ប៉ុន្តែនៅក្នុងពេលនេះខ្ញុំសូមជាភាសាបារាំង ហើយសូម្បីអង់គ្លេសក៏ខ្ញុំសូមឲ្យបញ្ចាំងឲ្យខ្ញុំមើលផងដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

យើងនឹងព្រីនជាភាសាបារាំងជូនលោក សូមលោកចាំមួយភ្លែតសិន ហើយខ្ញុំសូមអាន ហើយពេលមកក្រោយទៀតលោកអាចមើលតាមក្រោយបាន ហើយធ្វើដូចនេះដើម្បីចំណេញពេលវេលា។ ខ្ញុំបានផ្តល់លេខ ERN ហើយៗ។

[០៩:៥៦:២៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី លោកចង់និយាយឬក៏យ៉ាងម៉េច? ឥឡូវខ្ញុំបន្តសំណួរដែលគេចោទទៅលោកជូន ប្រសិទ្ធិ ដូចតទៅនេះ "សំណួរ៖ តើលោកស្គាល់ ខៀវ សំផន ដែរឬទេ? ចម្លើយ៖ ខ្ញុំចាំមិនបានថាបានស្គាល់គាត់នៅបារាំងទេ គឺខ្ញុំស្គាល់ឈ្មោះគាត់នៅប្រទេសកម្ពុជា នៅពេលដែលគាត់ចេញទស្សនាវដ្តីឡូបស៊ែវ៉ាទ័រ។ ខ្ញុំធ្លាប់សរសេរអត្ថបទនៅក្នុងកាសែតនេះនៅក្រោមរហស្សនាម សាន។ ខៀវ សំផន ល្បីថាជាជនសុចរិតបំផុត។ នៅភ្នំពេញខ្ញុំមានឱកាសជួបគាត់ប៉ុន្មានដងដែរ។ គាត់គឺជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាតំណាងរាស្ត្រ គាត់ជាអ្នកនយោបាយនៅក្នុងរបប សីហនុ និង ប៉ុល ពត។ គាត់គឺជាបណ្ឌិតផ្នែកសេដ្ឋកិច្ច។ ខ្ញុំមិនដឹងថា គាត់ជាសមាជិកគណៈកម្មការមជ្ឈិមឬទេ ទោះបីជាគាត់ជាប្រធានគណៈប្រធានរដ្ឋក៏ដោយ។ មុនឆ្នាំ១៩៧៥ គាត់គឺជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺជាមេបញ្ជាការយោធា ដែលជាតំណែងមានតែឈ្មោះ ព្រោះថា ប៉ុល ពត ជាមេបញ្ជាការពិតប្រាកដ។

នៅពេលនេះដដែល នៅពេលដែលគាត់ធ្វើដំណើរទៅបរទេសគឺ អៀង សារី ជាអ្នកអំណាច ចំណែកឯ ខៀវ សំផន គឺជាប្រធានគណៈប្រតិភូ។ នៅពេលដែលមានគណៈប្រតិភូដឹកនាំដោយ អៀង សារី គឺ អៀង សារី នេះហើយជាអ្នកមានអំណាចពិតប្រាកដ"។ សូមបញ្ចប់ការដកស្រង់។

[០៩:៥៨:២៨]

ខ្ញុំដកស្រង់ចប់ហើយ ឥឡូវខ្ញុំសូមផ្តល់អត្ថបទនេះជាភាសាបារាំងទៅលោក។ ឥឡូវសូមមន្ត្រីតុលាការជួយយកអត្ថបទនេះទៅជូនគាត់។ សំណួរទី១ មុននឹងគេផ្តល់ឯកសារនេះទៅលោក តើលោកមាន តើឯកសារពិតជាឯកសារហ្នឹងហើយឬ ដែលលោកបានពិគ្រោះពេលដែលលោកធ្វើការនៅក្នុង អ.វ.ត.ក យើងនេះ?

**លោក ស្ទីវ ហេដ័រ៖**

**ឆ៖** ខ្ញុំមិនយល់ថា ថាតើលោកស្រីមានន័យយ៉ាងម៉េច នៅពេលដែលនិយាយថាពិគ្រោះយោបល់ជាមួយឯកសារនេះ? ខ្ញុំបានឃើញឯកសារនេះ ហើយខ្ញុំមិនមានតួនាទីក្នុងការវិភាគឯកសារនេះទេ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ គឺថាខ្ញុំបានឆ្លង និងពិនិត្យមើលឯកសារនេះដែរ។

**ស៖** នៅពេលដែលខ្ញុំនិយាយថា "ពិគ្រោះ" ហ្នឹងគឺថាចង់និយាយថា លោកពិនិត្យ វិភាគហ្នឹងហើយ។ អ៊ីចឹងសំណួរខ្ញុំនឹងសួរលើខ្លឹមសារ ដែលលោក ជួន ប្រសិទ្ធិ បានលើកឡើង។ អម្បាញ់មិញនេះ យើងនិយាយអំពីរបាយការណ៍ស៊ើបការណ៍នៃអង្គការលេខយោធា។ នៅក្នុងចម្លើយរបស់គាត់ ជួន ប្រសិទ្ធិ បានពន្យល់ថា៖ "ឋានៈអង្គមេបញ្ជាការរបស់លោក ខៀវ សំផន នោះមានតែឈ្មោះទេ"។

[០៩:៥៩:៥៥]

តើនេះឆ្លុះបញ្ចាំងអំពីអង្គហេតុដែលលោកមាននៅក្នុងឯកសាររបស់លោក ឬក៏តាមរយៈព័ត៌មានដែលលោកទទួលបានក្នុងពេលដែលលោកស្នាក់នៅប្រទេសកម្ពុជា ហើយនិង/ឬក៏នៅក្រោយមកទៀតក្នុងក្របខ័ណ្ឌនៃការបំពេញការងាររបស់លោកនៅការិយាល័យសហព្រះរាជអាជ្ញា ហើយនិងការិយា-ល័យសហចៅក្រមស៊ើបអង្កេត ហើយនិងតាមរយៈការស្រាវជ្រាវលើអ្វីដែលកើតឡើងមាននៅប្រទេសកម្ពុជាដើម្បីសរសេរសៀវភៅរបស់លោក?

**ឆ៖** ពិតជាដូច្នោះមែន។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីចំណុចមួយទៀត ស្តីអំពីទម្រង់ពាក្យពេចន៍ដែលលោកមិនច្បាស់លាស់។ លោកមិនប្រាកដថា ជួន ប្រសិទ្ធិ លោកមិនច្បាស់ថាតើ ជួន ប្រសិទ្ធិ ហ្នឹង បាន

និយាយពាក្យអ្វីច្បាស់ទេ នៅពេលដែលគាត់និយាយថា ខៀវ សំផន ជាលខារបស់ នួន ជា ផ្ទាល់។ កាលនោះលោកបាននិយាយនេះនៅថ្ងៃទី១៧ កក្កដា និយាយទៅកាន់សហព្រះរាជអាជ្ញា។ តើលោកមានព័ត៌មានអីបញ្ជាក់បន្ថែមទៀតទេ នៅពេលដែលលោកនិយាយថា ខៀវ សំផន ជាលេខផ្ទាល់របស់ នួន ជា កាលណោះ កាលពីថ្ងៃទី១០ កក្កដា ឆ្នាំ២០១៣នេះ?

[១០:០១:៤១]

**ឆ៖** តាមខ្ញុំចាំ ការអះអាងជាក់លាក់លើចំណុចនេះតែមួយគត់នោះគឺ អង្គហេតុដែលគេចោទប្រកាន់ ហើយដែលគិតថាវាជាអង្គហេតុការពិត។ នេះគឺជាអង្គហេតុដែលខ្ញុំដឹង។ ហើយចំណុចហ្នឹងមួយទេ ដែលខ្ញុំគិតថាវាចេញមកពីចំណុចហ្នឹង។

**ស៖** លោក ស្ទីវ ហេដឌ័រ នៅក្នុងសវនាការនៅថ្ងៃទី១១ កក្កដា ម៉ោង ១៤:២១វិនាទី លោកនិយាយអំពីព័ត៌មានដែលលោកស្ដាប់បានតាមវ៉ាដ្យូ។ ក្រោយម៉ោង១៤:២១នាទីបន្តិច លោកនិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ម្ដងម្កាល ព័ត៌មានបានផ្សាយអំពីសំឡេងរបស់លោក ខៀវ សំផន ឬក៏អ្នកផ្សេងទៀត ហើយជួនកាលមានអ្នកនិយាយវ៉ាដ្យូហ្នឹងដែលយើងមិនស្គាល់ឈ្មោះ"។ សូមបញ្ចប់ការដកស្រង់។

ដូចដែលលោកបានលើកឡើងថា លោកបានត្រួតពិនិត្យពិច័យលើរបាយការណ៍ ហ្វីប៊ីស។ ខ្ញុំចង់ដឹងថា តើនៅក្នុងរបាយការណ៍ទាំងអស់ហ្នឹង តើមានការបែងចែកថាអំពីពេលខ្លះ ដែលជាសំឡេងរបស់លោក ខៀវ សំផន? ពេលខ្លះជាសំឡេងអ្នកផ្សេងទៀតដែលផ្សាយវិទ្យុហ្នឹង និយាយតាមវ៉ាដ្យូហ្នឹង? តើលោកមានបានពិនិត្យមើលគ្រង់ចំណុចហ្នឹងទេ មានបានវិភាគទេ?

[១០:០៣:២១]

**ឆ៖** បាទ ជាទូទៅ គឺយើងតែងតែបញ្ជាក់ច្បាស់នៅលើដើមទំព័រនៃរបាយការណ៍នោះ។

**ស៖** នៅពេលដែលយើងអានទាំងស្រុងនូវសុន្ទរកថារបស់លោក ខៀវ សំផន តើលោកមានចាំ លោកមានចាំទេថានៅពេលអ្នកផ្សាយវិទ្យុហ្នឹង ពេលខ្លះគាត់ថា យើងនឹងស្ដាប់សុន្ទរកថារបស់លោក ខៀវ សំផន ឬក៏យើងអានសុន្ទរកថារបស់លោក ខៀវ សំផន ហ្នឹង លោកមានដែលធ្លាប់ឮការប្រកាសជាមុនបែបហ្នឹងទេ?

**ឆ៖** ខ្ញុំមិនចាំអំពីករណីដែលថាមានអ្នកមនុស្សណាម្នាក់ គាត់បង្ហាញថាអ្នកនិយាយហ្នឹងជាអ្នកណា អីអ្នកណា ហើយបន្ទាប់មកមានការនិយាយបែបនោះទេ។ ទោះបីថាជាព័ត៌មានដែលថាជាសុន្ទរ-

កថារបស់អ្នកណាម្នាក់ ឧទាហរណ៍ថាជាសុន្ទរកថារបស់ ខៀវ សំផន ជាដើម ឬក៏វាអាចថាមាន ការបន្ថែមរបស់អ្នកត្រួតពិនិត្យខាងហ្វីប៊ីស ដែលគេបញ្ជាក់ថា នេះជារបស់អ្នកណា អីអ្នកណា។ ឧទាហរណ៍ដូចខ្ញុំនិយាយអ៊ីចឹងថា អានដោយអ្នកណា ឬក៏ជាសំឡេងរបស់ ខៀវ សំផន ជាដើម។

ដូច្នេះ ខ្ញុំអាចនិយាយបានថា គេធ្វើការបង្ហាញបែបនេះ គឺពួកគេជាអ្នកធ្វើការសន្និដ្ឋានបែបនេះ ប៉ុន្តែខ្ញុំមិនច្បាស់ថាតើយ៉ាងណានោះទេ ប៉ុន្តែយ៉ាងណាក៏ដោយ វាជាមតិរបស់អ្នកដែលត្រួតពិនិត្យ ឬក៏អ្នកដែលពិនិត្យមើលនៅក្នុងផ្នែក នៅក្នុងវិទ្យុហ្វីប៊ីសនោះ។

[១០:០៥:០៩]

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺ។ ឥឡូវនេះ ខ្ញុំសូមចូលត្រឡប់ទៅនិយាយ -- ចូលទៅនិយាយពីប្រធានបទមួយទៀត នៅសវនាការថ្ងៃទី១១ កក្កដា ២០១៣ ប្រហែលនៅម៉ោង ១០:០៨នាទី នៅពេលដែលលោកឆ្លើយ -- កាលនោះសហព្រះរាជអាជ្ញាសួរ លោកបានឆ្លើយ អំពីការអនុវត្តគោលនយោបាយរបស់បក្ស។ លោកបាននិយាយដូចតទៅនេះ "នៅក្នុងកិច្ចសម្ភាសន៍នោះ បើគេសរសេរអំពីគោលនយោបាយជាផ្លូវការដូចដែលមានរៀបរាប់នៅក្នុងឯកសារ ក៏ប៉ុន្តែនៅក្នុងពេលសម្ភាសនោះ អ្នកខ្លះនិយាយថា គោលនយោបាយផ្លូវការនោះមិនបានដាក់ឲ្យអនុវត្តតាមដែលដូចមានសរសេរនៅលើក្នុងអត្ថបទនោះទេ"។

អ៊ីចឹងខ្ញុំសូមប្រៀបធៀបជាមួយនឹងអត្ថបទរបស់លោកមួយ ដែលសរសេរនិយាយអំពីការវាយតម្លៃឡើងវិញ គឺឯកសារ E190.1.398 ចំណងជើងនោះគឺ "ការវាយតម្លៃឡើងវិញអំពីតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ និងមន្ត្រីថ្នាក់មូលដ្ឋានចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់កម្ពុជាក្នុងទស្សនវិស័យប្រៀបធៀប"។

[១០:០៦:៥៨]

ខ្ញុំមិនដឹងថា លោកមានឯកសារនេះនៅចំពោះមុខលោក ឬក៏អត់ទេ បើលោកអត់មានទេ ឥឡូវខ្ញុំសូមឲ្យលោកមន្ត្រីតុលាការជួយយកឯកសារនេះទៅជូនសាក្សី។

សូមលោកមន្ត្រីតុលាការសូមអញ្ជើញ!

ឥឡូវ -- ខ្ញុំមានសាមីដាក់ឯកសារហ្នឹង ដែលមានឯកសារចំណងជើង ឯកសារ D366/7.1.14 អត្ថបទនេះ មានចំណងជើងថា "ការវាយតម្លៃឡើងវិញ" គឺឯកសារ E190.1.398។ ឯកសារទាំងអស់នេះសុទ្ធតែជាភាសាអង់គ្លេសទេ។ ផ្នែកដែលខ្ញុំចាប់អារម្មណ៍នៅក្នុងអត្ថបទនេះស្ថិតនៅលេខ ERN ជា

ភាសាអង់គ្លេសគឺ 00661462 ដល់ 63, ERN ជាភាសាបារាំងគឺ 00792912, ទំព័របន្ទាប់ ERN 00830768 ទៅដល់ 69។ ទំព័រជាភាសាបារាំងគឺទំព័រ៩ គឺកថាខណ្ឌ១ ដែលលោកនិយាយអំពីប្រជាជនថ្មី។

[១០:០៩:00]

សម្រង់នេះវែងបន្តិច អ៊ីចឹងខ្ញុំសូមនិយាយយឺតៗ ដើម្បីអ្នកបកប្រែ លោកបានលើកឡើងដូចតទៅនេះនៅក្នុងអត្ថបទនុ៎ង។ "ដើម្បីធ្វើឲ្យប្រជាជនថ្មីក្លាយជាផ្នែកស្ថិតថេរមួយនៃប្លុកសាមគ្គីដ៏រឹងមាំតែមួយជាមួយអំណាចរដ្ឋបដិវត្តន៍ កម្មាភិបាលមូលដ្ឋានត្រូវបានណែនាំឲ្យបានប្រកាន់យកទស្សនៈទូលំទូលាយជាមួយនឹងប្រជាជនដែលគេជម្លៀសដោយមានលក្ខណៈបត់បែនទន់ភ្លន់ ហើយនិងមិនតឹងតែងជាមួយនឹងពួកគេ ជាពិសេសមិនត្រូវប្រព្រឹត្តមកលើពួកគេដូចជាឈ្លើយសឹកនោះទេ។ កម្មាភិបាលក៏ត្រូវទប់ស្កាត់ចំពោះភាពមិនអត់ឱនរវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ដោយការរៀបចំចាត់ចែងឲ្យធ្វើការងារជាមួយគ្នានៅក្នុងបរិយាកាសសប្បាយរីករាយ និងសាមគ្គីគ្នា"។

ខ្ញុំសូមជម្រាបជូនលោកថា ខ្ញុំមានសម្រង់ជាច្រើន ហើយនិងសូមត្រឡប់មកនិយាយពីកំណត់សម្គាល់ជើងទំព័រនៃសម្រង់ទាំងអស់នោះ ពេលក្រោយ។

ខ្ញុំសូមបន្តទៀត៖ "កម្មាភិបាលត្រូវដោះស្រាយជីវភាពរបស់ប្រជាជនថ្មីដើម្បីឲ្យពួកគេឃើញថារបបនេះ គឺជាកម្មសិទ្ធិរបស់ពួកគេ ហើយធានាថាប្រជាជនមូលដ្ឋានស្វាគមន៍ និងចែករំលែកដីធ្លី សត្វពាហនៈ និងចំណីអាហារជាមួយនឹងពួកគេ។ ប្រជាជនមូលដ្ឋានមិនត្រូវកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់ប្រជាជនថ្មីឡើយ តែផ្ទុយទៅវិញ ត្រូវជួយដល់ប្រជាជនថ្មីដែលទើបតែមកកាន់ទីជនបទ ដែលមានតែដៃទទេ ដោយបង្ហាញឲ្យឃើញនូវកង្វះការយល់ដឹងទាំងស្រុងរបស់ពួកគេ ចំពោះអ្នកដែលទើបមកថ្មី។

ដូច្នេះ ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ត្រូវតែរស់នៅធ្វើការរៀនសូត្រ មានពេលវេលាសប្បាយ ទទួលបាននូវការរីកចម្រើន និងការស៊ូទ្រាំនឹងភាពអត់ឃ្លានរួមគ្នានៅក្នុងសហករណ៍ប្រមូលផ្តុំ។

[១០:១១:១៧]

កម្មាភិបាលត្រូវបានដាស់តឿនឲ្យអប់រំកែប្រែប្រជាជនថ្មីឲ្យមានប្រសិទ្ធភាព ហើយបក្សត្រូវតែបង្ហាញឲ្យពួកគេឃើញថា បដិវត្តគឺពិតជាកំពុងតែអនុវត្តសេដ្ឋកិច្ចស្មើភាពគ្នាដែលខ្លួនសម្រេចបាន។ គោលនយោបាយទាំងនេះ ត្រូវតែបញ្ជ្រាបដល់រចនាសម្ព័ន្ធបក្សថ្នាក់ក្រោម ដែលការណែនាំថាត្រូវចាត់

ទុកថាប្រជាជនថ្មីទាំងនោះ ជាចំណែកនៃប្រជាជនកម្ពុជា ហើយមិនមែនជាខ្មាំងទាំងអស់។ ហើយដូច្នោះត្រូវតែឲ្យរៀបចំចំណីអាហារ ទឹក ទីកន្លែងស្នាក់នៅ ឲ្យប្រជាជនជម្លៀសទាំងអស់នេះ ដោយមិនសម្លាប់សត្វពាហនៈដើម្បីចិញ្ចឹមពួកគេ”។

អ៊ីចឹងនៅក្នុងសម្រង់នេះ គឺថាមានកំណត់សម្គាល់ជើងទំព័រដែលជាប្រភពរបស់លោក។ ខ្ញុំនឹងសូមឲ្យលោកបញ្ជាក់ថា លោកបានឈរលើមូលដ្ឋាននូវឯកសារជាភាសាខ្មែរ ហើយលោកបានធ្វើការបកប្រែដោយខ្លួនឯង។ អ៊ីចឹង តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺខ្ញុំធ្វើការបកប្រែពីឯកសារដើម ជាភាសាខ្មែរ ហើយដាក់បញ្ចូលនូវការដកស្រង់ដោយធ្វើការបកប្រែពីភាសាខ្មែរ ដែលខ្ញុំមាននៅក្នុងឯកសារដើមរបស់ខ្ញុំ។

[១០:១២:៥៥]

**ស៖** កំណត់សម្គាល់ជើងទំព័រដែលជាមូលដ្ឋាននៃកថាខណ្ឌដែលខ្ញុំទើបតែអានហ្នឹង គឺជាកំណត់សម្គាល់៣១ ទៅដល់៤១។ គោលបំណងគឺចង់ដឹងថា តើលោកតាក់តែងឯកសារហ្នឹងយ៉ាងណាម៉េច? លោកយកមករៀបរាប់យ៉ាងណាម៉េច? ហើយខ្ញុំ នៅពេលដែលខ្ញុំរកពីមូលដ្ឋាននៃកំណត់សម្គាល់ជើងទំព័រនៃឯកសារ E3 ដែលដាក់បញ្ចូលនៅចំពោះមុខតុលាការនេះ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារទៅលោក ស្ទីវ ហេដឌ័រ ដើម្បីចង់ដឹងថាតើគាត់ពិតជាប្រើប្រាស់ឯកសារទាំងអស់នេះ ឬក៏អត់ ដើម្បីសរសេរកថាខណ្ឌនេះ។

ឯកសារទី១ ខ្ញុំយល់ឃើញថា ប្រហែលជាមាននៅក្នុងសំណុំរឿងនោះ គឺឯកសារ E3/216។ នៅក្នុងកំណត់សម្គាល់ជើងទំព័ររបស់លោកៗបានលើកឡើងដូចតទៅនេះ ហើយគឺជាភាសាអង់គ្លេសទេ ខ្ញុំសូមភ័យទោស គឺជាកំណត់សម្គាល់ជើងទំព័រលេខ៣១។

[១០:១៤:៣០]

(អានជាភាសាអង់គ្លេស៖) “កំណត់ហេតុនៃដំណើរទស្សនកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ចន្លោះថ្ងៃទី២០ ដល់២៤ ខែសីហា ឆ្នាំ១៩៧៥”។

**កញ្ញា អង់តា ហ្គីសសេ៖**

ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតដាក់ជូនឯកសារជាភាសាខ្មែរនេះ ទៅលោកសាក្សី ពីព្រោះថាគាត់ធ្លាប់សិក្សាលើឯកសារភាសាខ្មែរនេះ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់បញ្ជាក់ ឲ្យគាត់បញ្ជាក់ថា តើគាត់ពិតជាពិគ្រោះឯកសារនេះ ដើម្បីសរសេរកថាខណ្ឌហ្នឹង ឬក៏យ៉ាងម៉េចទេ? លោកប្រធាន តែប៉ុណ្ណឹងទេ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនសាក្សីពិនិត្យ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឥឡូវខ្ញុំសូមទុកពេលឲ្យលោកពិគ្រោះឯកសារហ្នឹងបន្តិច។ ខ្ញុំសូមជម្រាបជាមុនថា ខ្ញុំគ្រាន់តែចង់បញ្ជាក់ថាតើនេះពិតជាឯកសារដែលលោកបានប្រើប្រាស់ ដើម្បីតាក់តែងកថាខណ្ឌដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ។ តើលោកពិនិត្យមើលហើយឬនៅ ឬក៏លោកត្រូវការពេលវេលាច្រើនជាងហ្នឹង?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ គឺឯកសារតែមួយ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំឃើញថា ឯកសារនេះវាហាក់ដូចជាមិនពេញលេញទាំងស្រុងទេ។ ហើយនៅទំព័រទី៧ គឺមានចំណងជើងថ្មី ហើយមានអត្ថបទបន្ទាប់ ខ្ញុំមិនចាំថាឯកសារដែលខ្ញុំធ្លាប់ធ្វើការ ឬឯកសារដែលខ្ញុំបកប្រែហ្នឹងគឺវាមិនពេញលេញនោះទេ ប៉ុន្តែប្រហែលជាមានឯកសារបន្ថែម ឬក៏មានចំណុចបន្ថែមលើសពីអ្វីដែលខ្ញុំធ្លាប់ពិនិត្យមើលឯកសារចាស់របស់ខ្ញុំនោះ។

[១០:១៧:០៦]

**ស៖** សូមអរគុណ។ សំណួរខ្ញុំដូចតទៅនេះ ទាក់ទងទៅនឹងអ្វីដែលលោកបានឆ្លើយរៀបរាប់នៅក្នុងកថាខណ្ឌហ្នឹង។ យើងយល់ស្របទាំងអស់គ្នាថា ផ្នែកទាំងអស់ហ្នឹងសុទ្ធតែជាការបកប្រែជាភាសាខ្មែរ ដែលជាឯកសារពីចេញពីគណៈអចិន្ត្រៃយ៍នៃរបបកម្ពុជាប្រជាធិបតេយ្យ គឺឯកសារ E3/216។

**ឆ៖** ឯកសារដែលខ្ញុំបានទទួលអាចថាមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏មកពី ដេវីដ ឆេនដ៍ល័រ។

**ស៖** លោកក៏បានលើកឡើងផងដែរ គឺកំណត់សម្គាល់ជើងទំព័រ៣៣ ប៉ុន្តែខ្ញុំមិនចង់បង្ហាញអាហ្នឹងទេ ចង់បង្ហាញ៣២ វិញ។ នៅក្នុងកំណត់សម្គាល់ជើងទំព័រនេះ គឺឯកសារនេះនិយាយអំពីសៀវភៅកំណត់ត្រារបស់កម្ពុជាប្រជាធិបតេយ្យ។ សំណួរខ្ញុំគឺថាតើនេះគឺជាសៀវភៅកំណត់ត្រារបស់កម្មាភិបាល ដែលលោកបានឆ្លើយ អង្កាល់ដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញាកន្លងមកនេះ? អ៊ីចឹងមែនទេ សៀវភៅហ្នឹងមែនទេ?**ឆ៖** បាទ គឺហ្នឹងហើយ។

**ស៖** បន្ទាប់កំណត់សម្គាល់ជើងទំព័របន្ទាប់មកទៀត បន្តបន្ទាប់ទៀតហ្នឹងគឺលេខ៣៣ នេះ។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសម្តងទៀតហើយ។

[១០:១៩:០៦]

(អានជាភាសាអង់គ្លេស) "ឯកសារលេខ៣ ការពិនិត្យទៅលើការយល់ដឹង និងការអនុវត្តមាគ៌ានយោបាយ ស្តីពីការកសាងសេដ្ឋកិច្ចឡើងវិញ និងការកំណត់ការកំណត់កសាងជាតិនៅគ្រប់ផ្នែកទាំងអស់"។

ខ្ញុំត្រឡប់មកនិយាយជាភាសាបារាំងវិញ ចុះថ្ងៃទី១៩ កញ្ញា ឆ្នាំ៩៧៥។ តើលោកនៅចាំឯកសារហ្នឹងដែរឬទេ? តើវាពិត វាជាឯកសារដែលជាឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឲ្យ ឬក៏លោក ដេវីដ ឆេនដ័ល័រ បានផ្តល់ឲ្យ? អ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺដូច្នេះហើយ។

**ស៖** ទាក់ទងនឹងកំណត់សម្គាល់ជើងទំព័រ៣៤។ លើកនេះគឺយើងមានជាភាសាបារាំង គឺថាកំណត់ហេតុនៃដំណើរទស្សនកិច្ចរបស់គណៈកម្មការអចិន្ត្រៃយ៍ គឺយោងនេះ វាដូចនឹងយោង៣១ដែរ ឬក៏ខុសគ្នា?

**ឆ៖** គឺដូចគ្នា។

**ស៖** ឥឡូវនេះ កំណត់ជើងទំព័រលេខ៣៥ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសទៀតហើយ។

[១០:២០:៥៤]

(អានជាភាសាអង់គ្លេស៖) "មហាជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥ គឺជាជ័យជម្នះនៃសាមគ្គីភាព និងការបង្រួបបង្រួមជាមួយប្រជាជនកម្ពុជាយើង រណសិរ្សកម្ពុជា"។

ឥឡូវខ្ញុំសូមបកមកនិយាយជាភាសាបារាំងវិញគឺ សីហា ឆ្នាំ៧៥។ ខ្ញុំមិនឃើញឯកសារនេះនៅក្នុងសំណុំរឿងទេ។ ប៉ុន្តែឯកសារនេះ ខ្ញុំសួរលោកដដែលគឺថាតើឯកសារនេះ គឺលោក ឆេនដ័ល័រ ផ្តល់ជូនលោក ឬក៏មជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំគិតថា ឯកសារនេះគឺជាបណ្តុំឯកសាររបស់បក្សដែលឯកសារនេះមាននៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង អាចជាការយកឯកសារច្បាប់ដើម ឬមួយក៏ជាការថតចម្លងនៅក្នុងឆ្នាំ៨០ ឬក៏៨១ ឬក៏អាចដល់៨៩ ប្រសិនបើខ្ញុំចាំមិនខុសទេ។ ហើយខ្ញុំគិតថាឯកសារតែមួយហ្នឹងក៏ហ្វីលីព ស្សូត ក៏លោកមានដែរ អាចថាជាឯកសារច្បាប់ដើម ឬក៏ឯកសារថតចម្លង។

នៅពេលដែលខ្ញុំពិនិត្យមើលទៅលើឯកសារមួយនេះ ខ្ញុំគិតថាប្រហែលជាឯកសារថតចម្លងទេ។ ព្រោះគេ យើងមើលទៅ យើងអាចដឹងថាវាបាត់ទំព័រ ឬក៏បាត់លេខទំព័រមួយចំនួន។ ដូច្នេះគឺថាដោយសារតែធ្វើការថតចម្លងប្រញាប់ប្រញាប់ពេក។ ហើយម៉ាស៊ីនថតចម្លងសម័យនុំងវាមិនល្អ។ ដូច្នេះវាអាចបាត់ទំព័រ បាត់នូវអក្សរមួយចំនួន។ ដូច្នេះ ខ្ញុំគិតថានេះគឺជាឯកសារថតចម្លង មិនមែនជាឯកសារច្បាប់ដើមនោះទេ។

**សៈ** កំណត់សម្គាល់ជើងទំព័រ៣៦ យើងរកមិនឃើញទេកំណត់សម្គាល់ជើងទំព័រនេះ។ អ៊ីចឹងសំណួរ -- ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសដដែល។

[១០:២៣:១៥]

(អានជាភាសាអង់គ្លេស៖) "អនាគតដ៏ភ្លឺស្វាងនៃសេដ្ឋកិច្ចកម្ពុជាថ្មី រណសិរ្សកម្ពុជា"។ (បញ្ចប់ការអានជាភាសាអង់គ្លេស)

ឥឡូវខ្ញុំត្រឡប់មកនិយាយជាភាសាបារាំងវិញ គឺខែសីហា ឆ្នាំ១៩៧៥។ ហើយនេះប្រភេទឯកសារដែលលោកបានលើកឡើងដដែលហ្នឹងឯង គឺថាឯកសារដែលមាននៅក្នុងសំណុំឯកសារដែលរាយប៉ាយដោយសារ ហើយកាលណោះ ការថតចម្លងក៏មិនសូវមិនល្អដែរ ដោយសារម៉ាស៊ីនថតចម្លងមិនសូវល្អ មិនទាន់ជឿនលឿន។ ឥឡូវខ្ញុំសូមចូលទៅដល់កំណត់ហេតុ -- សម្គាល់ជើងទំព័រលេខ៣៧ ដែលជាឯកសាររបស់លោកដដែល។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសម្តងទៀតហើយ។

(អានជាភាសាអង់គ្លេស) "យុវជនកម្ពុជាត្រូវតែលត់ដំ និងកសាងខ្លួននៅក្នុងចលនាពង្រឹង និងពង្រីកសហករណ៍បង្កបង្កើនផល"។ (បញ្ចប់ការអានជាភាសាអង់គ្លេស)

[១០:២៤:២១]

ទង់បដិវត្តយុវជន យុវនារីបដិវត្ត ទស្សនាវដ្ដី។ អ៊ីចឹងកំណត់សម្គាល់លេខ៣៧ នេះមានលេខកូដ E3 ហើយខ្ញុំសូមបង្ហាញឯកសារចម្លងមួយទៅលោក ស៊ីវ ហេងឆ័រ នេះដើម្បីឲ្យគាត់បង្ហាញបញ្ជាក់ថាពិតជាឯកសារហ្នឹងមែន ឬមិនមែន? សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកស្រីមេធាវី យកជូនសាក្សីពិនិត្យ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមលោកអញ្ជើញពិនិត្យមើល តើលោកពិតជាបានពិគ្រោះឯកសារហ្នឹង ដើម្បីសរសេរកថាខណ្ឌលោកនោះ?

**លោក ស្មីរ ហេដឌ័រ៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**លោក ឃីត រេយ៉ន័រ៖**

សូមអភ័ទោស ខ្ញុំស្នើសុំឯកសារលេខ E3។

**កញ្ញា អង់តា ហ្គីសសេ៖**

ឯកសារ E3/729។ ឥឡូវនេះ ខ្ញុំសូមចូល -- ខ្ញុំអត់លើកកំណត់សម្គាល់៣៨មកទេ ដោយសារខ្ញុំពុំមានឯកសារចម្លង។ ខ្ញុំចូលនិយាយពីកំណត់សម្គាល់៣៩សិន បានខ្ញុំត្រឡប់មក៣៨ក្រោយ។ កំណត់សម្គាល់ជើងទំព័រ៣៩នេះ ប្រហែលជា E3/750 គឺ៧៥០។ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះទៅគាត់ ដើម្បីឲ្យគាត់បញ្ជាក់ថា តើគាត់ពិតជាបានធ្វើការពិគ្រោះឯកសារនេះ ឬក៏អត់ ដើម្បីសរសេរកថាខណ្ឌនេះ? សូម--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សីស្គាល់ឯកសារហ្នឹងទេ?

[១០:២៧:៥៦]

**លោក ស្មីរ ហេដឌ័រ៖**

**ឆ៖** ខ្ញុំគិតថា ដូចជាមានភាពខុសគ្នាតិចតួច ប៉ុន្តែ អ៎! ការពិតគឺជាឯកសារតែមួយទេ។ ប្រសិនបើយើងមើលមាតិកាវិញ គឺខ្ញុំព្យាយាមពិនិត្យមើលតើវាយ៉ាងដូចម្តេចដែរ។

**ស៖** សូមអរគុណដែលបានឆ្លើយបញ្ជាក់។ ឥឡូវកំណត់សម្គាល់ជើងទំព័រលេខ៤០ យើងរកមិនទាន់ឃើញទេ។ ហើយនៅកំណត់សម្គាល់ជើងទំព័រលេខ៤១ លោកបានដកស្រង់ដែរ ហើយលោកបានឆ្លើយទៅសហព្រះរាជអាជ្ញា។ ពាក់ព័ន្ធនឹងកំណត់សម្គាល់លេខ៤១នេះដែរ និយាយពីកិច្ចសម្ភាសន៍របស់លោកជាមួយនឹងជនភៀសខ្លួននៅតាមព្រំប្រទល់កម្ពុជា-ថៃ។ ហើយកំណត់សម្គាល់លេខ៤១នេះ ក៏ជា

ឯកសារដែលលោកប្រើដើម្បីសរសេរកថាខណ្ឌរបស់លោកនេះដែរ អ៊ីចឹងមែនទេ? លោកឆ្លើយបញ្ជាក់ហើយ។

ឥឡូវកំណត់សម្គាល់លេខ៣៨ ដែលខ្ញុំមិនអាចបង្ហាញលោកជាភាសាខ្មែរនេះ។ ខ្ញុំចង់ -- គឺឯកសារ E3/747។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំសូមអនុញ្ញាត ហើយនិងសូមអញ្ជើញលោកមន្ត្រីតុលាការ ខ្ញុំសូមអភ័យទោសដែលប្រើលោកច្រើនព្រឹកនេះ។ សូមអញ្ជើញលោកយកឯកសារនេះទៅជូនលោក ស្ទីវ ហេដឌ័រ ដើម្បីឱ្យគាត់ត្រួតពិនិត្យមើលកំណត់សម្គាល់លេខ៣៨។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:៣០:៥៥]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** តើលោកស្គាល់ឯកសារនេះទេ? ហើយលោកបានប្រើឯកសារហ្នឹងដើម្បីសរសេរអត្ថបទរបស់លោកហ្នឹងដែរឬទេ?

**លោក ស្ទីវ ហេដឌ័រ**

**ឆ៖** ខ្ញុំចង់ដឹងថាតើលោកស្រីនិយាយអំពីជើងទំព័រលេខប៉ុន្មានដែរ?

**ស៖** មិនមែន៤០ទេ ខ្ញុំបានត្រឡប់មកនិយាយពីកំណត់សម្គាល់ជើងទំព័រ៣៨ ដែលអង្កាល់អំមិញខ្ញុំមិនទាន់ឃើញ ឥឡូវរកឃើញហើយ។

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** *(គ្មានការបកប្រែ)*

**ស៖** មិនមែនឯកសារតែមួយទេ?

[១០:៣១:៥៨]

**ឆ៖** គឺថ្ងៃទី០៨ ខែ៨ ឆ្នាំ៧៧ ហើយមានការដកស្រង់នូវលេខពិសេស ចុះថ្ងៃតុលា វិច្ឆិកា ឆ្នាំ៧៥។ ដូច្នេះខ្ញុំគិតថា ឯកសារខុសគ្នា។ ឯកសារដែលខ្ញុំដកស្រង់លេខ៦ នៅក្នុងជើងទំព័រ៤០ តើលោកស្រីមិនអាចរកឃើញ គឺប្រសិនបើនគឺជាឯកសារដូចគ្នានៅក្នុងជើងទំព័រ២៩។

**ស៖** សូមអរគុណដែលបានផ្តល់ព័ត៌មាននេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានឥឡូវខ្ញុំសួរលើប្រធានបទនេះ ខ្ញុំសួរចប់ហើយ នៅសល់តែមួយសំណួរចុងក្រោយទេទាក់ទងទៅនឹងប្រធានបទនេះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ទាក់ទងទៅនឹងបទបញ្ជាដែលលោកបានប្រើប្រាស់ -- លោករកឃើញបទបញ្ជាផ្សេងៗហ្នឹងនៅក្នុងឯកសារផ្សេងៗទៀតឬក៏យ៉ាងម៉េច ដើម្បីសរសេរកថាខណ្ឌរបស់លោកហ្នឹង?

[១០:៣៣:១៦]

**លោក ស៊ឺរ ហេដឌ័រ**

**ឆ៖** បាទ គឺមានឯកសារបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗគ្នាជាច្រើន ឯកសាររបស់វណសិរ្សផងព្រមទាំងឯកសារដែលជាការសម្ភាសរបស់ខ្ញុំផង។ ដូច្នេះគឺថាវាមានប្រភពឯកសារផ្សេងៗគ្នាជាច្រើន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំចូលទៅប្រធានបទផ្សេងទៀត ប៉ុន្តែឥឡូវនេះសូមសម្រាកសិន ឬក៏យ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីនេះទៅរហូតដល់ដប់មួយខ្ទះប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីរូបនេះឈប់សម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងអញ្ជើញគាត់ឲ្យត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្ទះប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៤នាទី ដល់ម៉ោង ១០:៥៨នាទី)*

[១០:៥៨:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

ក្រឡាបញ្ជីសវនាការចុះក្រុមមេធាវីការពារក្តីលោក នួន ជា គាត់អវត្តមាន។ គាត់អញ្ជើញទៅណា? មានដឹងទេ?

បាទសូមអញ្ជើញបាទ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ក្នុងអំឡុងពេលនេះ ខ្ញុំបានរកឃើញកំណត់ត្រាលេខ៣៨ ដែលយើងបាននិយាយអម្បាញ់មិញនេះ គឺលេខកំណត់ជើងទំព័រដែលខ្ញុំឲ្យខុស។ ឥឡូវនេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីឲ្យមន្ត្រីតុលាការយកឯកសារ E3/748 ហើយខ្ញុំនឹងសូមលោក ហេងខ័រ ឲ្យគាត់បញ្ជាក់អំពីឯកសារនេះដែលពាក់ព័ន្ធនឹងកំណត់សម្គាល់ជើងទំព័រលេខ៣៨ នៃឯកសាររបស់គាត់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សំណួរដដែលដូចសំណួរមុនៗលោក ហេងខ័រ តើពិតជាឯកសារហ្នឹងមែនទេ ដែលលោកយកមកសរសេរក្នុងសៀវភៅរបស់លោកនោះ?

**លោក ស្ទីវ ហេងខ័រ៖**

**ឆ៖** បាទ គឺពិតដូច្នេះមែន។

[១១:០០:៣០]

**ស៖** សូមអរគុណ។ ក្នុងក្របខ័ណ្ឌនៃការរៀបចំត្រៀមខ្លួនមកបង្ហាញខ្លួននោះ លោកបានដាក់នូវលោកបានរៀបចំនូវឯកសារមួយចំនួនដែលលោកបានសម្ភាសជាមួយសាក្សី ទាំងនៅក្នុងក្របខ័ណ្ឌឯកសារដែលយើងបានឃើញអម្បាញ់មិញនេះ ពាក់ព័ន្ធទៅនឹងជនភៀសខ្លួននៅព្រំដែនខ្មែរ-ថៃ។ ហើយក៏នឹងមានចម្លើយផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿង។ ដូច្នេះ ខ្ញុំនឹងពិនិត្យមើលជាមួយលោកនៅ

ចម្លើយរបស់ជនភៀសខ្លួនមួយចំនួន។ អ្វីដែលខ្ញុំចង់សួរលោកនោះ គឺពាក់ព័ន្ធទៅនឹងប្រធានបទនៃការទទួលខុសត្រូវនៅថ្នាក់ក្រោមគឺការទទួលខុសត្រូវរបស់កម្មាភិបាលថ្នាក់ក្រោម និងអំពីគោលនយោបាយដែលថាមិនត្រូវបានអនុវត្តនៅថ្នាក់ក្រោម។

[១១:០១:៣១]

ទាំងអស់នេះហើយជាឃ្លាដែលខ្ញុំចាប់អារម្មណ៍ ហើយនិងខ្ញុំលើកឡើងពិនិត្យទាំងអស់គ្នាជាមួយលោក។ ឯកសារទី១ ដែលខ្ញុំចង់លើកឡើងជាមួយលោកនោះ គឺឯកសារលេខ D224.77។ ឯកសារនេះមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។

**កញ្ញា អង់តា ហ្គីសសេះ**

អាស្រ័យហេតុនេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់បញ្ចាំងឯកសារនេះនៅលើអេក្រង់ជាភាសាខ្មែរ ទំព័រ ERN ពាក់ព័ន្ធគឺ ឯកសារនេះសូមឲ្យលេខម្តងទៀតគឺ D224.77។ ឥឡូវនេះខ្ញុំកំពុងតែរកមើលលេខ ERN ជាភាសាអង់គ្លេសគឺ 00352107, ERN ជាភាសាបារាំង 00612235, ERN ជាភាសាខ្មែរ 00657429។

លោក ហេដឌ័រ តើលោកចង់បានឯកសារនេះជាក្រដាសដើម្បីពិនិត្យមើលទេ បើឯកសារក្រដាសនោះ ខ្ញុំមានជាភាសាអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកស្រីមេធាវីយកជូនសាក្សីពិនិត្យ!

[១១:០៣:២៥]

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំនឹងប្រឹងប្រែងផ្តល់ឯកសារជាច្បាប់ដើមដែលយើងអាចរកឃើញជាភាសាដើម។ បើសិនជាកុំឲ្យមានកំហុស។ ឯកសារនេះគឺជាការសម្ភាសន៍របស់ អេស.អូ.អេស ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំពីរពាន់ -- ខែតុលា ឆ្នាំ២០០៥ នៅខេត្តពោធិ៍សាត់ នៅស្រុកបាកាន។

ឯកសារយោងដំបូងដែលខ្ញុំចង់ប្រើនោះ គឺទំព័រដំបូងគ្រប់ភាសាទាំងអស់។ ខ្ញុំសូមអានលេខ ERN ជូនលោកម្តងទៀត ដើម្បីឲ្យលោកតាមទាន់គឺ 00352107, ជាភាសាបារាំងនោះគឺថាបីទំព័រមុនចប់។ ជាភាសាបារាំងគឺថាឃ្លាដែលខ្ញុំចង់លើកឡើងនោះ គឺថាកថាខណ្ឌទី៣៖ "នៅឆ្នាំ១៩៧៦ យើង

ប្រមូលផលបានពីរដងបន្ទាប់ពីដោះស្រាយបញ្ហាទឹកបាន។ ការប្រមូលផលពីរដងនេះ ផ្តល់ឲ្យទិន្នផល៣ហិកតា ក្នុង១តោន -- ៣តោន ក្នុង១ហិកតា។ គេមានចែកជារបបអង្ករ គឺសម្រាប់មនុស្សម្នាក់ៗ ហើយនិងសម្រាប់១ថ្ងៃ។ ការបង្កបង្កើនផលហ្នឹង គឺសម្រាប់ចិញ្ចឹមប្រជាជនប៉ុន្តែមានការបាត់បង់ច្រើន។ មិនមានការបញ្ជាក់អំពីបរិមាណជាក់លាក់នោះទេ។ តំបន់ពាយ័ព្យនោះ គឺថាធ្វើអ្វីតាមតែចិត្តពួកគេ។ ស្រុកជាអ្នកកំណត់របប តាមដោយផ្ទាល់មាត់របបអាហារ។ ប្រសិនបើយើងចែកលើសរបបនោះ គឺកម្មាភិបាលនឹងត្រូវចាប់ខ្លួន។ ម្យ៉ាងវិញទៀត ស្រុកមិនចាប់អ្នកណាម្នាក់ដែលថាចែករបបអង្ករតិចតួចឲ្យប្រជាជននោះទេ។ ការចោទប្រកាន់នេះ គឺថានៅពេលដែលមានពួកនិរតីមកដល់។ គេចោទពួកពាយ័ព្យថាមិនឲ្យប្រជាជនហូបគ្រប់គ្រាន់"។ សូមបញ្ចប់ការដកស្រង់។

សំណួរដំបូងគឺថាលោកចាំអំពីកិច្ចសម្ភាសន៍នេះទេ? ហើយអ្វីដែលខ្ញុំបានអាននេះ គឺថាវាត្រូវគ្នាទៅនឹងខ្លឹមសារនៃការសម្ភាសរបស់លោកដែលប្រព្រឹត្តទៅនៅថ្ងៃនោះដែរឬទេ?

[១១:០៦:២២]

**ឆ៖** បាទ គឺត្រឹមត្រូវ។ នេះគឺជាឧទាហរណ៍មួយ ក្នុងករណីដែលថាខ្ញុំធ្វើការសម្ភាសជាភាសាខ្មែរ ហើយខ្ញុំនិយាយជាភាសាខ្មែរ ហើយខ្ញុំធ្វើការកត់ត្រាដោយផ្ទាល់តែម្តង។ ហើយបន្ទាប់មកមានការធ្វើជាប្រតិចារឹកអំពីកំណត់ត្រារបស់ខ្ញុំ។

**ស៖** សំណួររបស់ខ្ញុំគឺខ្ញុំចង់ដឹងថា នៅពេលនោះ គឺលោកនិយាយភាសាខ្មែរហើយ មែនទេ?

**ឆ៖** បាទ គឺថាការសម្ភាសហ្នឹងគឺយើងប្រើប្រាស់ភាសាខ្មែរទាំងស្រុងតែម្តង។

**ស៖** នៅពេលដែលលោកនិយាយថា បកប្រែហ្នឹងគឺថាជាការបកប្រែផ្ទាល់របស់លោក ដែលលោកសរសេរជាកំណត់ត្រា មែនទេ?

**ឆ៖** បាទ គឺត្រឹមត្រូវហើយ។

**ស៖** ហើយនៅខាងក្រោមនោះ គឺថាលោកសរសេរផ្ទាល់ដៃ ហើយក្រោយមកលោកកែប្រែរបៀបលោកធ្វើការពិនិត្យមើលឡើងវិញ ដើម្បីថាឲ្យអត្ថបទហ្នឹងមានខ្លឹមសារច្បាស់លាស់ ឬក៏លោកកត់ត្រាសួរបណ្តើរកត់បណ្តើរ?

[១១:០៧:៥៤]

**ឆ៖** គឺថាខ្ញុំធ្វើបណ្តើរ សួរបណ្តើរតែម្តង។ ហើយនៅពេលដែលខ្ញុំពិនិត្យមើល ខ្ញុំសរសេរបន្តទៅទៀត ហើយបន្ទាប់មកទៀត ខ្ញុំយកវាដោយប្រើប្រាស់កុំព្យូទ័រ គឺខ្ញុំប្រើប្រាស់កុំព្យូទ័ររបស់ខ្ញុំ។ ដូច្នេះ

ខ្ញុំគិតថា នេះគឺទម្រង់គំរូនៃការវាយកុំព្យូទ័ររបស់ខ្ញុំហើយ វាមិនមែនជាទម្រង់ដែលតុលាការ ដែលកុំព្យូទ័រដែលប្រើប្រាស់នៅតុលាការយើងនេះទេ។

**ស៖** សូមអរគុណ។ សំណួររបស់ខ្ញុំនោះ គឺថាលោកវាយពាក្យមួយពាក្យម្តងតែម្តង នៅសម្ភាសហ្នឹងកត់ វាយមួយពាក្យតាមពាក្យហ្នឹងម្តង ឬលោកមានការកែសម្រួលខ្លឹមសារដើម្បីឲ្យមានន័យល្អគ្រប់គ្រាន់នោះ។ ខ្ញុំចង់ដឹងអ៊ីចឹង ថាលោកកត់តាមពាក្យដែលគេនិយាយមកតែម្តង គឺថាគេនិយាយមក កត់អ៊ីចឹង នៅពេលដែលសម្ភាសហ្នឹង ឬក៏មានការកែសម្រួលនៅពេលក្រោយមកទៀត?

[១១:០៩:០៥]

**ឆ៖** ការកត់ត្រារបស់ខ្ញុំ របៀបក្នុងការកត់ត្រារបស់ខ្ញុំគឺថាខ្ញុំដកចេញនូវពាក្យមិនប្រយោជន៍ ឧទាហរណ៍ដូចជាពាក្យថា មួយ ឬក៏នេះនោះ ឬក៏បែបនេះ បែបនោះជាដើម។ ដូច្នេះគឺថាខ្ញុំមានការបន្ថែមខ្លះទៅលើអ្វីដែលបាននិយាយ គឺថានៅចុងបញ្ចប់ការសរសេររបស់ខ្ញុំ គឺថាខ្ញុំបន្ថែមបន្តិចបន្តួច ប៉ុន្តែជាទូទៅ ខ្ញុំរក្សាទុកនូវន័យដដែល ដោយខ្ញុំមិនមានកែប្រែអ្វីច្រើននោះទេ។ ហើយឥឡូវនេះ យើងអាចពិនិត្យមើល គឺថាវាមានលក្ខណៈដូចដែលខ្ញុំបាននិយាយអ៊ីចឹង វាហាក់ដូចជាអ្វីដែលបានដកស្រង់យកមកនិយាយ គឺថាខ្ញុំបានរៀបរាប់អំពីអ្វីដែលបានកើតឡើង។ វាហាក់ដូចជាអ្វីដែលថាខ្ញុំប្រើប្រាស់ជាលក្ខណៈសិក្សាស្រាវជ្រាវ។

**ស៖** លោកបានឆ្លើយនៅចំណុចនេះរួចមកហើយ នៅពេលដែលលោកឆ្លើយជូនសហព្រះរាជអាជ្ញា ដែលថាលោកដឹងពាក្យហ្នឹងនៅពេលក្រោយ។ ដូច្នេះនៅពេលដែលលោកសួរនុ៎ង គឺថាលោកអត់មានសួរចង់ចម្លើយពិតប្រាកដពីអ្នកដែលសម្ភាសនុ៎ងមែនទេ?

**ឆ៖** ជាទូទៅខ្ញុំមិនដែលដាក់សំណួរចូលទៅក្នុងការកត់ត្រារបស់ខ្ញុំទេ ខ្ញុំដាក់តែសង្ខេបចម្លើយតែប៉ុណ្ណោះ។

[១១:១០:៤៥]

**ស៖** សូមអរគុណ។ ពាក់ព័ន្ធទៅនឹងរបៀបនៃការធ្វើការរបស់លោកនោះ ឥឡូវនេះខ្ញុំនិយាយអំពីខ្លឹមសារនៃឃ្លាដែលខ្ញុំទើបតែលើកឡើងជាមួយលោក។ តើសក្ខីកម្មដែលលោកសម្ភាសទៅថ្ងៃនៅថ្ងៃនោះនុ៎ងវាត្រូវគ្នានឹងអ្វីដែលលោកបានស្តាប់ឮពីមនុស្សផ្សេងទៀត ពីការសម្ភាសផ្សេងទៀត ទាំងក្នុងក្របខ័ណ្ឌនៃការងារស្រាវជ្រាវរបស់លោក ក៏ដូចជាក្នុងក្របខ័ណ្ឌនៃការងាររបស់លោកនៅចំពោះមុខ អ.វ.ត.ក ក្នុងការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺថាធៀបទៅ

នឹងភូមិភាគពាយ័ព្យ និងនិរតី?

**ឆៈ** ចម្លើយគឺថាវាមាននូវព័ត៌មានមួយចំនួន ដែលខ្ញុំធ្លាប់បានឮក្នុងរយៈពេលកន្លង ហើយជាទូទៅគឺវាស្របទៅនឹងអ្វីដែលបានរៀបរាប់នៅទីនេះ។ ហើយក្នុងពេលគ្នានុំងក៏មានព័ត៌មានជាច្រើន ដែលថាវាមិនដូចគ្នានៅគ្រប់ទីកន្លែង គ្រប់ពេលវេលានោះទេ។ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំគិតថា វាមិនមែនជាលក្ខណៈពិសេស ឬក៏ប្លែកអ្វីនោះទេប្រសិនបើខ្ញុំចាំនោះ។ គឺថាកិច្ចសម្ភាសន៍ទាំងអស់ដែលខ្ញុំបានធ្វើ គឺវាមិនមានអ្វីជាលក្ខណៈខុសប្លែកពីអ្វីដែលបានអាននោះទេ។

[១១:១២:២៤]

**សៈ** ឥឡូវនេះខ្ញុំចូលទៅឃ្លានៃកថាខណ្ឌ ដែលខ្ញុំបានលើកឡើងជូនលោក គឺថាកថាខណ្ឌចុងក្រោយជាភាសាបារាំង ហើយជាភាសាអង់គ្លេសនៅដដែល ERN ដដែល ជាភាសាខ្មែរគឺ 00657430។ នេះជាចម្លើយអ្នកដែលលោកបានសម្ភាស "ក្នុងខែមេសា ឆ្នាំ១៩៧៥ របបអាហារគឺមួយកំប៉ុង សម្រាប់មនុស្ស -- សូមទោស គឺមានសេចក្ដីណែនាំថា ពួក១៧ និង១៨មេសា គួរតែហូបចុកដោយស្មើភាពគ្នា។ ការលត់ដំមិនមែនមានន័យថា បង្អត់ពួកគេទេ គឺធ្វើឲ្យពួកគេធ្វើការធ្ងន់ជាងយើង"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។ តើមានន័យថាម៉េចពួក១៧ និង១៨នេះ?

**ឆៈ** លេខ១៧ គឺជាពាក្យកាត់សម្រាប់ ១៧មេសា ១៩៧៥ ចំណែក១៨ គឺជាពាក្យកាត់ ១៨ មីនា ឆ្នាំ១៩៧០។ ដូច្នេះពាក្យទាំងអស់គ្នានេះ គឺលេខ១៨សំដៅលើអ្នកដែលស្ថិតក្រោមការគ្រប់គ្រងរបស់បក្ស ហើយបានទទួលការអប់រំ និងលត់ដំពីបក្សចាប់តាំងពីថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ គឺនៅពេលដែលគេធ្វើរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ។ ចំណែក១៧មេសា គឺសំដៅទៅលើថ្ងៃ១៧ មេសា ៧៥ ដែលប្រជាជនត្រូវបានស្ថិតក្រោមការគ្រប់គ្រងរបស់បក្ស។ អានេះគឺជាអ្វីដែលខ្ញុំប្រើពាក្យថា "អ្នកចាស់ និង ប្រជាជនថ្មី" នោះ។

[១១:១៤:២៦]

**សៈ** ឃ្លាដែលខ្ញុំទើបតែដកស្រង់អម្បាញ់មិញនេះ ខ្ញុំចង់ឲ្យផ្ទៀបទៅនឹងព័ត៌មានដែលជាភស្តុតាងផ្សេងទៀត ដែលលោកទទួលបានពីកិច្ចសម្ភាសន៍ផ្សេងៗ ហើយនិងផ្ទៀបទៅនឹងឯកសារដែលយើងបានលើកឡើងមុននេះនៅក្នុងទស្សនាវដ្ដីយុវជន យុវនារីបដិវត្ត ហើយនិងក្នុងកំណត់សម្គាល់ចុងទំព័រផ្សេងៗ និងការលើដកស្រង់នៅក្នុងអត្ថបទផ្សេងៗដែលលោកបានសរសេរ។ គឺគេថាឲ្យពួក១៧, ១៨ មេសា ហ្នឹងគឺថាហូបស្មើភាពគ្នា។ បុគ្គលម្នាក់នេះ ថាមានសេចក្ដីណែនាំ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើ

គាត់មានប្រាប់លោកថា សេចក្ដីណែនាំហ្នឹងចេញមកពីណាទេ?

**ឆ៖** ខ្ញុំគិតថាប្រហែលជាមាន -- ប្រសិនបើមានការបញ្ជាក់ឲ្យបានច្បាស់ប្រហែលជាខ្ញុំដាក់ចូលទៅក្នុងកំណត់ត្រានេះហើយ។ ដូច្នេះ ខ្ញុំគិតថាប្រហែលជាគេមិនប្រាប់ខ្ញុំថាគេបញ្ជូនមកពីណា។ ដូច្នេះទើបខ្ញុំមិនបានដាក់បញ្ជូន ដាក់បញ្ជាក់អំពីឈ្មោះអ្នកដែលចេញការបញ្ជាបែបនេះ។ ដូច្នេះ គឺខ្ញុំគ្រាន់តែប្រាប់គេថា គេ គឺបានន័យថាអ្នកណាមួយដែលមិនច្បាស់លាស់នោះ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកស្ដាប់ឮចំណុចនេះ តើលោកអាចភ្ជាប់ទំនាក់ទំនងជាមួយនឹងសេចក្ដីណែនាំនេះទៅនឹងសេចក្ដីណែនាំផ្សេងៗដែលលោកបានអាននៅក្នុងឯកសារដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះទេ? ហើយនៅក្នុងក្របខ័ណ្ឌនៃភាពស្របគ្នានេះហើយ ដែលលោកធ្វើៗនៅក្នុងការលោកធ្វើការប្រៀបធៀបបែបនេះហើយនៅក្នុងកិច្ចសម្ភាសន៍របស់លោកនេះ?

[១១:១៦:២៣]

**ឆ៖** ខ្ញុំគិតថាវាមានសំណួរពីរនៅពេលនេះ លោកស្រី។ ទី១ ចង់សួរខ្ញុំថាតើខ្ញុំអាចធៀបជាមួយចម្លើយនេះទៅនឹងចម្លើយដទៃទៀត ឬក៏ការសម្ភាសដទៃទៀត។ ចំណែកទី២ គឺអំពីខ្លឹមសារធៀបទៅនឹងឯកសារបក្ស។ ដោយសារតែទាំងអស់នេះគឺវាកើតឡើងក្រោយពេលដែលខ្ញុំសរសេរ។ ប្រសិនបើយើងពិនិត្យមើលទៅលើការសម្ភាសហ្នឹង គឺថាវាដូចជាមិនពាក់ព័ន្ធគ្នានោះទេ។ ពាក់ព័ន្ធទៅនឹងសំណួរលោកស្រីថាតើៗវាស្របគ្នាទៅនឹងការសម្ភាសដទៃទៀតដែលខ្ញុំបានធ្វើឬក៏អត់នោះ ប្រសិនបើយើងផ្ដោតឲ្យបានលម្អិតទៅលើការសម្ភាសជាមួយនឹងកម្មាភិបាលថ្នាក់ទាប ខ្ញុំអាចនិយាយបានថាវាជាការអះអាងឬក៏ជាចម្លើយទូទៅដូចៗគ្នា ដែលធ្វើឡើងដោយកម្មាភិបាលថ្នាក់ទាប។ ហើយវាជាចម្លើយទូទៅដែលជាទូទៅមន្ត្រី ឬក៏កម្មាភិបាលជាន់ទាបតែងតែនិយាយថាតើគោលនយោបាយគឺជាបែបនេះ ឬក៏បែបនោះជាដើម។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ឥឡូវនេះ ខ្ញុំសូមចូលទៅឯកសារមួយទៀត គឺឯកសារ D224.31។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារច្បាប់ដើមជាភាសាអង់គ្លេសជូនលោកស្ទីវ ហេដឌ័រ។ ខ្ញុំសង្កត់ធ្ងន់ទៅលើទំព័រជាភាសាខ្មែរ 00788310, ចំណុចត្រង់ទំព័រនេះ ខ្ញុំសូមការអនុញ្ញាតផ្ដល់បើកបញ្ចាំងនៅអេក្រង់ដើម្បីឲ្យសាធារណជនមើល ហើយនិងសូមឲ្យលោកមន្ត្រីតុលាការ

ផ្តល់ឯកសារជាភាសាអង់គ្លេសជូនសាក្សី។

ឥឡូវនេះ ខ្ញុំផ្តល់លេខ ERN ជាភាសាបារាំងគឺ 0077401, ជាភាសាអង់គ្លេស 00351976។

[១១:១៨:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកស្រីមេធាវីយកជូនសាក្សីពិនិត្យ!

**កញ្ញា អង់តា ហ្គីសសេ៖**

កថាខណ្ឌដែលខ្ញុំចាប់អារម្មណ៍នោះ គឺជាកថាខណ្ឌទី៣ ជាភាសាបារាំង គឺមុនពេលចប់ មុនកថាខណ្ឌចុងក្រោយ។ នេះគឺជាកិច្ចសម្ភាសន៍ដែលធ្វើឡើងនៅក្នុងភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលធ្វើឡើងនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៥--

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន! លោកស្រីមេធាវី មានបញ្ហាការបកប្រែភាសា គ្មានភាសាអង់គ្លេស។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពបកប្រែភាសា!

សូមអញ្ជើញលោកស្រីចាប់ផ្តើមសាឡើងវិញ ពីព្រោះអំមិញអត់មានភាសាអង់គ្លេសទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អម្បាញ់មិញនេះ ខ្ញុំនិយាយថា សូមអភ័យទោស អម្បាញ់មិញនេះគឺថាខ្ញុំកំពុងតែផ្តល់បរិបទនៃការសម្ភាសនេះ គឺថានៅទំព័រទី១ នៃគ្រប់ភាសាទាំងអស់នោះ យើងឃើញថាកិច្ចសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅឃុំព្រែកថ្មី ភូមិចំពុះក្អែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។ ឥឡូវនេះ ខ្ញុំចូលទៅដល់កថាខណ្ឌដែលខ្ញុំចាប់អារម្មណ៍។ ERN គឺថាខ្ញុំបានផ្តល់ជូនរួចទៅហើយ ជាភាសាបារាំងនោះគឺថាកថាខណ្ឌទី៣ មុននឹងបញ្ចប់។ “បងថ្លៃខ្ញុំ ឈ្មោះ នូ យ៉ាន នៅពេលនោះមានអាយុប្រហែលជាង៥0ឆ្នាំ ត្រូវបានចាប់ខ្លួននៅឃុំឈើទាល ភូមិឫស្សីស្រុក។ គាត់ជាអ្នកធ្វើការតូចតាចនៅសាធារណការ ហើយត្រូវបានប្រជាជនក្នុងភូមិចោទប្រកាន់ថាជាវរសេនាត្រីយ៍។ ការចាប់ខ្លួននេះ ត្រូវបានរាយការណ៍ដោយប្រធានកង ដែលដឹងថាវាមិនពិតទេ តែស្អប់រូបគាត់”។

សំណួរទី១ គឺថាលោកចាំអំពីកិច្ចសម្ភាសន៍នេះទេ?

[១១:២១:៥២]

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** *(គ្មានការបកប្រែ)*

**ស៖** ខ្ញុំស្តាប់ឮថា លោកកំពុងតែធ្វើបទអត្ថាធិប្បាយ។ ខ្ញុំមិនដឹងថាតើលោកកំពុងតែនិយាយអំពីកថាខណ្ឌដែលខ្ញុំអាននេះអម្បាញ់មិញ ឬក៏យ៉ាងណា ព្រោះថាខ្ញុំអត់ឮការបកប្រែជាភាសាបារាំងទេ?

**ឆ៖** សូមអភ័យទោស។

**ស៖** លោកក៏អត់បានឮការបកប្រែខ្ញុំសួរដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំឮសួរភាសាបារាំងនិយាយចេញមករហូតទៅ។ ប៉ុន្តែខ្ញុំស្តាប់មិនសូវជាច្បាប់ទេ ភាសាបារាំង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមិនដឹងតើមានភាសា មានបញ្ហាជាភាសាអង់គ្លេស ឬក៏យ៉ាងម៉េច? តើខាងតុលាការអាចពិនិត្យមើលទេ ថាមានបញ្ហាអីពាក់ព័ន្ធនឹងការបកប្រែ?

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកស្តាប់ខ្ញុំឮទេ? អ៊ីចឹង តើលោកស្តាប់ឮអំពីកថាខណ្ឌដែលខ្ញុំអានជូនលោកអម្បាញ់មិញនេះទេ? លោកឆ្លើយថា ឮ។ សំណួររបស់ខ្ញុំគឺថាបុគ្គលនេះត្រូវបានគេចាប់ខ្លួន។ ដូច្នេះខ្ញុំចង់ដឹងថានៅក្នុងក្របខ័ណ្ឌនៃកិច្ចសម្ភាសន៍របស់លោកនៅកន្លែងផ្សេងៗ តើលោកអាចមានឧទាហរណ៍ផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងមនុស្សដែលត្រូវបានគេចាប់ខ្លួន ដោយសារតែបញ្ហាផ្ទាល់ខ្លួនជាមួយនឹងអាជ្ញាធរមូលដ្ឋាននោះ គឺថាគ្រាន់តែមានបញ្ហាផ្ទាល់ខ្លួន គេចាប់គាត់?

[១០:២៣:៥៩]

**ឆ៖** បាទ ខ្ញុំអាចនិយាយបានថានេះជាបញ្ហាទូទៅមួយ។ គឺគេរាយការណ៍មកជាទូទៅទាក់ទងទៅនឹងបញ្ហានេះ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅឯកសារមួយទៀត ឯកសារ E3/1714 ដែលជាបទសម្ភាសន៍ដ៏ល្បីជាមួយនឹងជនភៀសខ្លួនកម្ពុជា នៅព្រំដែនកម្ពុជាថៃ។ ឯកសារនេះគឺធំណាស់ ច្រើនទំព័រ។ ដូច្នេះខ្ញុំចង់សួរលោកថា តើលោកចង់បានភាសាខ្មែរនៅលើអេក្រង់ ឬក៏លោកចង់បានទំព័រដែលខ្ញុំដកស្រង់នោះ ជាក្រដាស? ខ្ញុំនឹងអានសម្រង់មួយចំនួន ប៉ុន្តែមិនវែងទេ គឺចេញពីឯកសារមួយនេះ។ ដូច្នេះ វាអាស្រ័យទៅលើលោកៗយល់ថាចង់បានយ៉ាងម៉េច? ចង់បានជាក្រដាស ឬក៏មើលតាមកញ្ចក់ទូរទស្សន៍? គឺឯកសារ

នេះ E3/1714។ សក្ខីកម្មដែលខ្ញុំចាប់អារម្មណ៍ គឺលេខ២២ ដែលនៅ ERN ជាភាសាបារាំង 00648997, ជាភាសាខ្មែរ 00324740, ជាភាសាអង់គ្លេស 00170733។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនដឹងថា តើក្នុងការសម្ភាសឈ្មោះសាក្សីនេះ ខ្ញុំត្រូវដាក់ឈ្មោះលើឈ្មោះសាក្សី ឬក៏យ៉ាងណាម៉េច?

សូមលោកប្រធានបំភ្លឺអំពីចំណុចនេះ ខ្ញុំដូចជាភ្លេចអស់ហើយ ថាតើវិធានដែលយើងអនុវត្តនោះយ៉ាងម៉េច។ យើងមានឈ្មោះមនុស្ស ហើយនិងមានមុខងាររបស់គាត់។ ដូច្នេះ ខ្ញុំមិនដឹងថា តើលោកប្រធានអនុញ្ញាតឲ្យបង្ហាញឈ្មោះហ្នឹងនៅលើអេក្រង់ដែរឬទេ?

[១១:២៦:៥៧]

**ប្រធានអង្គជំនុំ៖**

យើងបានណែនាំកន្លងមក គឺបើសិនជាសាក្សីហ្នឹងមាន ជាសាក្សីដែលមាន -- អង្គជំនុំជម្រះបានកំណត់នូវរហស្សនាមរួចហើយ ឲ្យប្រើប្រាស់នូវរហស្សនាម ក្នុងការពិភាក្សាដេញដោលនៅចំពោះមុខអង្គជំនុំជម្រះនេះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** បាទខ្ញុំ -- គឺថាគាត់មិនមែនជាសាក្សីសក្តានុពលនោះទេ ក៏ប៉ុន្តែដើម្បីមានបញ្ហានោះ គឺថាមិនចាំបញ្ចាំងនៅលើអេក្រង់តែម្តងទៅ។ ដូច្នេះ ខ្ញុំគ្រាន់តែសូមបង្ហាញនូវផ្នែកពាក់ព័ន្ធ គឺជាភាសាខ្មែរ និងជាភាសាអង់គ្លេស។ ភាសាខ្មែរគឺ 00324741, ជាភាសាអង់គ្លេសគឺ 00170733។ កថាខណ្ឌនោះ គឺថាកថាខណ្ឌទីចុងក្រោយនៃសក្ខីកម្មលេខ២២ ចុះថ្ងៃ៩ ខែមីនា ឆ្នាំ១៩៨០ ដែលប្រព្រឹត្តទៅនៅស្រះកែវ។ កថាខណ្ឌនោះ មានដូចតទៅ៖ “នៅពេលនោះ គឺថាមានការលម្អៀងជាច្រើន គឺថា--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវីគាត់អានម្តងទៀត លឿនពេក អ្នកបកប្រែតាមដានអត់ទាន់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** --ថ្នាក់លើពុំបានស្វែងយល់សភាពការណ៍ជាក់ស្តែងឡើយ គិតតែអង្គុយក្នុងការិយាល័យអានរបាយការណ៍ ហើយចេះតែជឿ។ រីឯថ្នាក់ក្រោមវិញ ពួកកម្មាភិបាលចេះតែផ្គាប់ចិត្តមជ្ឈិមបក្ស ហើយលាក់បាំងការពិត។ ជាលទ្ធផល គឺមានគម្លាតគ្នាឆ្ងាយ រវាងថ្នាក់លើ និងប្រជាជន។ នៅភូមិភាគ

ពាយ័ព្យ ភ្នាក់ងារវៀតណាមដូចជា រស់ ញឹម បានយកស្រូវអង្ករពីសហករណ៍ទុកសម្រាប់ខ្លួនឯង។ គាត់លាក់ទុកស្រូវអង្ករនៅក្នុងឃ្លាំងដើម្បីប្រើប្រាស់ប្រឆាំងនឹងមជ្ឈិមបក្សទៅថ្ងៃក្រោយ។ ពួកវាបានទុកស្រូវអង្ករពីដៃមជ្ឈិមបក្ស និងប្រជាជន។ ហេតុនេះហើយ ពួកវាជាអ្នកក្បត់ប្រជាជន និងមជ្ឈិមបក្ស"។

[១១:២៩:៤០]

ខ្ញុំសូមបញ្ជាក់ថា កិច្ចសម្ភាសន៍នេះជាប្រភពរបស់លោក ហើយខ្ញុំសូមបញ្ជាក់ថា នេះជាកម្មាភិបាលរបស់បក្សដែលធ្វើការនៅក្រសួងការបរទេស។ តាមរយៈការអានសម្រង់នេះ ខ្ញុំចង់ដឹងថាក្នុងក្របខ័ណ្ឌក្នុងកិច្ចសម្ភាសន៍ផ្សេងៗទៀតរបស់លោក ទាំងក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវដើម្បីសរសេរអត្ថបទរបស់លោក ទាំងក្នុងក្របខ័ណ្ឌនៃការងាររបស់លោកនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត តើលោកធ្លាប់ឮសក្ខីកម្មប្រហាក់ប្រហែល ឬក៏ស្រដៀងគ្នានេះដែលថាថ្នាក់លើគឺថាអត់បាន -- អត់មានព័ត៌មានគ្រប់គ្រាន់ពីថ្នាក់ក្រោមទេ? នេះជាចំណុចទី១។ ឥឡូវខ្ញុំឈប់ត្រឹមហ្នឹងសិន សួរលោកសំណួរទី១ហ្នឹងសិន។

**ឆ៖** បាទ វាជាបញ្ហាទូទៅ គឺជាចម្លើយដែលភាគច្រើនគេនិយមនិយាយបែបនេះ រួមបញ្ចូលទាំងកម្មាភិបាល ក៏ដូចជាករណីខ្លះប្រជាជនសាមញ្ញក៏គាត់និយាយអំពីរឿងរ៉ាវបែបនេះដែរ។

[១១:៣០:៥៨]

**ស៖** សំណួរទី២ កម្មាភិបាលរូបនេះបានលើកឡើងថា រស់ ញឹម នៅភូមិភាគពាយ័ព្យនោះបានយកស្រូវអង្ករ។ តើផ្តើមចេញពីការសម្ភាសរបស់លោកនុ៎ង នៅតាមមូលដ្ឋាន ហើយនិងក្របខ័ណ្ឌនៃការធ្វើការរបស់លោកនៅ អ.វ.ត.ក តើលោកមានរឿងរ៉ាវស្រដៀងគ្នានេះទេ ដែលថាថ្នាក់លើ ថ្នាក់គ្រប់គ្រងនៅថ្នាក់មូលដ្ឋាននោះ គឺថាបានរំលោភលើមុខងាររបស់ខ្លួន ដើម្បីលួច ឬក៏យកស្រូវអង្ករ ឬក៏រំលោភលើអំណាចរបស់ខ្លួនដើម្បីធ្វើកិច្ចការអ្វីមួយនោះ?

**ឆ៖** បាទ គឺថាវាជារឿងរ៉ាវទូទៅ ហើយជារបាយការណ៍ដែលគេបញ្ជាក់ជាទូទៅក្នុងចំណោមកម្មាភិបាលជាន់ទាប ហើយនិងក្នុងចំណោមប្រជាជនជាទូទៅ។ ទាក់ទងទៅនឹងឃ្លាជាក់ស្តែងមួយនេះ ខ្ញុំគិតថា វាហាក់ដូចជាមិនសូវជាទូទៅទេ ដែលគេនិយាយថារឿងរ៉ាវនេះវាកើតឡើងនៅពេលនោះ ដែលគេថា រស់ ញឹម គឺជាភ្នាក់ងាររបស់វៀតណាម។ គេនិយាយបែបនេះ គឺដោយសារតែមានពួកកម្មាភិបាលជាន់ទាបគាត់ព្យាយាមលាក់លៀមស្រូវអង្ករ ឬក៏ការរបស់របរផ្សេងៗ។

**ស៖** នៅក្នុងឯកសារនេះដដែលគឺ E3/1714។ ខ្ញុំចូលទៅសក្ខីកម្មមួយផ្សេងទៀតគឺ ERN ជា

ភាសាបារាំង 00648994, ជាភាសាអង់គ្លេស 00170730, ជាភាសាខ្មែរ 00324735 ហើយបន្តរហូតទៅដល់ 36។

ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារនេះ ព្រោះថាក្នុងនេះអត់មានឈ្មោះមនុស្សដែលត្រូវបានសួរទេ។

[១១:៣៣:៣៧]

នេះគឺជាកិច្ចសម្ភាសន៍លេខ២០ ខែ -- ថ្ងៃទី០៩ ខែមីនា ឆ្នាំ៨១ នៅស្រះកែវ ហើយប្រភពនេះគឺថាបញ្ជាក់ថា គាត់ជាអ្នកបើកនាវាក្នុងការដឹកជញ្ជូនក្នុងផ្លូវជើងទឹក។ គឺឃ្លាដែលខ្ញុំចាប់អារម្មណ៍នោះគឺឃ្លាចុងក្រោយពីរដែលមានដូចតទៅ៖ "ក្រោយពីរំដោះ ប្រព័ន្ធគឺថាមុនពេលរដូវស្ទូងម្តងៗ ភូមិភាគនីមួយៗត្រូវបើកកិច្ចប្រជុំមួយ ដើម្បីសម្រេចថាត្រូវស្ទូងស្រូវប៉ុន្មាន និងត្រូវស្ទូងស្រូវរបៀបណា។ ហើយបន្ទាប់ពីការស្ទូង និងច្រូតរួចកាត់ស្រេចហើយ មានកិច្ចប្រជុំភូមិភាគមួយទៀត ដើម្បីសម្រេចថាតើត្រូវរក្សាទុកស្រូវចំនួនប៉ុន្មានសម្រាប់ប្រជាជន ហើយស្រូវចំនួនប៉ុន្មានត្រូវបញ្ជូនទៅមជ្ឈិម។ ជាទូទៅមជ្ឈិមបក្សមិនបានកំណត់ស្រូវសម្រាប់ភូមិភាគទាំងនោះទេ ប៉ុន្តែភូមិភាគនីមួយៗត្រូវបង្កបង្កើនផលឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

[១១:៣៤:៤៥]

ភូមិភាគទាំងអស់ត្រូវបានគេសន្មតថា អាចផ្តល់ធានាផ្តល់អាហារគ្រប់គ្រាន់ដល់ប្រជាជននៅក្នុងភូមិភាគរបស់ពួកគេ និងត្រូវមានស្រូវអង្ករគ្រប់គ្រាន់ ដើម្បីឧបត្ថម្ភដល់កងទ័ពភូមិភាគរបស់ពួកគេ។ ផលស្រូវដែលនៅសល់ត្រូវផ្តល់ទៅឲ្យអង្គការ ដើម្បីលក់ឲ្យបរទេស។ ប៉ុន្តែដោយសារតែមានជនក្បត់នៅក្នុងភូមិភាគនានា ដែលចង់មានកេរ្តិ៍ឈ្មោះល្អសម្រាប់ពួកគេ ពួកគេក៏បញ្ជូនស្រូវយ៉ាងច្រើនទៅថ្នាក់មជ្ឈិម ហើយទង្វើបែបនេះហើយដែលបណ្តាលឲ្យប្រជាជនជាច្រើនបានស្លាប់នៅក្នុងភូមិភាគទាំងនោះ។ ជនក្បត់ទាំងនោះមិនបានគិតពីរបបអាហាររបស់ប្រជាជនជាមុនតាមដែលពួកគេត្រូវបានតម្រូវឲ្យធ្វើឡើយ។ តែផ្ទុយទៅវិញពួកគេបញ្ជូនស្រូវអង្ករទៅថ្នាក់មជ្ឈិមដើម្បីបានឡើងបុណ្យស័ក្តិ។ បញ្ហាសំខាន់គឺថានៅតាមលំដាប់ថ្នាក់ទាំងអស់មិនមានការស៊ើបអង្កេតឲ្យបានជាក់លាក់គ្រប់គ្រាន់អំពីស្ថានភាពពិតឡើយ។ ពួកគេគ្រប់រូបជឿទៅលើរបាយការណ៍លើក្រដាសរបស់អ្នកផ្សេងទៀត។ ដូច្នេះកម្មាភិបាលក្បត់បានសរសេររបាយការណ៍ក្លែងក្លាយ ហើយបានទុកស្រូវអង្ករទាំងអស់សម្រាប់ពួកខ្លួន ហើយមិនបានចែកជូនប្រជាជនហូបឡើយ"។ សូមបញ្ចប់ការដកស្រង់។

[១១:៣៥:៥០]

ដូចសំណួរមុនដែរ ខ្ញុំចង់សួរលោកថាតើលោកបានធ្លាប់ជួបអ្នកសម្ភាសណាផ្សេងទៀតដែលបាននិយាយរឿងរ៉ាវស្រដៀងគ្នាហ្នឹងទេ តើក្របខ័ណ្ឌការងាររបស់លោកសម្រាប់សហព្រះរាជអាជ្ញា និងសម្រាប់អ្នកចៅក្រមស៊ើបអង្កេតនោះ? តើរឿងរ៉ាវបែបហ្នឹង ជារឿងរ៉ាវធម្មតាដែលកើតមានឡើងជាទូទៅ ឬក៏លោកធ្លាប់តែស្ដាប់ឮនៅតែភូមិភាគហ្នឹងទេ ឬក៏ស្ដាប់ឮចេញពីភូមិភាគផ្សេងៗទៀតដែរ?

**លោក ស្ទីវ ហេឌឌ័រ៖**

**ឆ៖** ខ្ញុំមិនបានឃើញអ្វីទេនៅលើអេក្រង់។ ដូច្នេះ សូមឲ្យខ្ញុំមើលឃើញផង។ តាមអ្វីដែលខ្ញុំឮស្ដាប់និយាយនោះ គឺខ្ញុំសូមនិយាយថា មានកំណត់ហេតុមួយចំនួន កិច្ចសម្ភាសន៍កំណត់ហេតុមួយចំនួនដែលវាស្របទៅនឹងរូបភាពដូចដែលលោកស្រីបានរៀបរាប់។ មិនមានច្រើនទេ ក៏ប៉ុន្តែខ្ញុំនិយាយអំពីថ្នាក់ក្រោមៗនៅក្នុងប្រព័ន្ធ។ ប្រសិនបើយើងសម្ភាសបុគ្គលមួយចំនួនដែលគាត់ធ្លាប់បានដឹងនៅក្នុងតំបន់ នៅមូលដ្ឋាននោះ គឺថាមានន័យដូចដែលខ្ញុំបានបកស្រាយនៅក្នុងកម្រិតថ្នាក់ភូមិភាគអ៊ីចឹង។ ក៏ប៉ុន្តែវាគ្មានអ្វីដែលថាចម្លែកចំពោះការរៀបរាប់ដូច្នេះនោះទេ។ តាមការចងចាំរបស់ខ្ញុំ ការអះអាងនៅក្នុងហ្នឹង គឺបានបង្ហាញថាមជ្ឈិមមិនបានបញ្ជាក់អំពីកូតាក្នុងការទទួលទិន្នផលស្រូវនោះទេ។ ហើយចំណុចហ្នឹងប្រហែលជាចំណុចលក្ខណៈជាក់លាក់ពិសេសមួយតែប៉ុណ្ណោះ។

[១១:៣៧:៤៥]

ឯកសារសម្ភារៈជាក់លាក់ផ្សេងទៀតរួមទាំងនៅក្នុងឯកសាររបស់បក្ស និងកិច្ចសម្ភាសន៍ដែលខ្ញុំបានដឹងនោះគឺថា គេបានរៀបរាប់ដូចដែលខ្ញុំបានលើកឡើង។ ហើយព័ត៌មានហ្នឹង គឺថាខ្ញុំចាំតែបានតែប៉ុណ្ណឹង។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។ ចំពោះការរៀបរាប់ដទៃទៀតនៅក្នុងឯកសារៗរបស់បក្សនោះ គឺខ្ញុំមិនដឹងថាតើគេបានកំណត់កូតា ឬមិនកំណត់នោះទេ។ ក៏ប៉ុន្តែខ្ញុំបានស្ដាប់ឮដូចដែលលោកស្រីបានរៀបរាប់អ៊ីចឹង គឺការរៀបរាប់នៅក្នុងចម្លើយនានានោះ ក៏បានបញ្ជាក់ដូចហ្នឹងផងដែរ។

**ស៖** ខ្ញុំយល់ ក៏ប៉ុន្តែអ្វីដែលលោកអានហ្នឹងគួរតែមានបញ្ចាំងនៅលើអេក្រង់ ដោយអត់មានអ៊ីចឹងខ្ញុំគិតថាប្រហែលជាមានបញ្ហាបច្ចេកទេសហើយ ព្រោះថាសហភាគីរបស់ខ្ញុំនៅជិតនេះមានបញ្ចាំង។

**កញ្ញា អង់តា ហ្គីសសេ៖**

អ៊ីចឹងខ្ញុំសូមឲ្យជួយដោះស្រាយបញ្ហាបច្ចេកទេសនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការពិនិត្យមើល យ៉ាងម៉េចបានជាមានបញ្ហា?

*(មានបញ្ហាបច្ចេកទេស)*

[១១:៣៩:២១]

**ស្តួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ធម្មតានៅក្នុងករណីមានបញ្ហា ខ្ញុំអាចផ្តល់ផ្នែកដែលខ្ញុំចង់ដកស្រង់នោះ គឺថាឯកសារដដែល ជាខ្ញុំអាចផ្តល់ជាក្រដាសជូនបានជាភាសាអស់គ្លេស។ ហើយខ្ញុំមិនត្រូវការពេលវេលាយូរប៉ុន្មានទេ ក្នុងការនិយាយអំពីឯកសារនេះ ដកស្រង់ឯកសារនេះ។ តែឥឡូវនេះ គឺមានជាភាសាខ្មែរហើយឬនៅ? បើថាទោះបីជាមានហើយក៏ដោយ ខ្ញុំឲ្យជាភាសាអង់គ្លេសផងដែរ។ នេះមានតែវគ្គដែលខ្ញុំចង់បង្ហាញនោះព្រោះថាឯកសារទាំងមូលនោះធំណាស់ វែងណាស់។

បើលើឯកសារដដែលនេះគឺថា ឯកសារ E3/1714។ ឥឡូវនេះ ខ្ញុំសូមលើកនិយាយអំពីកិច្ចសម្ភាសន៍លេខ១៣ ខែ៦ -- ថ្ងៃទី០៦ ខែមីនា ឆ្នាំ៨០ លេខ ERN គឺ 00170714, ជាភាសាខ្មែរគឺ 00324706, ជាភាសាបារាំងគឺ 006489--

**អ្នកបកប្រែ៖**

លោកប្រធាន! ខ្ញុំតាមលេខ ERN ជាភាសាបារាំងអំមិញអត់ទាន់។ លោកប្រធាន សូមអភ័យទោស។

[១១:៤១:០១]

**ស្តួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លេខ ERN ឡើងវិញ គឺជាភាសាអង់គ្លេសគឺ 00170714, ជាភាសាខ្មែរគឺ 00324706, ហើយជាភាសាបារាំងគឺ 00648979។ "ជាពិតណាស់ នៅពេលនោះ ប៉ុល ពត ហើយនិងអ្នកផ្សេងៗទៀតនោះត្រូវបានគេ -- របប ប៉ុល ពត នោះប្រជាជនជាច្រើនត្រូវបានគេសម្លាប់ដោយគ្មានមូលហេតុ។ ប៉ុន្តែទង្វើទាំងនេះមិនមែនធ្វើឡើងដោយបុគ្គលផ្ទាល់ដូចជា ប៉ុល ពត ឡើយ។ ទង្វើទាំងនេះធ្វើឡើងដោយលេខាតំបន់ និងលេខាស្រុក។ ឧទាហរណ៍ដូចជាកូនប្រុសមិត្តរបស់ខ្ញុំម្នាក់ជាយុទ្ធជន កូនប្រុសនោះត្រូវបានគេចោទថាជាជនក្បត់ ហើយបន្ទាប់មកនៅពាក់កណ្តាលយប់ លេខាស្រុកក៏ត្រូវបានចាប់ខ្លួនម្តាយនិងឪពុក ហើយពួកគេទាំងអស់បាត់ខ្លួនរហូត។

[១១:៤១:៥៦]

បន្ទាប់មកទៀតលេខាស្រុក និងលេខាតំបន់ទាំងអស់នោះត្រូវបានគេចោទថាជាជនក្បត់ ហើយក៏ត្រូវបានគេចាប់ខ្លួន ហើយប្រហារជីវិត ហើយត្រូវបានគេដាក់ជំនួសដោយអ្នកផ្សេង។ ហើយអ្នកដាក់ជំនួសនោះត្រូវឲ្យកាន់តួនាទីរបស់ពួកគេនោះ ហើយគឺមានរយៈពេលតែពីរបីខែប៉ុណ្ណោះ ហើយក្រោយមកកងទ័ពខ្មែរក្រហមចូលមកដល់"។

សំណួរទី១ ខ្ញុំចង់សួរលោកថា តើរឿងរ៉ាវទាំងអស់នេះដែលគេនិយាយអំពីការចាប់ខ្លួនរបស់លេខាស្រុកតំបន់អីនេះជាដើមនេះ តើលោកមានធ្លាប់ជួបប្រទះនៅក្នុងរឿងរ៉ាវអ្នកដែលលោកសម្ភាសផ្សេងទៀតទេ? អ្នកផ្សេងមានរៀបរាប់ដូចគ្នាទេ ហើយទាក់ទងនឹងការយកអ្នកផ្សេងមកជំនួសលេខាស្រុក លេខាតំបន់ ដែលត្រូវបានគេចោទប្រកាន់ថា បានប្រព្រឹត្តិអាក្រក់ ឬក៏ធ្វើបាបទៅលើប្រជាជននោះ លោកមានបានឮការចាប់ខ្លួនពួកទាំងនេះ ហើយនិងការជំនួសពួកទាំងអស់នេះដោយសារមានការរាយ-ការណ៍ពីថ្នាក់ក្រោម ប្រជាជន ពីប្រជាជន?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** គឺដូច្នោះមែន ហើយវាមានលក្ខណៈការរៀបរាប់នោះគឺថាមានលក្ខណៈច្រើនអំពីបញ្ហានេះ។

[១១:៤៣:៤២]

**ស៖** នៅក្នុងឯកសារដដែល គឺសាក្សីលេខ១៨ ថ្ងៃទី០៨ មីនា ERN ជាភាសាអង់គ្លេសគឺ 00170728, ERN ជាភាសាខ្មែរគឺ 00324732, ERN ជាភាសាបារាំងគឺ 00648993។ ជាភាសាបារាំងគឺនៅកថាខណ្ឌទី២។ ខ្ញុំសូមបញ្ជាក់ផងដែរថា នៅលេខ ERN 00648987 ជាភាសាបារាំង, ERN ជាភាសាអង់គ្លេស 00177323, ជាភាសាខ្មែរគឺ 00324722។ ប្រភពនោះគឺអ្នកមកពីតាកែវមកពីនិរតី ហើយជាកម្មាភិបាលរបស់បក្សផងដែរ។ នេះគ្រាន់តែរៀបរាប់បន្តិចបន្តួចទាក់ទងនឹងសាក្សីនេះ។

ERN ដែលខ្ញុំបានលើកឡើងអម្បាញ់មិញ មុនៗនេះអម្បាញ់មិញនេះ ខ្ញុំចង្អុលបង្ហាញពីផ្នែកដែលខ្ញុំចាប់អារម្មណ៍ដែលខ្ញុំនឹងអាន កថាខណ្ឌទី២ ជាភាសាបារាំង ហើយឃ្លាទី២ផងដែរ។ "នៅនិរតី -- អំពាយ័ព្យ ប្រព័ន្ធនោះធម្មតាទេ សហករណ៍មិនបានបង្កើតឡើងមុន៧៣, ៧៤ទេ ហើយពួកគេភ័យខ្លាចកម្មាភិបាល ដូចជាពួកខ្លាត្រីអ៊ីចឹង។ កាលនោះ ពុំមានភាពស្មើភាពគ្នានោះទេ"។

ហើយពាក្យ "សក្តិភូមិ ឬក៏ស្តេចត្រាញ់" អីនេះ "ខ្លាត្រី" អីនេះ ហើយសួរថាតើកម្មាភិបាល

មូលដ្ឋាននៅពេលនោះគឺគេមានឥរិយាបថគេហ្នឹងដូចពួកស្ដេចត្រាញ់ សក្ដិភូមិស្ដេចត្រាញ់។ តើលោកធ្លាប់មានបានសម្ភាស ឬក៏ធ្លាប់បានជួបប្រទះនឹងឯកសារស្រដៀងៗនេះដែរឬទេ ដែលនិយាយអំពីអាកប្បកិរិយា ឬក៏ដំណើរការនៅតាមមូលដ្ឋាននោះដែលមានអ្នកដែលប្រកាន់អាកប្បកិរិយាដូចស្ដេចត្រាញ់? តាមរយៈការស្រាវជ្រាវរបស់លោក តាមរយៈការងាររបស់លោកនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ហើយនិងការិយាល័យសហចៅក្រមស៊ើបអង្កេតជាដើមនោះ លោកធ្លាប់ជួបប្រទះបញ្ហាហ្នឹងទេ រឿងរ៉ាវទាំងហ្នឹង គេធ្លាប់រៀបរាប់អ៊ីចឹងទេ?

[១១:៤៦:៥៤]

**ឆ៖** មាន ពាក់ព័ន្ធទៅនឹងផ្នែកស្ដីអំពីមនុស្សរស់នៅក្នុងការភ័យខ្លាច អត់ឃើញមានទេ។ ជាពិសេសទៅនឹងការវិភាគជាក់លាក់ទៅលើប្រភពទាំងអស់នោះ ឬក៏តាមការបកស្រាយទៅលើរឿងរ៉ាវទាំងអស់នេះ។ ឥរិយាបថដែលថាមានការភ័យខ្លាចនោះ គឺថាដោយសារតែបញ្ហាសក្ដិភូមិ ហើយវាជាការរៀបរាប់សាមញ្ញទេ ទៅលើបញ្ហាហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយឯកសារមួយទៀត គឺជាឯកសារ E3/198 ដែលជាកំណត់សម្គាល់ ឬក៏ជាសេចក្ដីសង្ខេបសត្យានុម័តដែលលោកបានធ្វើដោយផ្ទាល់ នៅពេលដែលលោកសម្ភាសនៅថ្ងៃទី១៧ សីហា ឆ្នាំ២០០៥។ លោកសម្ភាសលោក ខៀវ សំផន លេខ ERN ដូចតទៅនេះ ជាភាសាបារាំងគឺ 00296212, ជាភាសាអង់គ្លេស 00184680, ជាភាសាខ្មែរគឺ 00078214។ ឯកសារដើមជាភាសាខ្មែរ អ៊ីចឹងខ្ញុំសូមបញ្ចាំងផ្នែកដែលខ្ញុំចង់ឲ្យលោកធ្វើការអត្ថាធិប្បាយ ហើយខ្ញុំចូលទៅនិយាយផ្នែកផ្សេងទៀតនៅពេលក្រោយ។ គឺកថាខណ្ឌចុងក្រោយគេទាំងអស់ ហើយលោកនិយាយពីលោក ខៀវ សំផន លោកនិយាយថា "បើតាមគាត់ នៅក្នុងរបបខ្មែរក្រហម ភូមិភាគនីមួយៗជាពិសេសគឺលេខាភូមិភាគទាំងអស់នោះ គឺសុទ្ធជាស្ដេចត្រាញ់ ដែលបែងចែកការងារតាមភូមិភាគតាមតែចិត្ត មជ្ឈិមមិនបានត្រួតត្រាបានទេ។ ដូច្នេះ ទទួលបានតែរបាយការណ៍។ នៅក្នុងភូមិភាគឧត្តរថ្មី ក្រោយពីចាត់តាំង កង ចាប ទៅកាន់កាប់ មានការចាប់មនុស្សដាក់គុក ដោយខាងលើមិនដឹង។ ហើយរហូតទាល់តែក្នុងឆ្នាំ១៩៧៨ ពេលដែលមជ្ឈិម និង ប-១ បញ្ជូនមនុស្សទីភ្នំពេញទៅរៀបចំទទួលភ្ញៀវទេសចរណ៍ទើបដឹង ហើយមករាយការណ៍"។ សូមបញ្ចប់ការដកស្រង់។

បើតាមមើលទៅ នេះជាកំណត់ត្រារបស់លោក តើលោកចាំកំណត់ត្រានៃកិច្ចសម្ភាសន៍នេះដែរឬទេ? ហើយលោកចាំទេ ថាលោក ខៀវ សំផន អ្វីដែលលោក ខៀវ សំផន និយាយនៅថ្ងៃហ្នឹង ថ្ងៃដែល

លោកសម្ភាសគាត់ហ្នឹង?

[១១:៤៩:៥០]

**ឆ៖** ជាការពិត នៅក្នុងករណីនេះ មិនមានកំណត់ហេតុការបកប្រែ ឬក៏កំណត់ហេតុ ឬក៏ឯកសារទាំងឡាយនោះជារបស់ខ្ញុំនោះទេ។ ដូច្នេះខ្ញុំមិនអាចឆ្លើយតបទៅនឹងសំណួររបស់លោកស្រី ដូចដែលធ្លាប់សួរពីមុនៗមកនោះទេ។

**ស៖** ឥឡូវខ្ញុំសូមចោទសំណួរផ្សេងពីនេះវិញ របៀបផ្សេងពីនេះវិញ។ តើអ្នកណាជាអ្នកសម្ភាស? ហើយមានភាពខុសគ្នាយ៉ាងម៉េចដែរ បើធៀបទៅនឹងរបៀបធ្វើកំណត់ត្រា ហើយនិងការបកប្រែជាដើមនេះ? បើធៀបទៅនឹងការសម្ភាសផ្សេងៗដែលយើងបានលើកឡើងពីកន្លងមកនេះ ខុសគ្នាយ៉ាងម៉េចដែរ?

**ឆ៖** កិច្ចសម្ភាសន៍ទាំងអស់នេះ ការពិភាក្សាទាំងអស់នេះគឺធ្វើឡើងដោយជនជាតិកម្ពុជាម្នាក់ឈ្មោះ ហេង ហាំខេង ហើយបន្ទាប់មកមាន តូច វណ្ណរិទ្ធ នោះអមជាមួយនឹង ហេង ហាំខេង នោះផងដែរពេលសម្ភាស។ កំណត់ហេតុហ្នឹងធ្វើឡើងជាភាសាខ្មែរ យ៉ាងណាក៏ការសម្ភាសនោះគឺវាស្របទៅនឹងគំរូ បែបបទដែលវាធ្វើដូចដែលខ្ញុំធ្វើកំណត់ហេតុអ៊ីចឹង។ អ្វីដែលយើងឃើញជាភាសាអង់គ្លេសនៅលើអេក្រង់នេះ ខ្ញុំយល់ឃើញថា ចំពោះខ្ញុំៗយល់ឃើញវារៀបចំឡើងស្របទៅតាមការបកប្រែក្នុងតុលាការ មិនមែនជាការបកប្រែតាមរបៀបខ្ញុំនោះទេ។ ខ្ញុំគិតថា នេះជាការបកប្រែឲ្យវាស្របទៅតាមក្របខ័ណ្ឌតុលាការ។

**ស៖** តើអ៊ីចឹងអ្វីដែលខ្ញុំត្រូវយល់នោះ គឺថាលោកមិនបានចូលរួមនៅក្នុងឆ្នាំ២០០៥ នេះទេ អ៊ីចឹងមែនទេ? ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៥នេះ?

**ឆ៖** លោកស្រីលើកឡើងនោះគឺត្រឹមត្រូវហើយ។

[១១:៥១:៥៤]

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំមិនសួរលោកច្រើនទៀតទេទាក់ទងនឹងចំណុចហ្នឹង។ ឥឡូវនេះខ្ញុំសូមចូលទៅនិយាយពីឯកសារមួយទៀត គឺឯកសារ 19.71។

**កញ្ញា អង់តា ហ្គីសសេះ**

ហើយជាចៀសវាងកុំឲ្យឈ្មោះ មិនបញ្ចេញឈ្មោះអ្នកដែលគេសម្ភាស ខ្ញុំសូមការអនុញ្ញាតផ្តល់ឯកសារកិច្ចសម្ភាសន៍នេះជាភាសាអង់គ្លេស និងជាភាសាខ្មែរទៅលោកសាក្សី ស្ទីវ ហេដឌ័រ ហើយ

ឯកសារដើមនោះជាភាសាអង់គ្លេស។ លោកប្រធានខ្ញុំសូមអនុញ្ញាតជូនឯកសារនេះទៅលោកសាក្សី។ ទំព័រទី១ ERN ជាភាសាបារាំងគឺ 00614079, ជាអង់គ្លេស 00089756, ជាភាសាខ្មែរគឺ 00602356 គឺជាសាក្សី TCW-325។ លោកប្រធានខ្ញុំសូមអនុញ្ញាត លោកប្រធាន។

[១១:៥៣:៣២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នៅទំព័រទី១ នៅក្នុងឯកសារនេះថាមានឈ្មោះអ្នកដែលគេសម្ភាស សំណួរខ្ញុំមិនចង់បញ្ចេញឈ្មោះហ្នឹងទេ។ តើលោកធ្លាប់បានសម្ភាសជាមួយអ្នកនុ៎ងដែរឬទេ? គឺសម្ភាសនៅថ្ងៃទី២២ កញ្ញា ឆ្នាំ ២០០៥ ហើយកាលណោះសម្ភាសជាភាសាអង់គ្លេស។ ជួនអាចថាកំណត់ត្រាឯកសារដើមហ្នឹងជាភាសាអង់គ្លេស។ តើលោកចាំទេ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ចាំខ្លះ ហើយនិងមិនចាំខ្លះ។ ខ្ញុំធ្វើកិច្ចសម្ភាសន៍ខ្ញុំកត់ត្រាតាមវិធីដែលខ្ញុំ ដូចដែលខ្ញុំបានរៀបរាប់ជាភាសាអង់គ្លេសនោះឯង។ ឯកសារនេះទំនងហាក់ដូចជាប្រតិចារឹក ឬក៏កំណត់ហេតុផ្ទាល់ដៃដែលខ្ញុំក្រោយមកវាយចូលជាប្រព័ន្ធកុំព្យូទ័រ ឬអង្គុលីលេខ។ អត់មានពាក់ព័ន្ធទៅនឹងពេលវេលាទេ ពេលវេលានៅលើនេះ គឺជាពេលវេលាដែលបង្កើតឡើងដោយប្រព័ន្ធ*ដេតា*តែប៉ុណ្ណោះ មិនមែនថ្ងៃសម្ភាសនោះទេ។ កិច្ចសម្ភាសន៍ថ្ងៃជាក់លាក់សម្រាប់កិច្ចសម្ភាសន៍នេះ ថ្ងៃជាក់លាស់សម្រាប់កិច្ចសម្ភាសនោះគឺប្រហែលជានៅក្នុងឆ្នាំ១៩៨០។ កន្លែងសម្ភាសខ្ញុំក៏អាចនៅចាំដែរ នៅខាវអ៊ីដាង តំបន់រដ្ឋបាលជំរំជនភៀសខ្លួនរបស់ខាងឧត្តមស្នងការសិទ្ធិមនុស្សនៅខាងព្រំដែនថៃ។ ខ្ញុំសម្ភាសបុគ្គលរូបហ្នឹងនៅទីតាំងនុ៎ងនៅឆ្នាំហ្នឹង ហើយកត់កំណត់ត្រាជាភាសាអង់គ្លេស ក្រោយមកវាើជាប្រព័ន្ធកុំព្យូទ័របង្កើតជាទិន្នន័យនេះ។ បានន័យថាទិន្នន័យនៅក្នុងនេះ លេខហ្នឹងគឺថាកាលបរិច្ឆេទនេះ គឺកាលបរិច្ឆេទបង្កើតឡើងដោយប្រព័ន្ធកុំព្យូទ័រ មិនមែនកាលបរិច្ឆេទសម្ភាសជាក់លាស់នោះទេ។

[១១:៥៦:០៧]

**ស៖** សូមអរគុណដែលដែលបានឆ្លើយបញ្ជាក់។ ឥឡូវខ្ញុំសូមដកសម្រង់ទី១ នៃកិច្ចសម្ភាសន៍នេះគឺនៅ ERN ជាភាសាបារាំងគឺ 00614086, ជាភាសាខ្មែរ 00602366, ជាភាសាអង់គ្លេសគឺ

00089764។ ខ្ញុំសូមៗអនុញ្ញាតបញ្ចាំងផ្នែកដែលពាក់ព័ន្ធនេះជូនលោកសាក្សី ជាភាសាបារាំងគឺទំព័រទី៣ កថាខណ្ឌទី៣នៃទំព័រនុំង សរសេរដូចតទៅនេះ៖ “នៅពេលដែលធ្វើថ្លែងសុន្ទរកថាក្នុងពិធីបុណ្យថ្ងៃទី១៧ មេសា ខៀវ សំផន មិនដែលបានឡើងអង្គុយលើវេទិកាកិត្តិយសទេ។ មានតែក្នុងឆ្នាំ៧៥ទេ ដែលមានមនុស្សច្រើននៅលើវេទិកា ព្រោះពេលនោះនៅមានរណសិរ្សនៅឡើយ។ ក្រោយឆ្នាំនោះមកគឺ ប៉ុល ពត, នួន ជា និង តាម៉ុក ជាដើម។

ប៉ុល ពត ថ្លែងសុន្ទរកថានៅក្នុងពិធីនោះក្នុងឆ្នាំ៧៦, ៧៨ ពេលដែលខ្ញុំមកចូលរួមដែរ។ ខ្ញុំគិតថាគាត់ថ្លែងសុន្ទរកថាក្នុងពិធីឆ្នាំ៧៧ផងដែរ ទោះបីជាខ្ញុំមិនបានចូលរួមក្នុងពិធីនោះក៏ដោយ។ គាត់នៅតែបន្តជាលេខាបក្សរហូតមក”។

[១១:៥៧:៤៧]

សំណួរ នេះជាសំណួរចុងក្រោយហើយមុនពេលសម្រាកពិសារអាហារថ្ងៃត្រង់។ តើនៅក្នុងក្របខ័ណ្ឌនៃកិច្ច -- នៃការស៊ើបអង្កេត ឬក៏ការស្រាវជ្រាវរបស់លោក ឬក៏ការងាររបស់លោកនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ហើយនិងចៅក្រមស៊ើបអង្កេត តើលោកធ្លាប់បានជួបសក្ខីកម្មផ្សេងទៀតដែលនិយាយពីពិធីប្រារព្ធបុណ្យថ្ងៃ១៧ មេសា នេះទេ? ហើយដែលឃើញថាក្នុងនុំងមានតែ ប៉ុល ពត ទេថ្លែងសុន្ទរកថា ហើយ ខៀវ សំផន មិនដែលថ្លែងសុន្ទរកថាទេ? តើលោកធ្លាប់បានធ្វើជួបប្រទះកិច្ចសម្ភាសន៍ដែលមានខ្លឹមសារប្រហាក់ប្រហែលហ្នឹងដែរឬទេ?

**ឆ៖** ចំពោះចំណុចហ្នឹងគឺថាគ្មាន ឬក៏វាមានតិចតួចពេក ខ្ញុំមិនអាចចាំបាន ហើយខ្ញុំមិនអាចនិយាយថាខ្ញុំមានទិន្នន័យច្រើន ឬក៏កិច្ចសម្ភាសន៍ កំណត់ហេតុកិច្ចសម្ភាសន៍ច្រើនលើបញ្ហានេះនោះទេ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ឥឡូវនេះ តើត្រូវសម្រាកឬយ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។ បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ឬក៏ទីកន្លែងណាមួយសមស្របនៅក្បែរសាលសវនាការនេះដល់សាក្សីក្នុងអំឡុងពេលឈប់សម្រាក និងឲ្យ

អញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញនៅក្នុងបន្ទប់សវនាការនេះនៅរសៀលឲ្យបានមុខម៉ោងមួយ សាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៣:៣៧នាទី)*

[១៣:៣៧:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំងើបឈរទីនេះមិនមែនដើម្បីរំខាន ឬក៏ដើម្បីកាត់នេះទេ ប៉ុន្តែខ្ញុំនិយាយអំពីអ្វីដែលបានកើតឡើងនៅព្រឹកនេះ ហើយខ្ញុំសូមធ្វើការពន្យល់ ហើយខ្ញុំស្នើសុំឲ្យមានការពិចារណាបន្ថែមទៀតទៅលើអ្វីដែលបានកើតឡើងនៅព្រឹកមិញនេះ។

លោកប្រធាន មេធាវីការពារក្តីទាំងពីរក្រុមបាននិយាយយោងទៅដល់ចម្លើយរបស់សាក្សីនៅក្នុងការសួរដេញដោលរបស់ខ្លួន។

ពាក់ព័ន្ធទៅនឹងសាក្សីដែលនឹងមិនមកផ្តល់សក្ខីកម្ម។ ខ្ញុំនិយាយយោងទៅលើចម្លើយរបស់សម្តេច ហេង សំរិន កាលពីម្សិលមិញ។ ហើយនៅព្រឹកមិញនេះគឺចម្លើយរបស់ ខូ វ៉ាន់នី ហើយនិងរបស់ ជួន ប្រសិទ្ធិ ដែលជាចម្លើយរបស់សហចៅក្រមស៊ើបអង្កេត។

[១៣:៣៨:២២]

លោកប្រធាន យើងមិនមានបញ្ហាជាមួយការលើកស្រង់បែបនេះទេ ប៉ុន្តែផលប៉ះពាល់ដែលទទួលបាន ជាពិសេសគឺផលប៉ះពាល់នៃភស្តុតាងគឺមិនទាន់ត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលា

ដំបូងនៅឡើយ។

ហើយសំណើសុំរបស់ខាងសហព្រះរាជអាជ្ញា គឺស្នើសុំឲ្យមានការទទួលហ្នឹង គឺស្របទៅតាមសក្ខីកម្ម គឺស្នើសុំដាក់ចម្លើយជាលាយលក្ខណ៍អក្សរជំនួសឲ្យការផ្ដល់សក្ខីកម្ម។ ហេតុដូច្នេះហើយគឺថា យើងសូមបញ្ជាក់ថានៅពេលដែលសក្ខីកម្មហ្នឹងពាក់ព័ន្ធទៅនឹងអំពី និងសកម្មភាពរបស់ជនជាប់ចោទ គឺមិនអាចទទួលយកធ្វើជាភស្តុតាងបានទេ លុះត្រាតែម្ចាស់សក្ខីកម្មហ្នឹងមកផ្ដល់សក្ខីកម្មដោយផ្ទាល់។ ប៉ុន្តែឥឡូវនេះវាមានរយៈពេលប្រហែល២ថ្ងៃមកហើយ ដែលគេបាននិយាយយោងទៅលើចម្លើយរបស់សាក្សីនៅក្នុងការសួរដេញដោល។

ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ ទោះបីជាក្នុងកាលៈទេសៈដែលសក្ខីកម្មនិយាយទាក់ទងនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទក៏ដោយ។ មេធាវីការពារក្ដីក្នុងពេលឆ្លើយតបទៅនឹងសំណើរបស់ព្រះរាជអាជ្ញាស្នើឲ្យដាក់នូវសក្ខីកម្មជាលាយលក្ខណ៍អក្សរជំនួសឲ្យការមកផ្ដល់សក្ខីកម្មផ្ទាល់ គឺថាវាផ្ដោតសំខាន់លើសពីអំពើ និងអាកប្បកិរិយាបន្តទៅទៀត។ ហើយនិងភស្តុតាងដែលពាក់ព័ន្ធទៅនឹងហេតុការណ៍ ឬក៏បញ្ហាដែលសំខាន់ ក៏ដូចជារចនាសម្ព័ន្ធរបស់អាជ្ញាធរ។

[១៣:៤០:២០]

លោកប្រធាន ការដែលមេធាវីការពារក្ដីលោកយកនូវចម្លើយរបស់សាក្សីទាំងអស់នេះ យកមកគឺហាក់ដូចជាមានន័យថា មេធាវីការពារក្ដីបានដកនូវការជំទាស់របស់ខ្លួនក្នុងការដែលជំទាស់ទៅនឹងការដាក់ចម្លើយរបស់សាក្សីជាលាយលក្ខណ៍អក្សរជំនួសឲ្យការមកផ្ដល់សក្ខីកម្មផ្ទាល់។ ដូច្នេះ អ្វីដែលខ្ញុំចង់លើកឡើងនៅពេលនេះ គឺមានពីរចំណុច។

ទី១ មេធាវីការពារក្ដីត្រូវបញ្ជាក់ជំហររបស់ខ្លួន ហើយប្រសិនបើជំហរមិនច្បាស់លាស់។ ទី២ អង្គជំនុំជម្រះសាលាដំបូងត្រូវកត់សម្គាល់នូវសំណើរបស់ខ្ញុំនៅថ្ងៃនេះ ដោយសារតែអង្គហេតុដែលខ្ញុំលើកមកនេះ គួរតែទទួលបានការពិចារណានៅពេលដែលអង្គជំនុំជម្រះធ្វើការសម្រេចជាចុងក្រោយ ថាតើអង្គជំនុំជម្រះត្រូវទទួលយកចម្លើយជាលាយលក្ខណ៍អក្សរជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ ឬមួយក៏យ៉ាងណា។

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

[១៣:៤១:២៤]

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបំភ្លឺពាក់ព័ន្ធនឹងបញ្ហាច្បាប់សំខាន់ៗ។ ថ្ងៃនេះ តើនៅក្នុងលក្ខខណ្ឌណាខ្លះ ដែលយើងប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរដែលលោកសហព្រះរាជអាជ្ញាបានលើកឡើងថា យើងខ្ញុំកំពុងតែដកចេញវិញនូវសំណើសុំរបស់យើងឲ្យច្រានចោលនូវចម្លើយជាលាយ-លក្ខណ៍អក្សរណាដែលពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។ ជាដំបូងនោះ ខ្ញុំចង់បញ្ជាក់ថា ខ្ញុំចង់បញ្ជាក់អំពីលក្ខណៈពិសេសនៃការសួរដេញដោល។ នៅថ្ងៃនេះ យើងមានសាក្សីដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខយើងដែលមានឋានៈជាសាក្សីអង្គហេតុ។ ពីព្រោះគាត់មិនព្រមបង្ហាញខ្លួនក្នុងឋានៈជាអ្នកជំនាញនោះទេ។ ក៏ប៉ុន្តែទោះជាយ៉ាងក៏ណាដោយ នៅក្នុងក្របខ័ណ្ឌនៃការងាររបស់គាត់ទាំងក្នុងឋានៈជាអ្នកស្រាវជ្រាវ ឬក៏ក្នុងឋានៈជាសមាជិកនៃការិយាល័យសហព្រះរាជអាជ្ញា ឬក៏ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺគាត់ប្រើ គាត់មិនមានជាប់ចម្លើយមួយចំនួន ហើយចម្លើយទាំងអស់នោះ គឺថាប្រើដោយសហព្រះរាជអាជ្ញានៅក្នុងក្របខ័ណ្ឌនៃការសួរសំណួរ។ ពីព្រោះថាគាត់យកមកសួរថា តើយកមកធ្វើជាមូលដ្ឋាន ឬក៏យកមកជាប្រភពនៅក្នុងការសរសេរសៀវភៅរបស់ខ្លួនដែរឬទេ? គាត់សួរទៅកាន់លោក ហេដឌ័រ។

[១៣:៤៣:១៣]

ពីព្រោះថាគេបានយោងខ្លឹមសារនៃសក្ខីកម្មរបស់សាក្សី ឬក៏របស់បុគ្គលទាំងអស់នោះ នៅក្នុងក្របខ័ណ្ឌនៃជើងទំព័រ។ ដូច្នេះ យើងចង់បានព័ត៌មានផ្សេងទៀតដែលលោក ហេដឌ័រ គាត់ធ្លាប់ជួបប្រទះនៅក្នុងឯកសារផ្សេងទៀត ពីព្រោះថាគាត់ធ្វើដូចជាអ្នកជំនាញ។ ឧទាហរណ៍ដូចខ្ញុំបានលើកឡើងអំពីចម្លើយរបស់លោក ជួន ប្រសិទ្ធិ ហើយដែលលោកសាក្សីនេះ ក៏គាត់ទទួលបានដែរចម្លើយនេះ។ ក៏ប៉ុន្តែខ្ញុំមិនមានមូលដ្ឋានរឹងមាំងគ្រប់គ្រាន់ដើម្បីនិយាយជាលក្ខណៈទូទៅអំពីព័ត៌មានផ្សេងទៀតដែលគាត់អាចទទួលបានក្នុងឋានៈគាត់នេះ។

ជាថ្មីម្តងទៀត នេះជាបច្ចេកទេសក្នុងការសួរសំណួររបស់លោក ហេដឌ័រ ក្នុងការសម្ភាសរបស់គាត់ ដែលពាក់ព័ន្ធទៅនឹងលក្ខណៈពិសេសនៃដំណើរខ្សែជីវិតរបស់គាត់ចាប់ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥

ដែលគាត់ជាសាក្សីអង្គហេតុ ហើយក៏គាត់អាចនិយាយអំពីខ្លឹមសារនៃឯកសាររបស់គាត់ ដោយមិនឱ្យគាត់ធ្វើសាក្សី។ ដូច្នេះហើយ យើងប្រើឯកសារនៅក្នុងសំណុំរឿងដែលគាត់បានដឹងឮ ដើម្បីឱ្យគាត់និយាយអំពីអង្គហេតុទូទៅនៅក្នុងក្របខ័ណ្ឌនៃការសម្ភាសរបស់គាត់ជាទូទៅនោះ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន លោក លោកស្រីចៅក្រម ថាកុំឱ្យចាត់ទុកឯកសារដែលខ្ញុំលើកឡើងហ្នឹងថាជាសក្ខីកម្មរបស់លោក ហេងឆ័រ។ អ្វីដែលយើងចាប់អារម្មណ៍នោះ គឺចម្លើយរបស់លោក ហេងឆ័រ ដែលឆ្លើយទៅនឹងសំណួរនៅពេលដែលយើងបង្ហាញឯកសារទាំងអស់នោះ។ ជារួមនៅពេលដែលខ្ញុំសូមសួរលោក ហេងឆ័រ ថាតើលោក ជួន ប្រសិទ្ធិ បាននិយាយថា “មុននាទី -- តួនាទីរបស់លោក ខៀវ សំផន ជាអគ្គមេបញ្ជាការនេះតើលោកធ្លាប់ទេ? គាត់ក៏ឆ្លើយថាបាទ”។ ដូច្នេះខ្ញុំមិនចាប់អារម្មណ៍ទៅលើអ្វីដែលគាត់ចម្លើយនោះទេ គឺខ្ញុំចង់បានចម្លើយសាក្សីរូបនេះនៅក្នុងក្របខ័ណ្ឌការសម្ភាសរបស់គាត់នោះ។

[១៣:៤៥:៣៥]

នេះជាអ្វីដែលខ្ញុំចាប់អារម្មណ៍ អ្វីដែលខ្ញុំមិនមែនចាប់អារម្មណ៍ទៅចម្លើយរបស់សាក្សីដែលបានសម្ភាសជាមួយគាត់នោះទេ គឺខ្ញុំចង់បានពីគឺផលវិបាកដែលកើតឡើងចេញមកពីកិច្ចសម្ភាសន៍ទាំងអស់នោះ។ ដូច្នេះការប្រើប្រាស់ឯកសារ ដែលយើងធ្វើរហូតមកដល់ពេលនេះនោះ គឺដើម្បីតែទទួលបានចម្លើយជាក់លាក់ពីលោក ហេងឆ័រ។ គឺយើងចង់យកចម្លើយរបស់គាត់ទេ មិនមែនចង់បានយកចម្លើយសាក្សីដែលគាត់សម្ភាសនោះទេ។ ដូច្នេះ ព្រោះថាគាត់ៗមានបទពិសោធន៍ជាអ្នកស៊ើបអង្កេត នេះជាចំណុចទី១។

ចំណុចទី២ អង្គជំនុំជម្រះបានសម្រេចរួចទៅហើយ ពីបញ្ហាដែលសហព្រះរាជអាជ្ញាលើកឡើងនេះ ដូច្នេះខ្ញុំមិនចាំបាច់និយាយឡើងវិញនោះទេ។ មិនមែនបានន័យថា ខ្ញុំចូលបង្អួចហើយ ចេញតាម -- ចូលតាមទ្វារចេញតាមបង្អួចអីនោះទេ។

ដូច្នេះខ្ញុំសូមឱ្យអង្គជំនុំជម្រះមេត្តាកត់សម្គាល់ថា ជាមួយលោក ហេងឆ័រ របៀបដែលយើងអាចធ្វើបាននោះ គឺថាយើងនឹងឱ្យគាត់ប្រឈមមុខ តទល់ជាមួយនឹងឯកសារ ជាមួយនឹងព័ត៌មាន គាត់ប្រៀបធៀបព័ត៌មានដែលមាននៅក្នុងសំណុំរឿង ហើយដើម្បីទទួលបានចម្លើយរបស់គាត់ ដើម្បីទទួលសក្ខីកម្មពីគាត់ គឺយើងមិនចង់បានសក្ខីកម្មរបស់បុគ្គលផ្សេងទៀតនោះទេ។ នេះជាចំណុចទី២។

[១៣:៤៦:៥៣]

ចំណុចទី៣ ខ្ញុំគិតថាយើងគួរតែដោះស្រាយបញ្ហានេះនៅថ្ងៃក្រោយ។ ដូច្នេះកាលពីព្រឹកមិញនេះមានការកាត់យកអស់កន្លះម៉ោងហើយ ដូច្នេះខ្ញុំខាតម៉ោងណាស់។ ខ្ញុំមិនចង់និយាយឡើងវិញទៀតទេ យើងគួរតែនិយាយបញ្ហានេះនៅថ្ងៃក្រោយ។ តាំងពីពេលដែលលោក ហេងឌ័រ បានមកផ្ដល់សក្ខីកម្មដំបូងមកម្ល៉េះ ខ្ញុំបានបញ្ជាក់ថាខ្ញុំសូមពេលវេលាបន្ថែម។ ដូច្នេះវាស្រ័យទៅតាមហេតុការណ៍ជាក់ស្ដែង វាអាស្រ័យទៅតាមស្ថានភាពជាក់ស្ដែង។ ដូច្នេះខ្ញុំមិនដឹងថាតើលោកប្រធានអនុញ្ញាត ឬក៏យ៉ាងម៉េចនោះទេចំពោះការស្នើសុំនេះ។

ហើយអម្បាញ់មិញនេះ គឺមានលើកឡើងពីឈ្មោះរបស់ ខូ វ៉ាន់នី។ ដូច្នេះមិនគួរគាត់លើកឡើងឈ្មោះទេ ពីព្រោះថាយើងបាន -- លោកប្រធានបានបញ្ជាក់ពីព្រឹកមិញហើយ ថាឲ្យប្រើរហស្សនាម ក៏ប៉ុន្តែអំមិញសហព្រះរាជអាជ្ញាគាត់លើកឈ្មោះតែម្ដង។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយឈ្មោះនេះគឺមាននៅក្នុងបញ្ជីសាក្សីរបស់យើង។

[១៣:៤៨:០១]

ខ្ញុំសូមបញ្ជាក់ថា យើងមិនចង់យកមកដាក់ជាភស្តុតាងនូវព័ត៌មានដែលយើងបានបង្ហាញជូនសាក្សីនោះទេ គឺយើងគ្រាន់តែប្រើប្រាស់សម្រាប់ជាមធ្យោបាយ ដូចដែលយើបានធ្វើពីមុនៗមកអ៊ីចឹង គឺថាយើងយកមកប្រឈមជាមួយគាត់ យកមកប្រៀបធៀប ឲ្យគាត់ប្រៀបធៀបមើល ហើយដើម្បីឲ្យទទួលបានចម្លើយពីគាត់។ យើងមិនមែនចង់បានចម្លើយ យកតែចម្លើយជាសាក្សីនោះមកដាក់ជាភស្តុតាងទេ គឺចម្លើយរបស់គាត់តែម្ដង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងមេធាវីការពារក្ដីលោក នួន ជា?

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការ។ ក្នុងនាមលោក នួន ជា ខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យកូនក្ដីខ្ញុំលោក នួន ជា សុំសិទ្ធិធ្វើការកត់សម្គាល់នៅពេលនេះមួយយ៉ាងខ្លី អស់រយៈពេលតែ៣នាទីប៉ុណ្ណោះ ស្ដីអំពីកម្មវិធីដែលតុលាការសួរដេញដោលរូបលោក។ បើលោកប្រធានអនុញ្ញាត គាត់បានរៀបចំរួចហើយ។

[១៣:៤៩:០៩]

**ប្រធានអង្គជំនុំ៖**

ហើយចុះបញ្ហានៃការលើកឡើងរបស់ក្រុមតំណាងសហព្រះរាជអាជ្ញា អំពីការលើកយកឯកសារសាក្សី ដែលកំណត់ហេតុស្តាប់សក្ខីកម្មសាក្សីជាលាយលក្ខណ៍អក្សរ ដែលមិនបានកោះហៅមានត្រូវការលើកឡើងសម្គាល់អ្វីដែរឬទេ ទៅលើការលើកឡើងរបស់សហព្រះរាជអាជ្ញា?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមធ្វើការឆ្លើយតបបន្តិចទៅចុះលោកប្រធាន គឺថាយើងកំពុងតែបញ្ចប់នូវពង្រាងចុងក្រោយរបស់ខ្ញុំ ដើម្បីដាក់សំណើទៅលើប្រធានបទរួមមួយនេះ។ គឺប្រធានបទដែលសហព្រះរាជអាជ្ញាបានលើកឡើងហ្នឹង គឺវាត្រូវនឹងអ្វីដែលយើងចង់និយាយ ហើយយើងនឹងដាក់បញ្ចូលអ្វីដែលបានលើកឡើងនេះចូលទៅក្នុងសំណើជាលាយលក្ខណ៍អក្សររបស់យើងខ្ញុំ។ ហើយយើងខ្ញុំនឹងដាក់នៅយ៉ាងយូរត្រឹមថ្ងៃស្អែកនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតផ្តល់ឱកាសជូនលោក នួន ជា ដើម្បីធ្វើការកត់សម្គាល់អំពីការគម្រោងផែនការកាលវិភាគសវនាការក្នុងសួរចម្លើយគាត់ ដែលអង្គជំនុំជម្រះគ្រោងធ្វើនៅពេលខាងមុខនេះ។ សូមអញ្ជើញលោក នួន ជា!

[១៣:៥០:៤៧]

**លោក នួន ជា៖**

សូមគោរពលោក លោកស្រីចៅក្រម។ ខ្ញុំសូមលើកឡើងនូវការជូនដំណឹងខ្លីមួយទៅលោកលោកស្រីចៅក្រម។ ដូចដែលខ្ញុំតែងតែបានលើកឡើងមកហើយថា តុលាការនេះមិនបានគោរពទៅលើគោលការណ៍នៃការកាត់សេចក្តីដ៏ត្រឹមត្រូវ និងយុត្តិធម៌នោះទេ។ ខ្ញុំបានសង្កេតឃើញការប្រព្រឹត្តមកលើជនជាប់ចោទ ក៏ដូចជាក្រុមមេធាវីការពាររបស់ខ្ញុំ វិវត្តន៍ពីអាក្រក់ទៅកាន់តែអាក្រក់ថែមទៀត។ ខ្ញុំក៏អស់ជំនឿនឹងតុលាការនេះ ដូចលោក ខៀវ សំផន ដែរ។ ការប្រព្រឹត្តរបស់តុលាការមកលើខាងយើងខ្ញុំគឺនៅភពម្ខាង ហើយខាងព្រះរាជអាជ្ញាគឺនៅភពម្ខាង។ ជាក់ស្តែងដូចជានៅពេលថ្មីនេះ មេធាវីរបស់ខ្ញុំត្រូវបានកាត់ផ្តាច់មិនឲ្យសួរសំណួរជាសារធាតុ ដើម្បីដោះស្រាយបន្ទុកមកលើរូបខ្ញុំនោះទេ។ នេះជាភាពអយុត្តិធម៌មួយដែលរារាំងមិនឲ្យមេធាវីរបស់ខ្ញុំបំពេញនូវតួនាទីការពារខ្ញុំដោយពេញលេញ។

[១៣:៥២:៣០]

នេះជារឿងក្តីនៃអាយុជីវិតរបស់ខ្ញុំ មិនមែនជាធ្វើលំៗឲ្យតែឆាប់រហ័ស ដើម្បីដាក់ទោសខ្ញុំនោះទេ។ ដោយភាពអស់ជំនឿ និងប្រព្រឹត្តដោយលម្អៀងបែបនេះ ខ្ញុំសូមជូនដំណឹងថា ខ្ញុំមិនឆ្លើយបតទៅនឹងសំណួររបស់ព្រះរាជអាជ្ញា និងភាគីនានានៅក្នុងតុលាការដែលមិនយុត្តិធម៌នេះទេ។ ក្នុងគ្រានេះ ការពិតយុត្តិធម៌ និងមានប្រយោជន៍ត្រូវបានបំផ្លាញដោយតុលាការ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយសង្ខេបជាការឆ្លើយតបទៅនឹងសេចក្តីប្រកាសរបស់លោក នួន ជា ហើយនិងសូមបញ្ជាក់ឡើងវិញនូវសំណើរបស់យើងទាក់ទងទៅនឹងលោក នួន ជា ដោយផ្ទាល់ ដូចដែលយើងបានធ្វើឡើងចំពោះលោក ខៀវ សំផន ផងដែរ។ នៅពេលដែលជនជាប់ចោទ គាត់បានផ្តល់នូវសក្ខីកម្ម ព្រមទាំងចូលរួម ប៉ុន្តែឥឡូវនេះគាត់បែរជាស្នើសុំនៅស្ងៀម។ ដូច្នេះការដែលបដិសេធមិនឆ្លើយតបនូវសំណួរហ្នឹង ក្នុងករណីនេះគួរតែធ្វើឲ្យមាននៅ -- ឲ្យមានការពិចារណាទៅលើភស្តុតាងដោយអង្គជំនុំជម្រះផងដែរ។

[១៣:៥៤:១៤]

ខ្ញុំចង់ជម្រាបដល់អង្គជំនុំជម្រះផងដែរ អំពីបញ្ហានេះ ដោយសារតែឥឡូវនេះយើងកំពុងតែធ្វើសំណើមួយ ប៉ុន្តែប្រហែលជាមិនទាន់ដល់អង្គជំនុំជម្រះនោះទេ។ យើងបានដាក់កាលពីម្សិលមិញពេលរសៀល ដើម្បីធ្វើការឆ្លើយតបទៅនឹងការប្រកាសរបស់លោក ខៀវ សំផន ក្នុងការដកខ្លួនមិនឆ្លើយតបទៅនឹងសំណួរនានា ហើយក្នុងពេលជាមួយគ្នានេះ យើងសូមស្នើសុំដល់លោក លោកស្រីចៅក្រមមេត្តាបញ្ជាក់នៅក្នុងសវនាការជាលាយលក្ខណ៍អក្សរនៅចំពោះមុខវត្តមានរបស់លោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងអង្គហេតុនានា ហើយនិងបង្ហាញអំពីផលលំបាកនានា។

ឥឡូវនេះ យើងនឹងបង្កើនសំណើសុំរបស់យើងជូនទាក់ទងទៅនឹងលោក នួន ជា ផងដែរ។ ទោះបីយ៉ាងណាក៏ដោយ យើងគិតថាអាចថាបន្ទាប់ពីបញ្ចប់លោក ហេងឌ័រ ទៅ យើងអាចនឹងមានស្តាប់សាក្សី ឬក៏មិនមានស្តាប់សាក្សីបន្តទៀត។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយខ្លីទេ ខ្ញុំគ្រាន់តែចង់បញ្ជាក់ជូនអង្គជំនុំជម្រះថា ទោះបីជាខ្ញុំស្រឡាំងកាំងចំពោះការលើកឡើងរបស់ នួន ជា នេះក៏ខ្ញុំមិនភ្ញាក់ផ្អើលដែរ ព្រោះថានេះជាឥរិយាបថរបស់ជនជាប់ចោទទាំងពីរ។ ក៏ប៉ុន្តែខ្ញុំសោកស្ដាយណាស់ការអត្ថាធិប្បាយរបស់ខ្ញុំគឺដូចទៅនឹងអ្វីដែលខ្ញុំបានលើកឡើងពាក់ព័ន្ធនឹងលោក ខៀវ សំផន អ៊ីចឹង។ គ្រាន់តែខ្ញុំចង់បន្ថែមមួយចំណុច។

ខ្ញុំសង្កេតឃើញថាអស់រយៈពេលមកប៉ុន្មានមកនេះ បន្តិចម្ដងៗមេធាវីការពារក្ដី និងជនជាប់ចោទហ្នឹងគិតថាខ្លួនជាជនរងគ្រោះ។ ដូចជាមេធាវីការពារក្ដីអ៊ីចឹង។ គាត់បានតម្រូវឲ្យយើងអនុវត្តវិធានពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ហើយឲ្យយើងសួរក្នុងនាមជាសាក្សី មិនមែនជាអ្នកជំនាញឲ្យយើងបង្ហាញអំពីឯកសារយោង ហើយនៅពេលដែលពេលខ្លួនឯងសួរវិញនោះ គឺខ្លួនលើកឡើងជាសាធារណៈថាគាត់ថាគេរាំងគាត់មិនឲ្យគាត់និយាយ ហើយថាយើងហ្នឹងអត់គោរពគោលការណ៍ចំពោះមុខ។

[១៣:៥៦:៣៤]

ដូច្នេះវាមិនស្មោះត្រង់ទេ វាមិនយុត្តិធម៌ទេ ហើយវាក៏មិនត្រឹមត្រូវដែរ។ ដូច្នេះគួរឲ្យសោកស្ដាយណាស់ដែលពួកគាត់បានប្រកាន់នូវឥរិយាបថបែបនេះនោះ ទោះជាខាងមេធាវីការពារក្ដីក៏ខាង ដូចជាខាងជនជាប់ចោទដែរ គឺប្រកាន់ឥរិយាបថមិនសមរម្យនោះទេ។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ពាក់ព័ន្ធទៅនឹងប្រធានបទនេះ ខ្ញុំគិតថាកូនក្ដីរបស់ខ្ញុំបានបញ្ចេញមតិរួចមកហើយ ហើយមានការជំទាស់ជាលាយលក្ខណ៍អក្សរទៀត ហើយយើងខ្ញុំបានបង្ហាញអំពីគោលជំហររបស់លោក ខៀវ សំផន ហើយ។ ពាក់ព័ន្ធទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការទទួលបានសវនាការដើម្បីជជែកដេញដោលមុនពេលបញ្ចប់នោះ ខ្ញុំសូមជំទាស់ ប្រសិនបើក្នុងក្របខ័ណ្ឌនៃការ -- នៃសេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោលនោះ បើសិនជាគាត់ចង់ធ្វើទៅលើប្រធានបទនោះ គាត់ឆ្លើយ -- គាត់ធ្វើទៅ ហើយយើងនឹង -- ខ្ញុំនឹងឆ្លើយតប។

ហើយបើសិនជាគាត់និយាយបែបនោះ គឺគាត់អាចធ្វើបាននៅពេលដែលគាត់សេចក្ដីថ្លែងចុងក្រោយ។ ខ្ញុំគិតថាមិនចាំបាច់មានសវនាការដាក់ដោយឡែកមួយដើម្បីឲ្យគាត់លើកឡើងនូវសំណើនោះទេ។ គឺថានៅពេលសេចក្ដីសន្និដ្ឋានបញ្ចប់ជាលាយលក្ខណ៍ដោយអី បញ្ចប់ដោយផ្ទាល់មាត់នោះ គាត់ធ្វើ

ទៅ ហើយយើងខ្ញុំក៏ឆ្លើយតបនៅពេលនុ៎ងដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៣:៥៨:១៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអភ័យទោសដែលខ្ញុំត្រូវធ្វើការថ្លែងម្តងហើយម្តងទៀត។ ហេតុផលដែលយើងដាក់សំណើសុំហ្នឹង គឺថាយើងចាំបាច់ត្រូវធ្វើ ហើយចេតនារបស់យើងគឺដើម្បីធានាថាមិនមានតវ៉ាដោយមេធាវីការពារក្តី។ នៅពេលដែលមានការប្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះមិនបានលើកអំពីហេតុផលសំខាន់ៗ ឬក៏អង្គហេតុសំខាន់ៗដែលមិនមានការឆ្លើយតបនេះ។

ដូច្នេះហើយយើងធ្វើឲ្យបញ្ហាហ្នឹងវាមានភាពច្បាស់លាស់ ហើយនិងដើម្បីឲ្យមេធាវីការពារក្តីគាត់ដឹងច្បាស់ថាយើងបានធ្វើសំណើរួចទៅហើយ ហើយអង្គជំនុំជម្រះបានធ្វើការសម្រេចរួចទៅហើយមុនពេលដែលយើងបញ្ចប់សវនាការជំនុំជម្រះ។ ដូច្នេះយើងធ្វើសំណើនេះដើម្បីធានាថា យើងផ្តល់ឱកាសទៅដល់ជនជាប់ចោទ ប៉ុន្តែក៏ជាដើម្បីប្រយោជន៍របស់ជនរងគ្រោះផងដែរ។

ដូច្នេះវាជាការសំខាន់ចំពោះជនជាប់ចោទ ដើម្បីស្តាប់នូវសារណាបញ្ចប់ការពិភាក្សាដេញដោលនេះ។ ហេតុដូច្នេះហើយទើបយើងស្នើសុំដល់អង្គជំនុំជម្រះឲ្យធ្វើការពិចារណាសម្រេចទៅលើបញ្ហានេះ។ សូមអរគុណលោកប្រធាន។

[១៣:៥៩:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៦:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់លើការកត់សម្គាល់របស់លោកតំណាងសហព្រះរាជអាជ្ញាដែលបានលើកឡើង ហើយនិងបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធជាមួយនឹងកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានកត់សម្គាល់នូវការសង្កេតខាងព្រះរាជអាជ្ញាទាក់ទងទៅនឹងការនិយាយយោងរបស់ភាគីនានា ដែលលើកឡើងទាក់ទងទៅនឹងចម្លើយរបស់សាក្សី។ នៅពេលដែលសាក្សីមិនត្រូវបានកោះមកបង្ហាញខ្លួន ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយយើងក៏បានកត់សម្គាល់ផងដែរ ថាយើងនឹងដោះស្រាយជាមួយបញ្ហានេះ នៅក្នុងករណីជាក់ស្តែងនៅក្នុងសាលក្រមរបស់យើង។

ក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា ខ្លួនចង់បានពេលវេលាបន្ថែមទៀត ដើម្បីធ្វើការសួរដេញដោលទៅលើសាក្សីនេះ ហើយយើងនឹងធ្វើការសម្រេចនៅមុនពេលយើងផ្អាកសវនាការនៅថ្ងៃនេះ។ បន្ទាប់ពីយើងបានសម្រេចថាតើវាមានភាពពាក់ព័ន្ធ ឬវាមានភាពជាន់គ្នាច្រំដដែលៗ។

សូមអរគុណលោកប្រធាន ប្រហែលជាខ្ញុំបាននិយាយនូវអ្វីដែលយើងបានពិភាក្សាគ្នារួចហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។

[១៤:០៨:២៣]

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស្ទីវ ហេដឌ័រ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក ហេដឌ័រ ជម្រាបសួរជាថ្មីម្តងទៀត ខ្ញុំនិយាយនូវអ្វីដែលយើងបានឈប់សម្រាកអម្បាញ់មិញនេះ គឺឯកសារលេខ 19.71។ ខ្ញុំចង់លើកឡើងនូវឃ្លាផ្សេងទៀតនៃឯកសារនេះ។ លោកមានហើយឯកសារមួយនេះ ឯកសារជាភាសាខ្មែរ អ៎! អង់គ្លេស ដែលខ្ញុំចាប់អារម្មណ៍នោះ គឺ 0089 768, ជាភាសាខ្មែរគឺ 00602370។ ខ្ញុំសូមបង្ហាញទំព័រនេះនៅលើអេក្រង់ ជាភាសាបារាំង 00614 089។ ជាភាសាបារាំងគឺកថាខណ្ឌទី៣នៃទំព័រនោះ។

ខ្ញុំសូមបញ្ជាក់ជូនលោក ហេដឌ័រ ថាការដកស្រង់នេះគឺវែងណាស់ ខ្ញុំចង់អានមួយកថាខណ្ឌពេញតែម្តង។ ដូច្នេះ ខ្ញុំកាត់ជាបីផ្នែកដើម្បីសួរជាបន្តបន្ទាប់។

ផ្នែកទី១ "ជាសង្ខេបបញ្ញវន្តដែលធ្វើការនៅទីក្រុងភ្នំពេញ មិនដឹងអំពីទំហំនៃភាពអត់ឃ្លាន ព្រមទាំងការកាប់សម្លាប់នៅតាមជនបទនោះទេ។ ក្នុងឆ្នាំ១៩៧៦ នៅពេលដែលយើងហូបបបរនៅទីក្រុងភ្នំពេញ យើងគិតថាប្រហែលជាមានការខ្វះខាតនៅតាមជនបទ។ ប៉ុន្តែនៅឆ្នាំ១៩៧៧, ៧៨ យើងគិតថាអ្វីៗបានប្រសើរឡើងវិញហើយនៅជនបទ ព្រោះនៅភ្នំពេញយើងបានប្រសើរឡើងវិញ។ យើងគិតដូច្នេះពីព្រោះវិទ្យុក៏បានផ្សាយ ផ្សព្វផ្សាយដូច្នេះដែរ។ លើសពីនេះទៀតក៏មានការនិយាយដូចគ្នានេះក៏មានការនិយាយដូចគ្នានេះ នៅក្នុងអត្ថបទអមដោយរូបភាពដែលចុះផ្សាយនៅក្នុងទស្សនាវដ្ដីទៀតផង"។ សូមបញ្ចប់ការដកស្រង់ផ្នែកដំបូង។

[១៤:១០:៥២]

ដូច្នេះ ខ្ញុំចង់ដឹងថា ក្នុងក្របខ័ណ្ឌនៃការងាររបស់លោក និងក្នុងឋានៈជាអ្នកស្រាវជ្រាវ និងអ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេត និងការិយាល័យសហព្រះរាជអាជ្ញា តើលោកធ្លាប់ពិភាក្សា ឬក៏អានឯកសារដែលពាក់ព័ន្ធទៅនឹងបញ្ញវន្តដែលធ្វើការនៅទីក្រុងភ្នំពេញ ហើយដែលគាត់មិនដឹងអំពីរឿងរ៉ាវដែលកើតឡើងនៅតាមទីជនបទនោះទេ? តើនេះគឺជាព័ត៌មានដែលលោកបានដឹងនៅក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់លោកដែរឬទេ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** និយាយពាក់ព័ន្ធទៅនឹងកថាខណ្ឌមួយនេះ គឺពីអ្វីដែលបាននិយាយនៅក្នុងចំណុចទាំងអស់នេះគឺយើងនិយាយអំពីបញ្ញវន្តដែលមិនមែនជាសមាជិកបក្ស គឺបញ្ញវន្តដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ ហើយមានករណីមួយចំនួន មនុស្សទាំងអស់នេះបាននិយាយនូវរឿងរ៉ាវប្រហាក់ប្រហែលគ្នាប្រាប់ខ្ញុំ។ ប៉ុន្តែក៏មានព័ត៌មានផ្ទុយពីនេះផងដែរ ដែលគេធ្លាប់ប្រាប់ខ្ញុំ។ គឺថាក្រុមមនុស្សដែលជាប្រភេទបញ្ញវន្តដែលនៅទីក្រុងភ្នំពេញហ្នឹង គឺនិយាយថាពួកគាត់ដឹងអំពីស្ថានភាពច្បាស់ជាងនៅទីជនបទ។ ហើយខ្ញុំផ្អែកទៅលើចំណុចនេះ ខ្ញុំចាំទៅលើអ្វីដែលគេបាននិយាយ។ ប៉ុន្តែវាមានករណីខ្លះដែរ ដែលមនុស្សមួយចំនួនស្ថិតនៅក្នុងប្រភេទបញ្ញវន្តហ្នឹង គឺគាត់ធ្លាប់បានទៅជួប ឬក៏ធ្លាប់បានទៅឃើញនៅទីជនបទ។ ហើយនៅពេលដែលគាត់ដឹងអំពីព័ត៌មានទាំងអស់នេះ គាត់បានបង្ហាញនូវព័ត៌មានទាំងអស់នេះក្នុងលក្ខណៈផ្សេងពីនេះដើម្បីប្រាប់មកខ្ញុំ។ ដូច្នេះអ្វីដែលខ្ញុំចង់បញ្ជាក់ គឺថាមានអ្នកខ្លះគាត់ផ្ដល់ព័ត៌មានដូចដែលនៅក្នុងអត្ថបទនេះបានសរសេរដូច្នេះដែរ។

[១៤:១៣:០៦]

**ស៖** ខ្ញុំបន្តអានទៅទៀត ដើម្បីឲ្យយើងសិក្សាឲ្យបានស៊ីជម្រៅពាក់ព័ន្ធទៅនឹងបញ្ហានេះ គឺនៅទំព័រដដែល កថាខណ្ឌដដែល។ "ដូច្នេះហើយទើបយើងគិតថា អ្វីៗបានប្រសើរឡើងវិញហើយ តែចំពោះបញ្ហានេះវាពិបាកនិយាយសម្រាប់បក្ខជន។ ពួកគេធ្វើដំណើរទៅជនបទ ហើយរាយការណ៍ពេលដែលពួកគេត្រឡប់មកវិញ។ តែខ្ញុំមិនដឹងថា គេសរសេរអ្វីនៅក្នុងរបាយការណ៍នោះទេ ខ្ញុំមិនដឹងថាគេបានឃើញស្ថានការណ៍ ឬក៏អត់នោះទេ ហើយក៏មិនដឹងថាគេរាយការណ៍ប្រាប់ថ្នាក់លើ ឬអត់នោះដែរ។ មានកត្តាបង្ហាញមួយ នៅពេលដែលមេដឹកនាំកំពូលបក្សចុះទៅតាមជនបទ កម្មាភិបាលសហករណ៍នៅតាមជនបទបានបិទបាំងការពិត។ ពួកគេបានបង្ហាញអាហារនៅពេញតុ ហើយបានដេញប្រជាជនដែលឈឺ ឬក៏ស្គមស្គាំងឲ្យចេញទៅឆ្ងាយ"។ សូមបញ្ចប់ចំណុចទី២។

គឺថាគោលដៅរបស់ខ្ញុំ គឺដូចដដែលទេ គឺថាតើលោកធ្លាប់ទទួលបានព័ត៌មាននៅក្នុងក្របខ័ណ្ឌនៃការងាររបស់លោកនោះ គឺថាព័ត៌មានដែលពាក់ព័ន្ធទៅអង្គហេតុបែបនេះ ឬក៏ក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវរបស់លោក ក្នុងការសរសេរសៀវភៅរបស់លោក? ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកធ្លាប់ឮ ឬក៏ធ្លាប់ទទួលបានព័ត៌មាន ឬក៏ធ្លាប់ទទួលបានឯកសារដែលមានបង្ហាញថា គឺថានៅតាមសហករណ៍មូលដ្ឋាននៅតាមជនបទមួយចំនួននោះ គឺថាមានការលាក់បាំងការពិតទៅថ្នាក់ គឺលាក់បាំងស្ថានការណ៍ជាក់ស្ដែងនៅពេលដែលថ្នាក់លើចុះមកទស្សនកិច្ចនោះ?

[១៤:១៤:៤៨]

**ឆ៖** មានព័ត៌មានជាច្រើន មានសាក្សីជាច្រើនដែលគាត់បានប្រាប់ខ្ញុំអំពីការបិទបាំង ហើយជាពិសេសនៅពេលដែលមេដឹកនាំមកពីមជ្ឈិមបក្សហ្នឹងគាត់ចុះទៅតាមមូលដ្ឋានទាំងអស់នោះ។ ជាឧទាហរណ៍ ដូចកាលពីម្សិលមិញ ខ្ញុំជិះឡានជាមួយមនុស្សម្នាក់ យើងបានពិភាក្សាអំពីបញ្ហាដូចគ្នាហ្នឹង គាត់ធ្លាប់នៅសហករណ៍នៅតាមជនបទ ហើយនៅពេលដែលមានមេដឹកនាំមកទស្សនកិច្ចនៅមូលដ្ឋានហ្នឹង គឺគេបានធ្វើរៀបចំបិទបាំងទាំងអស់នេះ។ ហើយព័ត៌មានទាំងអស់ហ្នឹង គឺវាមានភាពខុសគ្នាខ្លះដែរ។ ចំពោះមនុស្សដែលគាត់និយាយប្រាប់ខ្ញុំ គាត់មានមូលដ្ឋាន ឬគាត់មានប្រភពខុសៗគ្នា។ អ្នកខ្លះគាត់ធ្វើទៅបានជោគជ័យ អ្នកខ្លះដែលបិទបាំងជោគជ័យធ្វើឲ្យមេដឹកនាំហ្នឹង គាត់ជឿទៅលើអ្វីដែលគេបិទបាំងហ្នឹង ប៉ុន្តែអ្នកខ្លះធ្វើទៅអត់បានជោគជ័យទេ។ ដូច្នេះ ជាទូទៅគេតែងតែធ្វើការបិទបាំងហ្នឹង ទោះបីថាមេដឹកនាំជឿ ឬមិនជឿក៏វាជាបញ្ហាទូទៅដែលគេនាំគ្នាធ្វើការបិទបាំងបែបនេះ។

[១៤:១៦:១៣]

**ស៖** ដើម្បីឲ្យបានពេញលេញនេះ ខ្ញុំសូមអានបន្តទៅទៀត គឺកថាខណ្ឌទី៣ សាក្សីរូបនោះ គាត់បានបន្តទៅទៀត៖ "ប៉ុន្តែអ្នកមិនអាចនិយាយថា ថ្នាក់លើមិនដឹងអ្វីទាំងអស់នោះទេ ព្រោះថានៅក្នុងឯកសារបក្សមានណែនាំអំពីការតម្រង់ទិសទៅលើការអនុវត្ត។ ជាឧទាហរណ៍ ឯកសារបានចង្អុលបង្ហាញថា នៅតាមកន្លែងខ្លះកម្មាភិបាលមិនបានរៀបចំសម្ភារៈគ្រប់គ្រាន់សម្រាប់កងចល័តទេ។ ដូច្នេះនៅពេលកងចល័តមកដល់ ពួកគេមិនមានកន្លែងស្នាក់នៅទេ។ ឯកសារទាំងអស់នោះ ក៏បានបញ្ជាក់ផងដែរថា នៅកន្លែងខ្លះប្រជាជនមិនមានពេលសម្រាកគ្រប់គ្រាន់ ហើយបានណែនាំថា មិនគួរឲ្យប្រជាជនធ្វើការពេលក្តៅ ឬពេលថ្ងៃក្រៅ ឬនៅពេលយប់នោះឡើយ"។ សូមបញ្ចប់ការដកស្រង់។

ពាក់ព័ន្ធទៅនឹងសម្រង់ទី៣នេះ ខ្ញុំមានសំណួរដូចតទៅ: តើក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវ ឬក៏នៅក្នុងក្របខ័ណ្ឌនៃការសម្ភាសរបស់លោក ដើម្បីធ្វើការស្រាវជ្រាវរកអង្គហេតុនៅក្នុងការងាររបស់លោកជាមួយការិយាល័យសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត តើលោកមានធ្លាប់ទទួលបានព័ត៌មានដែលអាចឲ្យបញ្ជាក់បានថា មានព័ត៌មានដែលបង្ហាញថា មានសេចក្តីណែនាំឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយានៅថ្នាក់មូលដ្ឋានដែលមិនសមរម្យ? តើលោកធ្លាប់មានជួបអ៊ីចឹងទេ? ធ្លាប់ជួបឯកសារណាដែលបង្ហាញថា ឲ្យមានការណែនាំផ្លាស់ប្តូរអាកប្បកិរិយាមិនសមរម្យរបស់ថ្នាក់ដឹកនាំនៅតាមមូលដ្ឋាននោះ?

[១៤:១៧:៥២]

**ឆ៖** បាទទាំងមុន ទាំងក្នុងអំឡុងពេលហ្នឹង ទាំងក្រោយពេលខ្ញុំធ្វើការនៅជាមួយតុលាការនេះ។ គឺមានទាំងក្នុងឯកសារផ្លូវការទាំងពីរ ដែលធ្វើឡើងដោយថ្នាក់មជ្ឈិម និងដំណើររឿងដែលប្រជាជនដែលខ្ញុំសម្ភាសហ្នឹងបានរៀបរាប់ប្រាប់ខ្ញុំ។ គឺទាក់ទងទាំងបញ្ហានៃណែនាំ ក៏ដូចបញ្ហានៃការទទួលភ្ញៀវនោះដែរ។

**ស៖** សូមអរគុណ។ ឥឡូវសួរចប់នឹងឯកសារហ្នឹងហើយ។ ឥឡូវខ្ញុំសូមចូលមកនិយាយពីឯកសារដែលលោកបានពិគ្រោះនៅពេលដែលលោកធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយនិងការិយាល័យសហព្រះរាជអាជ្ញា។ សំណួរទី១នេះ គឺថាប្រហែលជាសំណួរឆោតល្ងង់ហើយ ក៏ប៉ុន្តែដោយយោងទៅលើមូលដ្ឋានរបស់ខ្ញុំ តើក្រៅពីការងារជាបឋមរបស់លោកលើរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំចង់ដឹងថាតើការចេះនិយាយខ្មែររបស់លោកនេះ កាលដែលលោកចេះនិយាយខ្មែរនេះវាជាគុណសម្បត្តិមួយសម្រាប់លោកនៅចំពោះការងារនៅ អ.វ.ត.ក យើងនេះ តុលាការខ្មែរក្រហមអ៊ីចឹងមែនទេ? គេ

រើសយក -- គេជ្រើសរើសយកដោយសារមូលហ្នឹង?

[១៤:១៩:៥៤]

**ឆ៖** សូមទោស ខ្ញុំដូចជាស្តាប់សំណួរលោកស្រីមិនយល់ ឬក៏វាមានបញ្ហាដោយប្រការណាមួយបកប្រែយ៉ាងម៉េច។

**ស៖** មិនអីទេ ខ្ញុំនិយាយឡើងវិញឲ្យយឺតជាងហ្នឹង។ តើការដែលលោកនិយាយខ្មែរនេះ វាជាលក្ខខណ្ឌសំខាន់ដើម្បីរើសយកលោកយកមកធ្វើការនៅ អ.វ.ត.ក នេះ ថាក្រៅពីការដែលលោកធ្លាប់បានធ្វើការលើរបបកម្ពុជាប្រជាធិបតេយ្យពីមុនៗមកនោះ?

**ឆ៖** ខ្ញុំគិតថាដូច្នេះដែរ។ ពិតណាស់ថា គឺថាអ្នកដែលធ្វើសេចក្តីសម្រេចថ្នាក់ខ្ពស់ហ្នឹង គឺថាបានដឹងអំពីប្រវត្តិរូបរបស់ខ្ញុំហើយ។

**ស៖** លោកបានស្តាប់សាក្សីមួយចំនួននៅក្នុងក្របខ័ណ្ឌនៃសំណុំរឿងយើងនេះ តើនៅពេលដែលចោទសំណួរទៅសាក្សីទាំងអស់នោះ តើលោកចោទសំណួរទៅគាត់ហ្នឹងជាភាសាខ្មែរដោយផ្ទាល់តែម្តង ឬក៏លោកមានអ្នកបកប្រែ បកប្រែឲ្យលោកក្នុងករណីដែលលោកត្រូវការ?

**ឆ៖** ទោះបីជាធ្វើការជាភាសាខ្មែរក្តីក៏តែងតែមានអ្នកស៊ើបអង្កេតជនជាតិខ្មែរទៅជាមួយដែរ។ គឺខ្ញុំធ្វើការនេះផ្តួចផ្តើមឡើងដោយខ្លួនខ្ញុំ ហើយក៏មានអ្នកស៊ើបអង្កេតពីជនជាតិខ្មែរយើងហ្នឹងអមដំណើរទៅជាមួយដែរ។

[១៤:២១:៥៧]

**ស៖** នៅក្នុងមុខងាររបស់លោកនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏ការិយាល័យសហព្រះរាជអាជ្ញា តើលោកអាចពិគ្រោះឯកសារទាំងអស់នៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតរបស់លោក ឬក៏ការកិច្ចសម្ភាសន៍ ឬក៏កិច្ចការស្រាវជ្រាវដែលលោកត្រូវធ្វើក្នុងការងារលោកនៅតុលាការយើងនេះដែរឬទេ?

**ឆ៖** ខ្ញុំគិតថាយ៉ាងដូច្នេះដែរ។ បើខ្ញុំចាំមិនច្រឡំទេ ការកំណត់ប្រភេទនេះគឺថាសម្ងាត់បំផុត គឺថាមិនបានផ្តល់ជាលក្ខណៈទូទៅឲ្យដឹងជាលក្ខណៈទូទៅទេ។

**ស៖** ចំណុចជាក់លាក់មួយ គឺថាទាក់ទងនឹងឯកសារសម្ងាត់នេះ ខ្ញុំមិនចាប់អារម្មណ៍ប៉ុន្មានទេ ប៉ុន្តែទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយដែលមាននៅគណៈអចិន្ត្រៃយ៍ ដែលធ្វើដោយគណៈអចិន្ត្រៃយ៍ហ្នឹង តើលោកធ្លាប់បានអាន ឬក៏ពិគ្រោះនៅពេលណាមួយដែរឬទេ? កំណត់ហេតុប្រជុំរបស់គណៈ

អចិន្ត្រៃយ៍ លោកសាក្សី?

[១៤:២៣:១៥]

**ឆ៖** សរុបទៅគឺថាវាជា -- ខ្ញុំអាចនិយាយបែបនេះបាន ដើម្បីវាមានសុវត្ថិភាពត្រឹមត្រូវ។ គឺថាឯកសារភស្តុតាងទាំងអស់គឺៗឯកសារភស្តុតាងគឺខ្ញុំយកចិត្តទុកដាក់ ប៉ុន្តែឯកសារពាក់ព័ន្ធទៅនឹងនីតិវិធីខ្ញុំមិនសូវយកចិត្តទុកដាក់ទេ។

**ស៖** ឥឡូវខ្ញុំសូមលើកយកឯកសារមួយចំនួនដែលខ្ញុំមិនដឹងថាលោកស្គាល់ ព្រោះ ពីព្រោះថាលោកបានដកស្រង់នៅក្នុងកំណត់សម្គាល់ជើងទំព័រនៃអត្ថបទរបស់លោក គឺឯកសារ E3/3169, ERN ជាភាសាបារាំងគឺ 00722073, ERN ជាភាសាខ្មែរគឺ 00711381, ERN ជាភាសាបារាំងគឺ 00722073។ លោកបានដាក់កាលបរិច្ឆេទ ហើយខ្ញុំចាប់អារម្មណ៍នៅទំព័រ នៅកំណត់សម្គាល់ជើងទំព័រលេខ៣៣ ដែលជាប្រភពដែលលោកបានលើកឡើង គឺកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ពីចន្លោះឆ្នាំ៧៥ និង៧៦ លោកនិយាយថា កំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលរៀបចំឡើងកាលពីថ្ងៃ២ វិច្ឆិកា ឆ្នាំ១៩៧៥, ថ្ងៃទី២២ កុម្ភៈ ឆ្នាំ១៩៧៦, ថ្ងៃទី១១ មីនា ឆ្នាំ១៩៧៦, ថ្ងៃទី១៧ ឧសភា ឆ្នាំ១៩៧៦, និងថ្ងៃទី៣០ ឧសភា ឆ្នាំ១៩៧៦។ ក្នុងកំណត់ហេតុនេះមានបង្ហាញអំពីវត្តមានរបស់ ខៀវ សំផន ផងដែរ ហើយលោក ដេវីដ ឆេនឌ័ល័រ អ្នកផ្តល់ឯកសារនេះ។

ខ្ញុំសូមជូនឯកសារកំណត់ហេតុប្រជុំទាំងអស់នេះជូនលោក ហើយខ្ញុំសូមឲ្យលោកបញ្ជាក់ថា តើពិតជាឯកសារកំណត់ហេតុសម្រាប់ប្រជុំហ្នឹងមែន ឬក៏អត់? ដែលលោកបានរៀបរាប់ក្នុងជើងទំព័រនេះ។ ហើយនិងខ្ញុំចោទសំណួរលោកទៀត ទាក់ទងទៅនឹងការស៊ើបអង្កេតរបស់លោក។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន! ដូច្នេះ ខ្ញុំសូមអនុញ្ញាតជូនឯកសារនេះទៅសាក្សី គឺឯកសារ E3/229 ដែលជាកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី២២ កុម្ភៈ ឆ្នាំ១៩៧៦ ដែលលោកសាក្សីនេះ គាត់បានប្រើធ្វើជាកំណត់ហេតុជើងទំព័រ។ អ៊ីចឹងសូមឲ្យមន្ត្រីតុលាការជួយយកឯកសារនេះ ទៅជូនលោក ស្ទីវ ហេដឌ័រ។ សូមអនុញ្ញាតលោកប្រធាន។

[១៤:២៦:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ទំព័រដែលខ្ញុំចាប់អារម្មណ៍គឺទំព័រទី១ នៅក្នុងគ្រប់ភាសាទាំងអស់ជាភាសាបារាំង គឺ 00334958, ជាភាសាខ្មែរគឺ 00000713, ជាភាសាអង់គ្លេសគឺ 00182625។ មុននឹងចោទសំណួរលើខ្លឹមសារជាក់លាក់ហ្នឹង ខ្ញុំចង់សួរលោកថា តើលោកបានអានឯកសារហ្នឹងហើយឬនៅ? តើឯកសារហ្នឹងជាឯកសារដែលលោកបានប្រើដើម្បីធ្វើជាកំណត់សម្គាល់ជើងទំព័រ គឺកំណត់សម្គាល់ជើងទំព័រនៃលេខ៣៣ នេះដែលស្ថិតនៅក្នុងឯកសារ E3/3169។

[១៤:២៨:១០]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** នេះគឺជាឯកសារមួយក្នុងចំណោមបណ្ដាឯកសារជាច្រើន។ ចំណារនេះជាចំណារដោយដៃរបស់ ដេវីដ ឆេនដ៍ល័រ មិនមែនជាចំណារដែលជាអក្សរខ្ញុំទេ។

**ស៖** ជាភាសាបារាំង ខ្ញុំអត់មានចំណារទេ អ៊ីចឹងខ្ញុំមិនចោទសំណួរលោកទាក់ទងនឹងចំណារនេះទេ។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយផ្នែករបៀបវារៈគឺបញ្ហាការពារប្រទេស។ ឧទាហរណ៍ចំណុចទី១ ដែលមានចំណងជើងថា របាយការណ៍អំពីស្ថានភាពខាងការពារប្រទេស។ លេខ១ ស្ថានភាពនៅព្រំដែនខាងកើត។

ខ្ញុំសូមអានកថាខណ្ឌទី១ "សមមិត្ត ខៀវ រាយការណ៍ថា ចាប់តាំងពីខែ២មក វៀតណាមបានធ្វើសភាពការណ៍យ៉ាងខ្លាំងនៅព្រំប្រទល់យើងខាងកើត ជាពិសេសគឺថារតនគិរី ស្វាយរៀង និងក្អមសំណ។ វាចូលមកនៅក្នុងទឹកដីយើង ប្រហែលជាចូល២០០ម៉ែត្រ ឬក៏៣គីឡូម៉ែត្រពីព្រំប្រទល់។ នៅកន្លែងខ្លះនោះ វាលួចបង្ខិតបង្គោលព្រំដែន។ យើងដេញវា១ទៅវិញ។ កន្លែងខ្លះវាមកបោះនៅក្នុងបន្ទាយចាស់របស់ លន់ នល់ មានកម្លាំងពីប្រហែលជាមួយអនុសេនាតូច ឬក៏ទៅមួយអនុសេនាធំ។ វាថាមជ្ឈិមឱ្យវាមក"។ សូមបញ្ចប់ការដកស្រង់។

[១៤:៣០:១០]

សំណួរខ្ញុំគឺ -- ប្រហែលជាទុកពេលឱ្យលោកអានឯកសារហ្នឹងឱ្យចប់សិន។ សំណួររបស់ខ្ញុំចង់ដឹងថា នៅក្នុងក្របខ័ណ្ឌស៊ើបអង្កេត ហើយនិងការស្រាវជ្រាវរបស់លោក ទោះជាក្នុងឋានៈលោកជាអ្នកស្រាវជ្រាវ ឬក៏ក្នុងឋានៈលោកអ្នកស៊ើបអង្កេត នៅការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏ការិយាល័យសហព្រះរាជអាជ្ញា តើលោកមានព័ត៌មាន ឬឯកសារ ឬចម្លើយរបស់អ្នកដែលមាននៅតាមព្រំ

ប្រទល់ផ្នែខាងកើតនេះ ដែលនិយាយអំពីការលុកលុយចូលរបស់ក្រុមទ័ពវៀតណាម។ តើលោកមានធ្លាប់ជួបប្រទះនឹងបញ្ហាព្រំប្រទល់នេះដែរឬទេ នៅពេលដែលលោកបំពេញការងាររបស់លោកក្នុងការស្រាវជ្រាវ...។ល។ នេះ?

**ឆ៖** បាទ ខ្ញុំបានបំពេញការងារហ្នឹងខ្លះដែរ។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេ ថានៅក្នុងឯកសាររកឃើញនោះ នៅក្នុងឯកសារផ្សេងៗទៀត ឬក៏តាមរយៈឯកសារ ឬក៏តាមការសម្ភាសនៅកន្លែងណាមួយ លោកអាចបញ្ជាក់ឲ្យច្បាស់ទេ នៅក្នុងតាមរយៈឯកសារអី? ហើយតាមរយៈការសម្ភាសនៅកន្លែងណាដែរ?

**ឆ៖** ទាក់ទងទៅនឹងឯកសារនានា ខ្ញុំមិនដឹងច្បាស់អំពីក្របខ័ណ្ឌ វាជាសារទូរលេខ វាអាចជារបាយការណ៍ ដែលផ្ញើមកពីផ្នែកខាងកើតនៃប្រទេស ដែលរបាយការណ៍ ឬតេឡេក្រាមនេះ គឺនិយាយអំពីបញ្ហាវៀតណាមដែលលុកលុយចូលមកក្នុងដែនដីកម្ពុជា។ ទាក់ទងទៅនឹងកិច្ចសម្ភាសន៍វិញ តាមដែលខ្ញុំចាំនោះ គឺគិតនៅពេលដែលខ្ញុំធ្វើការជាមួយនឹង ក.ស.ព ហើយនិង ក.ស.ច.ស។ ខ្ញុំមិនចាំជាក់លាក់អំពីបញ្ហានេះទេ។ ប៉ុន្តែចំពោះកិច្ចសម្ភាសន៍ចន្លោះពីឆ្នាំ១៩៧៨ ដល់១៩៨៤ និងកិច្ចសម្ភាសន៍ដែលខ្ញុំបានធ្វើនៅក្នុងឆ្នាំ២០០៥ គឺថាយើងតែងតែជួបប្រទះរឿងបែបនេះឯង គឺនៅខែកុម្ភៈ ៧៦ គឺនៅទីតាំងត្រង់នោះឯង។ ដូច្នេះ និយាយឲ្យទូលំទូលាយទៅ គឺថាខ្ញុំធ្លាប់បានធ្វើការផ្នែកនេះ។

[១៤:៣៣:៤៣]

**ស៖** ដើម្បីត្រឡប់មកនិយាយពីបញ្ហាកាលបរិច្ឆេទនេះ លោកបានឆ្លើយថា មិនប្រាកដថាជាថ្ងៃទី២០ កុម្ភៈ ៧៦ ទេ។ ក៏ប៉ុន្តែតើលោកអាចនិយាយថាការជម្លោះព្រំប្រទល់នេះ អាចកើតមានឡើងនៅពេលផ្សេងទៀត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះឆ្នាំណាមួយ តើលោកអាចបញ្ជាក់បានទេ ចន្លោះពីឆ្នាំនេះទៅឆ្នាំនោះ អាចមានដែរ? ខ្ញុំសូមបញ្ជាក់គឺតាមរយៈឯកសារលោក ដែលលោកមាន និងតាមរយៈការងាររបស់លោក ទោះជាកិច្ចសម្ភាសន៍ ឬក៏ការងារស្រាវជ្រាវផ្សេងៗ ខ្ញុំសូមបញ្ជាក់។

**ឆ៖** បាទ ទុកបញ្ហានៃការលំបាកនេះចោលមួយអន្លើ។ បញ្ហាពីវត្តមានរបស់កងទ័ពវៀតណាមនៅក្នុងប្រទេសកម្ពុជា គឺនៅក្នុងបរិបទដែលពាក់ព័ន្ធទៅនឹងការឈ្លានពានចូលមកព្រំដែន ចូលមកក្នុងទឹកដីកម្ពុជា គេធ្វើការញែកអំពីបញ្ហានេះដែរ។ ចំពោះរឿងរ៉ាវដែលកើតមានតាំងពីមុនខែកុម្ភៈ ឆ្នាំ១៩៧៥ រហូតមកដល់ ៧៥, ៧៦, ៧៧ ហើយពី១៩៧៧ តរហូត គឺថាមានការប្រយុទ្ធទៅវិញទៅមក។ ភាគីទាំងពីរហ្នឹងបានទទួលស្គាល់ ថាបានប្រយុទ្ធគ្នាទៅវិញទៅមក។ តាមកិច្ចសម្ភាសន៍ ហើយនិង

ឯកសារផ្លូវការផ្ទៃក្នុងនោះ គឺមានឯកសារផ្ទៃក្នុងតាំងពីមុន១៩៧៥ ក៏ដូចជាក្រោយ៧៥។ គឺថាការវាយប្រយុទ្ធគ្នានេះកាន់តែកើតឡើងក្លាយទៅជាទ្រង់ទ្រាយមួយធំ រហូតដល់ឈានដល់ខែមករា ១៩៧៩ តែម្តង។

[១៤:៣៦:០០]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំសូមចូលទៅប្រធាបបទថ្មីមួយទៀត។ លោកប្រធានចង់ឲ្យយើងខ្ញុំសម្រាកឥឡូវនេះ ឬក៏លោកប្រធានចង់ឲ្យខ្ញុំបន្តទៀត លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះក៏ដល់ពេលសម្រាកដែលហើយ អង្គជំនុំជម្រះប្រកាសចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦នាទី ដល់ម៉ោង ១៥:០៧នាទី)*

[១៥:០៧:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស្ទីវ ហេដឌ័រ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឥឡូវខ្ញុំសូមចូលមកនិយាយអំពីប្រធានបទថ្មីមួយទៀត នៅសវនាការថ្ងៃទី១១ កក្កដា ឆ្នាំ ២០១៣ នៅម៉ោង ១៥:២៨:០០ សហព្រះរាជអាជ្ញាបានសួរសំណួរលោកដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ទាក់ទងទៅនឹងព័ត៌មានអង្គហេតុ ហើយនិងប្រភពព័ត៌មានអង្គហេតុនេះ ខ្ញុំមិនសួរឲ្យលោកបញ្ចេញមតិ ឬក៏ការធ្វើសន្និដ្ឋានទេ ទាក់ទងទៅនឹង ស-២១ អ៎! ទាក់ទងទៅនឹងមន្ទីរ៨៧០។ តើលោកមានឯកសារដែរឬទេ?" ហើយចម្លើយរបស់លោក លោកឆ្លើយថា៖ "បាទ ក៏ប៉ុន្តែខ្ញុំសូមពិនិត្យឯកសារទាំងអស់នោះម្តងទៀត។ ខ្ញុំគិតថាមានពាក្យពេចន៍ផ្សេងៗ ក៏ប៉ុន្តែដោយបញ្ហានេះវាជាបញ្ហាចម្រូងចម្រាស ហើយនិងសំខាន់ ហើយនិងមានភាពស្រពេចស្រពិលទាក់ទងនឹងពាក្យពេចន៍ដែលគេប្រើទាក់ទងទៅនឹងមូលដ្ឋានអង្គហេតុនេះ"។

[១៥:០៩:១០]

សំណួរទី១ របស់ខ្ញុំដូចតទៅនេះ តើលោកចង់និយាយយ៉ាងម៉េចដែរនៅពេលដែលលោកនិយាយជាបញ្ហាមានការប្រទាញប្រទង់គ្នា ហើយនិងសារៈសំខាន់នេះ តើលោកចង់សំដៅទៅលើអ្វីពេលដែលលោកនិយាយប្រើពាក្យពេចន៍នេះទៅសហព្រះរាជអាជ្ញានេះ លោកចង់មានន័យយ៉ាងម៉េចដែរ?

**លោក ស៊្មីវ ហេងឌ័រ៖**

**ឆ៖** ខ្ញុំគិតថា វាមិនមែនជាភាពប្រទាញប្រទង់អីនោះទេ។ គឺថា គ្រាន់តែថាលេខកូដ៨៧០ ឬក៏ពាក្យ៨៧០ ហ្នឹងវាជារចនាសម្ព័ន្ធថ្នាក់កំពូលនៅក្នុងឋានានុក្រមរបស់បក្ស។ គឺថាមានសក្ខីកម្មដែលជាការសម្ភាស ក៏ដូចជាឯកសារមួយចំនួនដែលបាននិយាយ ឬក៏បានបង្ហាញថា ដែលបានបង្ហាញជាពិសេសអំពីវត្តមានក៏ដូចជាតួនាទីរបស់មន្ទីរ៨៧០។ ដូចដែលខ្ញុំបានបញ្ជាក់ពីដើមរួមមកហើយ គឺថាវាមិនមានភាពច្បាស់លាស់នៅក្នុងភាសាខ្មែរ ថាតើនៅណាដែលប្រើជាឯកវចនៈ នៅពេលណាដែលយើងប្រើជាពហុវចនៈ គឺអត់ច្បាស់លាស់ទេនៅក្នុងភាសាខ្មែរយើង។ ដូច្នេះហើយទោះបីថាយើងពាក្យ៨៧០ ឬក៏មន្ទីរ៨៧០ ឬក៏មន្ទីរ៨៧០ជាពហុវចនៈក៏ដោយ ក៏ខ្ញុំគិតថាគេចាត់ទុកថាវាជាមន្ទីរសំខាន់ ឬក៏ -- ប៉ុន្តែយើងនៅតែមិនមានឯកភាពគ្នាក្នុងចំណោមអ្នកដែលខ្ញុំបានសួរជាច្រើននាក់ ក៏ដូចជានៅក្នុងអង្គជំនុំជម្រះនេះក៏មិនមានភាពច្បាស់លាស់ ព្រោះថាខ្ញុំបានពិភាក្សាបញ្ហានេះនៅក្នុងការពិភាក្សាជាមួយភាគីនានារួចទៅហើយ។

[១៥:១១:២៧]

ដូច្នេះខ្ញុំគិតថាជាជាងនិយាយលើកឡើងយោងនូវឯកសារនោះ គឺខ្ញុំក៏ចង់ឃើញឯកសារនោះ ជាជាងការដែលគ្រាន់តែនិយាយជាទូទៅ ហើយថាវាមានបញ្ហានៅក្នុងការចងចាំ ឬក៏វាមានបញ្ហានៅក្នុងឯកសារអីបែបនោះ។ ដូច្នេះប្រសើរជាងការដែរខ្ញុំនិយាយទូទៅ។

**ស៖** អ៊ីចឹងហើយគឺថា ខ្ញុំចង់ចូលបង្ហាញឯកសារទាំងអស់នេះទៅលោក ដើម្បីសុំមតិយោបល់ ឬក៏ការបំភ្លឺរបស់លោក ដោយសារលោកជាអ្នកបានសិក្សាលើបញ្ហាទាំងអស់នេះ។ ក៏ប៉ុន្តែមុននឹងចូលទៅធ្វើនេះ ខ្ញុំចង់និយាយអំពីតួលេខ៨៧០នេះ ហើយខ្ញុំផ្តល់ពាក្យមួយចំនួន ហើយដើម្បីសុំសួរលោកថា តើពាក្យដែលខ្ញុំនឹងបង្ហាញនេះមានន័យយ៉ាងម៉េច? ហើយមានពាក់ព័ន្ធទៅនឹងឯកសារដែលលោកបានស្រាវជ្រាវស៊ើបអង្កេតឃើញដែរឬទេ? ឧទាហរណ៍ ពាក្យទី១ គឺ "គណៈ៨៧០"។ តើគណៈ៨៧០ នេះដូចគ្នានឹងមន្ទីរ៨៧០ ដែរឬទេ? តើ ម-៨៧០ នេះ យ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៥:១៣:០៨]

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាឥឡូវនេះ យើងកំពុងតែធ្វើឲ្យមានការស្នើសុំឲ្យមានការបញ្ចេញមតិយោបល់ហើយ។ ហើយវាមិនមានឯកសារជាក់លាក់ណាមួយដែលនិយាយអំពីគណៈ៨៧០ មន្ទីរ៨៧០ ឬក៏ម-៨៧០ នោះ ដែលថាលោក ហេដឌ័រ គាត់ចង់ឲ្យមានឯកសារជាក់លាក់ណាមួយ។ ដូច្នេះ គួរតែមានការសួរសំណួរទៅលើឯកសារជាក់លាក់ណាមួយដែលថាឯកសារនោះមិនមែនជាការស្នើសុំឲ្យមានការបញ្ចេញមតិរបស់អ្នកជំនាញ។ ប៉ុន្តែខ្ញុំគិតថាឥឡូវនេះ យើងកំពុងតែមានការប្រែប្រួលដោយសារតែយើងផ្លាស់ប្តូរពីការចាត់ទុកលោក ហេដឌ័រ ជាសាក្សីអង្គហេតុទៅជាសាក្សីអ្នកជំនាញ។

ដូច្នេះ ខ្ញុំគិតថាគួរតែមានការពិចារណាបន្ថែមទៀតទៅលើបញ្ហានេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ដូចខ្ញុំបានជម្រាបជូនអ៊ីចឹងឯង គឺខ្ញុំនឹងបង្ហាញឯកសារបន្តិចទៀត។ ខ្ញុំសួរម្តងទៀត តើលោកធ្លាប់បានឮពាក្យគណៈ៨៧០ដែរទេ ក្នុងក្របខ័ណ្ឌការងាររបស់លោកនៅ អ.វ.ត.ក ហើយនិងក្នុងការងារស្រាវជ្រាវស៊ើបអង្កេតរបស់លោកនោះ លោកធ្លាប់បានឮពាក្យគណៈ៨៧០នេះដែរឬទេ?

[១៥:១៤:៤២]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ ពិតហើយ គឺថាប្រាដកណាស់ ខ្ញុំធ្លាប់ឮ។ ខ្ញុំធ្លាប់ឮពាក្យនេះ ដែលពាក្យហ្នឹងគឺគេប្រើតាំងពីមុនពេលមានតុលាការនេះមកម្ល៉េះ។ គឺថាហើយនៅពេលដែលខ្ញុំនៅតុលាការ និងក្រោយពេលដែលខ្ញុំនៅតុលាការហ្នឹងក៏ឮពាក្យនេះដែរ។ ដូច្នេះតាមខ្ញុំគិតគឺថា ពាក្យនេះវាមាននៅក្នុងឃ្លាមួយដែលគេហៅថាមន្ទីរ៨៧០។ តាមដែលខ្ញុំចាំទាក់ទងទៅនឹងឯកសារ ក៏ដូចជាព័ត៌មានដោយផ្ទាល់មាត់ គឺគេសំដៅទៅលើគណៈ៨៧០ ទាំងមូល ឬក៏ជាទូទៅគេច្រើនតែហៅថាគណៈ៨៧០ អ៊ីចឹងមិនមែនជាគណៈកម្មការ ជាជាងការប្រើប្រាស់ពាក្យគណៈកម្មការ៨៧០ គេប្រើពាក្យគណៈ៨៧០ ដោយខ្លី។

ហើយចំពោះអ្នកដែលខ្ញុំធ្លាប់ជួបជាមួយ ធ្លាប់សម្ភាសជាមួយហ្នឹង គាត់ គឺគេប្រើត្រឹមតែពាក្យថា គណៈ។ ហើយគណៈហ្នឹងគឺគេសំដៅទៅលើបុគ្គលតែមួយរូប។ ហើយអ្នកដែលខ្ញុំធ្លាប់ជួបជាច្រើនឆ្នាំ ពិភាក្សាជាមួយជាច្រើនឆ្នាំបាននិយាយថា អាចថាពាក្យហ្នឹងគេសំដៅទៅលើគណៈកម្មការ ឬមួយក៏គេនិយាយសំដៅទៅលើបុគ្គលដែលជាថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៅក្នុងគណៈកម្មការហ្នឹង ឬក៏អាចថាពេលខ្លះគេសំដៅទៅលើចំណុចនេះ ឬក៏វត្ថុនេះ ឬក៏មនុស្សនេះ ពេលខ្លះគេសំដៅទៅលើអ្វីមួយផ្សេង។ ដូច្នេះហើយ គឺថាខ្ញុំធ្លាប់ឮគេនិយាយច្រើនផ្សេងៗគ្នាក្នុងរយៈពេលកន្លងមកហើយនោះ។

ហេតុដូច្នេះហើយក្នុងអ្វីដែលខ្ញុំបាននិយាយ ខ្ញុំគិតថាវាហាក់ដូចជាមិនច្បាស់ វាមិនប្រាកដប្រជាសោះចំពោះការប្រើប្រាស់ពាក្យ ក៏ដូចប្រើប្រាស់រូបមន្តនៃការសរសេរ ឬក៏ការនិយាយនេះ។

[១៥:១៧:០៣]

**ស៖** តើលោកបានឮពាក្យ ខ្ញុំអានជាបារាំង "មន្ទីរ៨៧០ ជាភាសាខ្មែរហ្នឹង មន្ទីរ៨៧០ បារាំង "*ប៊ុយរ៉ូ វីដសង់ស្វាសង់ឌីស*" ហើយភាសាខ្មែរគឺមន្ទីរ៨៧០"។ តើលោកធ្លាប់ឮពាក្យហ្នឹងទេ ឬក៏ឃើញ?

**ឆ៖** បាទ គឺថានៅក្នុងការងាររបស់ខ្ញុំតាំងពីមុនពេលដែលមានតុលាការខ្មែរក្រហមហ្នឹង ក៏ដូចជានៅពេលដែលខ្ញុំកំពុងធ្វើការនៅក្នុងតុលាការហ្នឹង គឺខ្ញុំឮពាក្យនេះ។ ហើយខ្ញុំថា វាជាបញ្ហានៃការប្រើប្រាស់ភាសាប៉ុណ្ណោះ។ ពាក្យថាមន្ទីរជាទូទៅគេប្រើជាភាសាអង់គ្លេសទេថាជា "*អូហ្វហ្វីស*"។ ហើយមុនហ្នឹងគឺគេគិតថា៨៧០ហ្នឹង គឺជាពាក្យកាត់របស់ពាក្យថា "មន្ទីរ"នោះ។ ខ្ញុំធ្លាប់មានការពិភាក្សាអំពីបញ្ហានេះជាមួយនឹងជនជាតិកម្ពុជា ក៏ដូចជាបក្ខជនដែលគាត់ដឹង ឬក៏គាត់ស្គាល់ ឬក៏ចេះទាំងពីរភាសា។ ហើយពួកគាត់ធ្លាប់ប្រាប់ខ្ញុំថា ពាក្យថា "មន្ទីរ" ក្នុងភាសាខ្មែរគឺដកយកចេញពីភាសាវៀតណាមហៅថា

*"បំ"(តាមសូរស័ព្ទ)* ហើយជាការបកប្រែពាក្យមកពីភាសាវៀតណាម។ ពេលខ្លះភាសាវៀតណាម ពាក្យហ្នឹងមានន័យថា សេវាកម្ម ឬក៏ការផ្តល់សេវា។ ដូច្នេះហើយ ខ្ញុំគិតថាវាគ្រាន់តែជាពាក្យដូចគ្នា គ្រាន់តែយើងយកមកប្រើប្រាស់ក្នុងភាសាខុសគ្នាតែប៉ុណ្ណោះ។

[១៥:១៩:០៨]

**ស៖** តើនៅក្នុងក្របខ័ណ្ឌការងាររបស់លោក មុន និងក្រោយ ក្នុងពេលដែលលោកធ្វើការនៅ អ.វ.ត.ក នេះ លោកធ្លាប់បានជួបឯកសារ ឬក៏ធ្លាប់បានសម្ភាសគេ មានគេប្រើពាក្យមន្ទីរនយោបាយ ៨៧០ដែរឬទេ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំធ្លាប់ឃើញម្តងដែរពាក្យនេះនៅក្នុងឯកសារ។ ប្រហែលជាវាតិចតួចពេកមើល ទៅ។ ប៉ុន្តែបើសិនបើតាមការនិយាយផ្ទាល់មាត់ ខ្ញុំធ្លាប់ឮម្តងម្កាលដែរ។ តាមដែលខ្ញុំចាំ គឺគេមិនប្រើ ប្រាស់ញឹកញាប់នោះទេ គឺកម្រមានការប្រើប្រាស់ពាក្យនេះណាស់នៅក្នុងបរិបទនានា ដូចដែលលោក ស្រីបានសួរខ្ញុំហ្នឹង។

**ស៖** ពាក្យចុងក្រោយ ខ្ញុំសួរសំណួរដដែលទេ សួរដូចមុនៗដែរ តើលោកធ្លាប់បានឮពាក្យហ្នឹង ឃើញពាក្យហ្នឹង ឬក៏អានពាក្យហ្នឹង នៅក្នុងក្របខ័ណ្ឌការងាររបស់លោក មុនធ្វើការនៅ អ.វ.ត.ក នេះ ហើយឬក្រោយក្នុងពេលមុន ឬក៏ក្រោយ។ ដូចជាបង៨៧០ ពាក្យថា "បង៨៧០" នេះ លោកធ្លាប់បាន ជួបប្រទះទេ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំធ្លាប់ឃើញពាក្យហ្នឹងនៅក្នុងឯកសារផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា ដែលខ្ញុំឃើញ នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា មុននឹងគេបង្កើតតុលាការខ្មែរក្រហមនេះឡើង។ ហើយនៅពេល ដែលខ្ញុំធ្វើការនៅក្នុងតុលាការនេះ គឺខ្ញុំធ្លាប់ជួបពាក្យហ្នឹងដែរ។

[១៥:២១:១០]

**ស៖** ដូចដែលលោកបានឆ្លើយប្រាប់ខ្ញុំថា លោកធ្លាប់ឃើញពាក្យមន្ទីរនយោបាយ៨៧០។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារហ្នឹងជាភាសាខ្មែរ។ ឯកសារមួយជាភាសាខ្មែរ គឺឯកសារ E3/182 ហើយខ្ញុំសូមអញ្ជើញលោកមន្ត្រីតុលាការជូនឯកសារនេះទៅលោកសាក្សី ស្ទីវ ហេដឌ័រ ហើយនិងជូនភាគីផងដែរ។ ចំពោះភាគីគឺ ERN ជាភាសាបារាំងគឺ 00292868។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឲ្យឯកសារនេះ ទៅលោកសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ERN ជាភាសាខ្មែរគឺ 00019108, ERN ជាភាសាអង់គ្លេសគឺ 00183393។ ខ្ញុំសូមបញ្ជាក់ថា ផ្នែកដែលខ្ញុំចាប់អារម្មណ៍នោះ គឺនៅទំព័រទី១ នៃឯកសារនុ៎ង។ ទំព័រទី១ទាំងបីភាសាតែម្តងហើយនិងទំព័របន្ទាប់ ទំព័រទី១ និងទំព័រទី២ គឺជាកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ថ្ងៃទី០៩ តុលាឆ្នាំ១៩៧៥។

របៀបវារៈដូចតទៅនេះ "១) ការបែងចែកការងារ និងកិច្ចដំណើរការ ២) ការរៀបចំនៅរួម ៣) ការចាត់ចែងការងារជាក់ស្តែងមួយចំនួន ពាណិជ្ជកម្ម យោធា"។ ខ្ញុំសូមឲ្យលោកសាក្សីអានឯកសារនេះហើយនិងជម្រាបជូនតុលាការថា តើលោកធ្លាប់បានឃើញឯកសារនេះដែរឬទេ?

[១៥:២៣:៣១]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ ខ្ញុំធ្លាប់ឃើញ។

**ស៖** ឥឡូវខ្ញុំសូមចោទសំណួរបន្តលើទំព័រទី១នេះដដែល។ "ចំណុចទី១ ការបែងចែកការងារ និងកិច្ចដំណើរការ៖ ១) សមមិត្តលេខទទួលរួមយោធា និងសេដ្ឋកិច្ច, ២) សមមិត្តអនុលេខាការងារបក្សសង្គមកិច្ច វប្បធម៌ ឃោសនា និងការសិក្សាធិការ, ៣) សមមិត្ត វ៉ាន់ ការងារបរទេស និងទាំងបក្សទាំងរដ្ឋ, ទី៤) សមមិត្ត ហែម ទទួលរណសិរ្ស និងរាជរដ្ឋាភិបាល ពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ, ៥) សមមិត្ត ធុច ពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស, ៦) សមមិត្ត ខៀវ ទទួលសេនាធិការនិងសន្តិសុខ"។ ខ្ញុំសូមបន្តទៀត ៧) -- គឺទំព័របន្តទៀតគឺ ERN បន្តទៀតនៅក្នុងគ្រប់ភាសាទាំងអស់ហ្នឹងភាសាទាំងបី។ "សមមិត្ត វន ឧស្សាហកម្មរថភ្លើង និងនេសាទ, ៨) សមមិត្ត ឌឿន ប្រធានមន្ទីរនយោបាយរបស់មន្ទីរ៨៧០, ៩) សមមិត្ត ភា ទទួលបន្ទុកវប្បធម៌ សង្គមកិច្ច និងការងារបរទេស, ១០) សមមិត្ត អាត ឃោសនាអប់រំទាំងផ្ទៃក្នុង និងខាងក្រៅ, ១១) សមមិត្ត ជ័យ កសិកម្ម, ១២) សមមិត្ត យ៉ែម ការិយាល័យ៨៧០, ១២) សមមិត្ត ប៉ង់ មន្ទីររដ្ឋបាល"។ ជាភាសាបារាំងឃើញគេបកប្រែថា "*អាដមីនីស្ត្រាស្យុង*"។

[១៥:២៥:៤០]

បើសិនជាខ្ញុំមិនច្រឡំទេ នៅលេខ៨ ដែលខ្ញុំទើបនឹងអានអម្បាញ់មិញនេះគឺមានឈ្មោះ ឌឿន ជាប្រធានមន្ទីរនយោបាយរបស់៨៧០។ អ៊ីចឹងខ្ញុំហាក់ដូចជាឃើញថា ពាក្យថា "ប៊ុយរ៉ូ" បកប្រែជាខ្មែរនេះឃើញថា "មន្ទីរ"។ តើត្រឹមត្រូវដែរឬទេលោកភាសាបារាំង "ប៊ុយរ៉ូ" ភាសាខ្មែរ "មន្ទីរ"? តើលោកមានធ្លាប់ឃើញទេពាក្យមន្ទីរ៨៧០នោះ "ប៊ុយរ៉ូ" ហើយនិង "មន្ទីរ"?

**ឆ៖** បាទ គឺថាតាមពិតទៅពាក្យនេះ គឺគេបកប្រែជាទូទៅថា "អូសហ្វី" ពីភាសាអង់គ្លេសហ្នឹងគឺខ្មែរ "មន្ទីរ"។ ហើយវាគឺជាគំរូ ឬក៏ជាទម្រង់មួយដែលគេប្រើប្រាស់ ហើយគេប្រើប្រាស់នូវពាក្យថា "របស់" របស់ជាភាសាខ្មែរហ្នឹង គឺថាជារបស់មន្ទីរនយោបាយហ្នឹង។ ប៉ុន្តែនៅក្នុងបរិបទនេះវាហាក់ដូចជាចម្លែក ព្រោះថាមិនឃើញមានប្រើនៅកន្លែងផ្សេងនោះទេ។ វាធ្វើដូច្នេះវាហាក់ដូចជាធ្វើឲ្យយើងយល់ឃើញមន្ទីរនយោបាយហ្នឹងជារបស់អ្នកដទៃ ឬក៏ជារបស់អ្នកណា។ អាចថាគាត់ថាជាប្រធានមន្ទីរនយោបាយដែលជាកម្មសិទ្ធិរបស់៨៧០ អាចថាមិនមែនជាមន្ទីរ៨៧០ ឬក៏ជានេះទេ។ ខ្ញុំមិនមែនជាអ្នកជំនាញឲ្យច្បាស់នោះទេ។

[១៥:២៧:២៣]

**ស៖** នៅលេខ១២ នៃបញ្ជីហ្នឹងជាភាសាបារាំងហ្នឹងបកប្រែថា "ប៊ុយរ៉ូ" ដែលគឺសមមិត្ត យែម ប៊ុយរ៉ូ ៨៧០។ អ៊ីចឹងជាភាសាខ្មែរគេសរសេរថា ពាក្យថា "ការិយាល័យ"។ តើលោកធ្លាប់ឮពាក្យហ្នឹងទេ ពាក្យ "ការិយាល័យ" ហ្នឹង? តើលោកដឹងថាបើតាមរយៈឯកសារ ឬក៏ការសម្ភាសក្នុងការក្របខ័ណ្ឌការងាររបស់លោក នៅពេលដែលលោកពិនិត្យមើលធាតុផ្សំភស្តុតាងនោះ លោកមានបានជួបពាក្យហ្នឹងទេ "ការិយាល័យ" ជាភាសាខ្មែរហ្នឹង?

**ឆ៖** ខ្ញុំអាចឆ្លើយបានថា នេះជាលើកទី១ ដែលខ្ញុំឃើញការប្រើប្រាស់លក្ខណៈបែបនេះ ឬក៏ជាទម្រង់បែបនេះ។ ប្រសិនបើខ្ញុំត្រូវធ្វើការបកប្រែដើម្បីឲ្យមានភាពខុសគ្នារវាងពាក្យទាំងពីរនេះ ខ្ញុំនឹងប្រើប្រាស់ភាសាជាភាសាអង់គ្លេសថា "ប៊ុយរ៉ូ" ដើម្បីសំដៅទៅលើ "ការិយាល័យ" ដើម្បីធ្វើឲ្យឃើញខុសគ្នាអំពីពាក្យដែលគេប្រើប្រាស់ទូទៅសម្រាប់ "មន្ទីរ"។ ដូច្នេះ ខ្ញុំគិតថាពាក្យទាំងពីរនេះ គឺយើងអាចប្រើប្រាស់ការបកប្រែឲ្យវាខុសគ្នាបន្តិច។

ចំពោះខ្ញុំ ក្នុងនាមខ្ញុំជាអ្នកនិយាយភាសាអង់គ្លេសជាភាសាកំណើតហ្នឹង ខ្ញុំគិតថាពាក្យថា "ការិយាល័យ" វាមើលទៅដូចជាមានលក្ខណៈការិយាធិបតេយ្យ ហើយវាតូច គឺតូចជាងប្រធាន តូចជាងមន្ទីរ។ អានេះគឺហោចណាស់ក៏តាមអ្វីដែលខ្មែរក្រហមគេបានប្រើប្រាស់។ ប៉ុន្តែអាចថាវាមានអ្វី

ខុសគ្នា ឬក៏វាមានភាពខុសគ្នានៅទីនេះ។ ដូច្នេះខ្ញុំពិបាកក្នុងការនិយាយអំពីចំណុចមួយនេះ។

**ស៖** ខ្ញុំសូមអរគុណដែលបានបញ្ជាក់បំភ្លឺនេះ។ ឥឡូវនេះខ្ញុំសូមលើកយកកំណត់ហេតុ មិនមែនជាកំណត់ហេតុទេ គឺឯកសារ E3/235។ យោងជាភាសាខ្មែរគឺ ERN 00019142 គឺទំព័រទី១, យោងជាភាសាបារាំងគឺ 00322968, ភាសាអង់គ្លេសគឺ 00183416។ គឺនៅទំព័រទី១ ឯកសារនេះមានចំណងជើងថា "សេចក្តីសង្ខេបនៃសេចក្តីសម្រេចគណៈអចិន្ត្រៃយ៍នៃកិច្ចប្រជុំថ្ងៃទី២០-២១ មេសា ឆ្នាំ ១៩៧៦"។

[១៥:៣០:៤៨]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារជាភាសាខ្មែរជូនទៅលោក ស្ទីវ ហេដឌ័រ ដើម្បីឲ្យគាត់អាចពិនិត្យពិគ្រោះឯកសារហ្នឹង លោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឥឡូវគេប្រាប់ខ្ញុំថា ឥឡូវនេះ គេមានសំណៅតែជាភាសាអង់គ្លេសទេ។ អ៊ីចឹងយើងសូមបញ្ចាំងជាភាសាអង់គ្លេស -- ជាភាសាខ្មែរនៅលើអេក្រង់សិន ហើយនិងឲ្យជាក្រដាសទៅលោកបន្តិចទៀតនេះ នៅពេលលោកមាន -- ឥឡូវសួរថា ឯកសារហ្នឹងបញ្ចាំងហើយឬនៅ? បន្ទាប់ពីចំណងជើងនៃសេចក្តីសម្រេចហ្នឹងមានសរសេរ "បន្ទាប់ពីបានពិភាក្សាអស់រយៈពេល៣ថ្ងៃលើបញ្ហាដែលមាននៅក្នុងរបៀបវារៈ គណៈអចិន្ត្រៃយ៍បានធ្វើសេចក្តីសម្រេចដូចតទៅ៖ I. អំពីការរៀបចំចាត់តាំងគណៈកម្មាធិការផ្សេងៗនៅជុំវិញ៨៧០: ១) គណៈកម្មាធិការពាណិជ្ជកម្ម"។

ឥឡូវនេះ ខ្ញុំសូមកម្រិតមកត្រឹមតែរៀបរាប់ពាក្យឈ្មោះ គណៈកម្មការផ្សេង មិនទាន់រៀបរាប់ឈ្មោះទេ។

"១) គណៈកម្មាធិការពាណិជ្ជកម្ម លេខ១ -- ២) គណៈកម្មាធិការថាមពល, ៣) គណៈកម្មាធិការដឹកជញ្ជូនផ្លូវគោក, ៤) ខាងផ្លូវទឹក, ៥) គណៈកម្មាធិការឃ្លាំងនៅភ្នំពេញ,៦) គណៈកម្មាធិការកំពង់ផែ"។

ហើយទំព័របន្ទាប់មកទៀតនោះ៖ "៧) គណៈកម្មាធិការកសិកម្ម, ៨) គណៈកម្មាធិការឧស្សាហកម្ម, ៩) គណៈកម្មាធិការសាធារណការ, ១០) គណៈកម្មធិការផ្លូវដែក, ១១) គណៈកម្មាធិការកាត់ដេរសម្លៀកបំពាក់"។

ខ្ញុំបញ្ចប់ការដកស្រង់ខ្ញុំត្រឹមនេះសិន ហើយខ្ញុំសូមឲ្យលោកមន្ត្រីតុលាការយកឯកសារជាភាសាខ្មែរនេះជូនទៅលោក ស៊ីវ ហេងឆ័រ។

[១៥:៣៣:២៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** សំណួរខ្ញុំដូចតទៅនេះ តើលោកបានដឹងពីឯកសារនេះទេ ហើយលោកបានធ្លាប់ពិគ្រោះឯកសារនេះនៅពេលមុន ឬក៏ក្នុងពេលក្រោយដែលលោកបានមកធ្វើការនៅ អ.វ.ត.ក នេះទេ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** បាទៗធ្លាប់។

**ស៖** តើលោកមានបានស្តាប់បុគ្គលមួយចំនួននៅក្នុងពេលដែលលោកសម្ភាស ឬក៏ពេលលោកស្តាប់យកចម្លើយ ហើយលោកបានធ្លាប់ឃើញប្រទះនឹងឯកសារមួយចំនួនដែលមាននិយាយអំពីគណៈនៅ -- ដែលស្ថិតនៅក្រោម ដែលនៅជុំវិញ៨៧០នេះ លោកធ្លាប់ជួបប្រទះទេ?

[១៥:៣៤:៤១]

**ឆ៖** បាទ ធ្លាប់បានជួបខ្លះដែរ គឺឯកសារទាំងពីរ។ បាទ ហើយក៏ធ្លាប់បានដឹងតាមរយៈការសម្ភាសផ្ទាល់មាត់នោះដែរ។

**ស៖** ខ្ញុំត្រឡប់មកនិយាយពីចំណុចនេះបន្តិចទៀត ឥឡូវខ្ញុំសូមបន្តទៅឯកសារមួយទៀត។ គឺឯកសារ E3/220 ERN ជាភាសាបារាំងគឺ 00323891, ERN ជាភាសាអង់គ្លេសគឺ 00182706, ERN ជាភាសាខ្មែរគឺ 00000827។ ដូចអម្បាញ់មិញដែរ គឺថាឥឡូវនេះសូមចាំព្រីនឯកសារនេះសិន ប៉ុន្តែមុននឹងព្រីននេះ ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារហ្នឹងទៅលើអេក្រង់ គឺជាកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី០៧ ឧសភា ឆ្នាំ១៩៧៦ ដែលមានចំណងជើងថា “បញ្ហាពាណិជ្ជកម្ម”។ សមាសភាពអ្នកចូលរួមប្រជុំគឺសមមិត្តលេខា សមមិត្តអនុលេខា សមមិត្តវ៉ាន់ សមមិត្តវន សមមិត្តហែម សមមិត្តឌឿន សមមិត្តទូច និងកំណត់ហេតុ។

ខ្ញុំសូមឲ្យមន្ត្រីតុលាការជួយយកឯកសារនេះជាភាសាខ្មែរជូនលោក ស៊ីវ ហេងឆ័រ។

លេខ(១)តូច ឯកសារនេះមានចំណងជើង--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៥:៣៧:១៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

"លេខ(១) នេះគឺគណៈកម្មាធិការពាណិជ្ជកម្ម សមមិត្តជ័យ ពីកសិកម្មឲ្យមកកាន់កាប់ពាណិជ្ជកម្ម។ សមមិត្តឌឿន ចុះទៅពាណិជ្ជកម្មក្នុងរយៈពេល៣ខែ គឺពីខែ៥ ខែ៦ ដល់ខែ៧ ហើយកន្លះថ្ងៃនៅមន្ទីរ ហើយកន្លះថ្ងៃនៅពាណិជ្ជកម្ម។ សមមិត្តឌឿន ជ្រើសរើសមិត្តមួយចំនួនត្រៀមកសាងសម្រាប់ពាណិជ្ជកម្មក្រៅប្រទេស សមត្ថភាពត្រឹមមិត្តឈុន ឬក៏ទាបជាង"។ សូមបញ្ចប់ការដកស្រង់។

សំណួរទី១ ខ្ញុំមានតែសំណៅជាភាសាបារាំងទេ គឺមានឃ្លាសមមិត្តឌឿន បានជ្រើសរើសថាទៅសមមិត្តឌឿន ធ្វើការនៅមន្ទីរកន្លះថ្ងៃ និងកន្លះថ្ងៃទៀតទៅពាណិជ្ជកម្ម។ អ៊ីចឹងខ្ញុំចង់សួរលោកថាតើពាក្យ "ប៊ុយរ៉ូ" នេះជាភាសាខ្មែរ គេប្រើពាក្យអីដែរលោក?

**លោក ស៊ីវ ហេងឌ័រ៖**

**ឆ៖** ខ្ញុំបានឃើញឯកសារជាភាសាខ្មែរ គេប្រើមន្ទីរ ជាភាសាខ្មែរហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅបង្ហាញឯកសារមួយសំណុំទៀត ដែលមិនមែនជាកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ទេ ក៏ប៉ុន្តែជាសារទូលេខ។ ដើម្បីចោទសំណួរទៅលោកនេះ ដោយឯកសារទាំងអស់នេះខ្លីៗ ហើយដោយលោកនិយាយទាំងបីភាសាគឺ បារាំង អង់គ្លេស ខ្មែរ អ៊ីចឹងខ្ញុំសូមផ្ដល់ឯកសារទាំងបីៗសំណៅ ទាំងបីភាសានេះជូនទៅលោក ដើម្បីចៀសវាងនូវការភាន់ច្រឡំ ច្របូកច្របល់។

[១៥:៣៨:២១]

**កញ្ញា អង់តា ហ្គីសសេ៖**

ឯកសារទី១ គឺឯកសារ E3/258 ខ្ញុំសូមអនុញ្ញាតបញ្ចាំងសំណៅជាភាសាខ្មែរទៅលើអេក្រង់ ហើយនិងផ្ដល់ទាំងបីច្បាប់ ទាំងបីភាសាហ្នឹងទៅលោក ស៊ីវ ហេងឌ័រ ដើម្បីសួរគាត់ ថាតើគាត់ធ្លាប់ស្គាល់ឯកសារទាំងអស់ហ្នឹងឬក៏អត់? សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៥:៤០:០៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមឲ្យលោកពិនិត្យមើលសំណៅជាភាសាខ្មែរដែលមានលេខយោង ERN គឺ 0000 1108 ខ្ញុំសូមឲ្យលោកមើលសំណៅជាភាសាបារាំងផងដែរ។ នេះគឺជាសំណៅដែលខ្ញុំកំពុងតែប្រើនេះ ដែលមានលេខកូដ 00531058, ជាភាសាបារាំង ខ្ញុំសូមអានទូរលេខ03, 267ខ្ទង់ "ជម្រាបជូនគណៈ ម៨៧០ ជាទីស្នេហា និងនឹករឭក"។ ជាភាសារអង់គ្លេសគឺ ERN ទី៣នោះគឺ 00522911។ ខ្ញុំសូមអានជាភាសាអង់គ្លេស៖ "សារទូរលេខ៣ ដែលមាន 267ខ្ទង់ "ជម្រាបមកគណៈម-៨៧០ ជាទីស្នេហា និងនឹករឭក"។

សំណួរខ្ញុំដូចតទៅនេះ ពាក់ព័ន្ធនឹងឯកសារជាភាសាខ្មែរនោះ ខ្ញុំសួរលោកថាមានពាក្យអីនៅក្នុងសំណៅជាភាសាខ្មែរនោះទាក់ទងនឹងពាក្យគណៈអីនេះ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ភាសាខ្មែរដើមនេះ គឺប្រើជាពាក្យកាត់អក្សរ "ម" ជាអក្សរកាត់អាចថាជំនួសឲ្យពាក្យមន្ទីរ។ ហើយគណៈនេះគឺមកពីគណៈកម្មាធិការ។ ដូច្នេះ ការបកប្រែទៅជាភាសាបារាំង តាមខ្ញុំយល់នោះគឺមិនបកមិនបានច្បាស់លាស់ មិនបានល្អទេ។ ហេតុដូច្នេះឯងទើបឲ្យមានការប្រើពាក្យថា "គណៈ" គឺថាមិន -- គឺថាពាក្យនេះគឺត្រូវតែដោះស្រាយ ឬក៏បកប្រែឲ្យបានប្រុងប្រយ័ត្នត្រឹមត្រូវ។ អង់គ្លេសបកប្រែបានត្រឹមត្រូវល្អ អាចទទួលយកបានហើយ។ យើងអាចប្រើដូចជាពាក្យដូចជាពាក្យថា "*អូហ្វហ្វីស*" ហ្នឹងដាក់ពាក្យថាពាក្យ "អូ" អ៊ីចឹង គឺបកប្រែទៅជាភាសាអង់គ្លេស ដូចខ្ញុំបញ្ជាក់អ៊ីចឹង គឺថាល្អគ្រប់គ្រាន់ហើយ។ តែបារាំងមិនទាន់បានល្អទេ។

[១៥:៤៣:២៨]

**ស៖** សូមអរគុណចំពោះការឆ្លើយបំភ្លឺនេះ។ តើលោកធ្លាប់ឃើញឯកសារនេះពីមុនមកទេ?

**ឆ៖** បាទធ្លាប់។

**ស៖** អម្បាញ់មិញនេះ លោកលើកឡើងអំពីបញ្ហាពហុវចនៈ និងឯកវចនៈ គឺថាជាភាសាខ្មែរនោះអត់មានបញ្ហាទេ ពហុវចនៈនិងឯកវចនៈនោះ ក៏ប៉ុន្តែជាភាសាបារាំង គឺមានបញ្ហា។ ជាភាសាបារាំងនៅក្នុងឯកសារនេះ ខ្ញុំឃើញកន្លែងពាក្យថា ចម្លងជូន ដាក់ថា "ជូនអ៊ំ, អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន មន្ទីរ"។ មន្ទីរហ្នឹង គឺពហុវចនៈ។ ឯកសារហ្នឹងក៏ពហុវចនៈ។ អង់គ្លេស ខ្មែរ អត់មានបញ្ហាទេ។ នៅពេលដែលលោកអានឯកសារនេះជាភាសាខ្មែរ តើលោកដឹងទេថា កន្លែងចម្លងជូនថាមន្ទីរហ្នឹង តើមន្ទីរមួយ ឬក៏មន្ទីរ

ច្រើនជាភាសាខ្មែរនោះ?

**ឆៈ** បាទ បើមើលទៅទម្រង់ហ្នឹងគឺវាអត់មានបរិបទ នៅក្នុងឯកសារនេះដែលវាមានបរិបទគឺមិនច្បាស់ទេ មិនអាចដឹងបាន។ បើមិនបានបរិបទឲ្យទូលំទូលាយបញ្ជាក់ថា មន្ទីរនៅខាងក្រោមជាភាសាខ្មែរនេះ ជាឯកវចនៈ ឬក៏ជាពហុវចនៈមិនដឹងទេ។ ខ្ញុំក៏ស្មានដែរ បើសិនណាជាខ្ញុំត្រូវគិត ឬក៏បកប្រែហ្នឹង គឺថាវាជាឯកវចនៈ ឬក៏ជាពហុវចនៈ ខ្ញុំត្រូវបើកអក្ខរានុក្រម ឬវចនានុក្រមបញ្ជាក់ហើយ។ វាអាចជាឯកវចនៈ ពហុវចនៈ។ នេះដោយសារតែពាក្យខ្មែរមានតែមួយពាក្យយ៉ាងដូច្នេះ វាត្រូវមានអត្ថបទមួយមកបញ្ជាក់។ បើសិនណាជាមានអត្ថបទណាមួយមក បរិបទនៃអត្ថបទណាមួយអាចបញ្ជាក់ហើយ ថាតើពាក្យនេះវាជំនួសឲ្យឯកវចនៈ ឬក៏ពហុវចនៈនោះ។

[១៥:៤៦:០៦]

**សៈ** សូមអរគុណចំពោះការឆ្លើយបញ្ជាក់។

**កញ្ញា អង់តា ហ្គីសសេះ**

មុននឹងចូលទៅឯកសារផ្សេងទៀត ឥឡូវនេះខ្ញុំឃើញថាម៉ោងបីសែសិបប្រាំនាទីជាងហើយ។ ដូច្នេះ ក្នុងដំណាក់កាលនេះខ្ញុំសូមលើកឡើងនូវសំណើរបស់ខ្ញុំ គឺមិនមែនជាសំណើសុំបន្ថែមពេលទេ ព្រោះជាធម្មតាខ្ញុំត្រូវបានពេល១ថ្ងៃ។ ហើយដោយសារតែមានការជំទាស់ផ្សេងៗ ហើយនិងការសម្រេចផ្សេងៗនោះ ខ្ញុំសូមមាន ខ្ញុំសូមបន្ថែមពេលដើម្បីបន្ត។ ដូច្នេះ ខ្ញុំនៅតែរក្សាសំណើដំបូងរបស់ខ្ញុំដដែល ដែលខ្ញុំបានលើកឡើងតាំងពីដំបូងមកហើយនោះ។ គឺខ្ញុំសូមបន្ថែម១ម៉ោងកន្លះបន្ថែមទៀត ដើម្បីអាចឲ្យខ្ញុំបញ្ចប់ការសួរសំណួរបាន។ គឺថាស្អែកព្រឹកបន្ថែមទៀត ដូចដែលលោកប្រធានបានពិនិត្យឃើញហើយថាអាចការសួរបែបនេះគឺថាមានការលំបាកណាស់នៅក្នុងការចូលទៅសួរលម្អិតអំពីឯកសារផ្សេងៗ។ ក៏ប៉ុន្តែនេះគឺជារបៀបតែមួយគត់ ដែលខ្ញុំអាចធ្វើបាន។ នេះគឺជាចំណុចសំខាន់ណាស់ នៅក្នុងការការពារក្ដីលោក ខៀវ សំផន។

[១៥:៤៧:២៧]

ហើយជាពិសេសនោះគឺថា ជាដំបូងគឺយើងមានពេលវេលា២ថ្ងៃ ដំបូងគឺថាឲ្យ២ថ្ងៃកន្លះសម្រាប់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយពួកគាត់ទាំងពីរក្រុមហ្នឹងក៏បានប្រើពេលលើស២ថ្ងៃកន្លះហ្នឹងទៅទៀត។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាបន្ថែមពេលវេលាឲ្យយើងខ្ញុំ ព្រោះថាខ្ញុំមានប្រធានបទជាច្រើនផ្សេងទៀត ដោយត្រូវសួរលោក ស្ទីវ ហេដឌ័រ ដើម្បីការពារក្ដីលោក ខៀវ សំផន។

នេះខ្ញុំបន្ថែម ខ្ញុំបញ្ជាក់ជូនលោកប្រធានមុនឲ្យហើយ ព្រោះថាឥឡូវម៉ោងបីជិតហាសិបទៅហើយ។ ហើយខ្ញុំនៅសល់ឯកសារច្រើនទៀត ដែលពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍ជាមួយ អៀង សារី ពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍ជាមួយកូនក្តីរបស់ខ្ញុំ។

ដូច្នេះ ខ្ញុំសូមឲ្យលោកប្រធានសម្រេចឲ្យហើយមុនពេលដែលយើងទៅដល់ម៉ោងបួននោះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយអង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់លោកស្រីមេធាវី ដោយបន្ថែមមួយវគ្គថែមទៀតនៅព្រឹកថ្ងៃស្អែក។

[១៥:៤៨:៥០]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំ -- តើលោកប្រធានចង់សម្រេចអំមិញបានន័យថាម៉េច? បានន័យថាមួយព្រឹកពេញស្អែក ឬក៏មួយវគ្គដំបូងនៃព្រឹក គឺបានន័យថាត្រឹមដល់ម៉ោងដប់កន្លះព្រឹកស្អែក។ គឺថាខ្ញុំទទួលបានតែពេលវេលាបន្ថែម ពេលវេលាតាមដើមមក ឬក៏លោកប្រធានបន្ថែម ពីព្រោះបើយើងគិតមើលទៅមានការជំទាស់អី គឺអស់១ម៉ោងជាងទៅហើយ។ អ៊ីចឹងសូមលោកប្រធានបន្ថែមសម្រាប់ព្រឹកស្អែក។

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកស្រីសុំយ៉ាងម៉េចទៅ ឲ្យច្បាស់លាស់? លោកស្រីសុំឲ្យអង្គជំនុំជម្រះគិតគូរទូទាត់សងវិញនូវពេលវេលាដែលមានការបាត់បង់ ហើយសូមបន្ថែមពេលវេលាមួយវគ្គទៀត វាស្មើនឹងមួយព្រឹក ឬក៏យ៉ាងម៉េចនៅថ្ងៃស្អែក?

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន គឺថាខ្ញុំសូមឲ្យលោកស្អែកមួយព្រឹកពេញ ប៉ុន្តែអាចបន្ថយបន្តិចបានប្រសិនជាពេលទៅសួរទៅអាចចប់មុន។ ដូច្នេះដូចដែលខ្ញុំបានបញ្ជាក់ជូនអ៊ីចឹងថា សុំ -- ខ្ញុំ១ថ្ងៃ ហើយសូមបន្ថែមពេលថែម១ម៉ោងកន្លះ។ អ៊ីចឹងដើម្បីឲ្យច្បាស់តែម្តងលោកប្រធាន គឺថាសុំមួយព្រឹកពេញតែម្តងនៅថ្ងៃស្អែកនេះ។

[១៥:៥០:២៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥១:២៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចអ៊ីចេះថា ពេលវេលាដែលលោកស្រីមានដើម្បីក្នុងការសួរដេញដោល សាក្សី ស៊្មីវ ហេងឆ័រ នេះនៅព្រឹកថ្ងៃស្អែកហ្នឹង គឺមួយវគ្គបានន័យថា ត្រឹមម៉ោងដំបូងនៃដំណើរការ សវនាការ។ ត្រឹមពេលម៉ោងសម្រកស្មើនឹង១ម៉ោងកន្លះ ដូចលោកស្រីបានស្នើសុំ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមស្នើសុំបន្ថែមបើសិនមានបញ្ហាសំខាន់ដែលត្រូវដោះស្រាយ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមបន្តទៀតលោក ហេងឆ័រ ឥឡូវនេះ ខ្ញុំសូមបង្ហាញឯកសារជូនលោក ឯកសារទាំងបី ភាសាគឺ E3/893 ដែលជាទូរលេខ១៧៨។

**កញ្ញា អង់តា ហ្គីសសេ៖**

ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីឲ្យក្រឡា -- មន្ត្រីតុលាការផ្ដល់ជូនឯកសារបី ភាសាជូនទៅលោក ស៊្មីវ ហេងឆ័រ ហើយសូមបញ្ចាំងទំព័រទី១ ជាភាសាខ្មែរនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជាថ្មីម្ដងទៀត ខ្ញុំសូមឲ្យលោកមើលឯកសារជាភាសាខ្មែរគឺទំព័រទី១ ដែលមានលេខ ERN 00000708, ជាភាសាអង់គ្លេស 00182629, ជាភាសាបារាំងគឺ 00386272។ ខ្ញុំសូមអានជាភាសា បារាំង "ទូរលេខ៧៨ ជម្រាបបង ម-៨៧០ និង បងវី ជាទីគោរព"។ ជាភាសាអង់គ្លេស ខ្ញុំសូមអានជា ភាសអង់គ្លេស៖ "ជម្រាបបង ម-៨៧០ គឺមន្ទីរ៨៧០ និងបងវី ជាទីគោរព"។ (បញ្ចប់ការអានជាភាសា អង់គ្លេស)។ ខ្ញុំចង់សួរលោកថា ជាភាសាខ្មែរលោកអានយ៉ាងម៉េច? ហើយលោកធ្លាប់មានឯកសារហ្នឹង នៅក្នុងដៃទេ?

[១៥:៥៤:៥២]

**លោក ស៊្មីវ ហេងឆ័រ៖**

**ឆ៖** បាទ គឺខ្ញុំធ្លាប់ឃើញឯកសារមួយនេះ ហើយការបកប្រែជាភាសាអង់គ្លេស គឺថាបានល្អ

ស្មើរតែដូចអត្ថន័យជាភាសាខ្មែរហើយ ភាសាដើមហើយ។

**ស៖** ឯកសារមួយទៀតគឺឯកសារ E3/902 ជាភាសាខ្មែរ ERN 00020894, ជាភាសាអង់គ្លេស 00183625, ជាភាសាបារាំង 00324514។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមការអនុញ្ញាតលោកប្រធានដើម្បីឲ្យមន្ត្រីតុលាការផ្តល់ឯកសារជូនលោក ហេងឥរ៍ ដើម្បីឲ្យគាត់បានពិនិត្យមើលទាំងបីភាសា។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមបញ្ជាក់ថា នេះគឺជាទូរលេខ238, 195ខ្ទង់ "គោរពជូនគណៈ៨៧០ ជាទីស្នេហា" ជាភាសាបារាំងដាក់ថា គណៈមជ្ឈិមទៀត។ ជាភាសាអង់គ្លេសគឺថា៖ "គោរពជូនគណៈ៨៧០ជាទីស្នេហា"។

[១៥:៥៧:១៦]

ដូច្នេះ ខ្ញុំសួរលោកថាតើខ្មែរគេដាក់ថាម៉េច? ព្រោះបារាំងគេដាក់ថា៖ "*ប៉ុយរ៉ូ សង់ត្រាល់*" ដែលមានន័យថាគណៈមជ្ឈិម។ ហើយសួរ ដំបូងសួរលោកសិន ថាលោកធ្លាប់ឃើញឯកសារនេះទេ?

**លោក ស៊ីវ ហេងឥរ៍៖**

**ឆ៖** បាទ ខ្ញុំធ្លាប់ឃើញឯកសារហ្នឹង គឺពេលនេះគឺថាការបកប្រែទាំងភាសាអង់គ្លេស ទាំងភាសាបារាំងគឺមិនត្រឹមត្រូវទេ។ គឺៗមិនមានគណៈកម្មាធិការកណ្តាល មិនមាន "ម" អីទេ គឺគោរពជូនគណៈ៨៧០។ យើងមិនដឹងថា "*ខម*" ហ្នឹងវាជាគណៈកម្មាធិការមួយ គណៈកម្មាធិការទាំងអស់មិនដឹងថាតើវាគណៈកម្មាធិការជាឯកវចនៈ ពហុវចនៈទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះលោក ហេងឥរ៍។

លោកប្រធាន ខ្ញុំមើលទៅឃើញថាម៉ោងបួនហើយ ហើយខ្ញុំបញ្ចប់លើឯកសារនេះហើយ។ តើលោកប្រធានចង់ឈប់សម្រាប់ឥឡូវនេះ ហើយនិងបន្តទៅថ្ងៃស្អែក ឬក៏ឲ្យខ្ញុំបន្តទៀត?

[១៥:៥៨:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទអរគុណលោក ស៊ីវ ហេងឆ័រ។ ឥឡូវកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក នៅថ្ងៃព្រហស្បតិ៍ ទី១៨ ខែកក្កដា ឆ្នាំ២០១៣។

ហើយនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ស៊ីវ ហេងឆ័រ ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។ ហើយសូមភាគីនៃរឿងក្ដី មន្ត្រីបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប។

លោក ស៊ីវ ហេងឆ័រ ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ស៊ីវ ហេងឆ័រ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ទី១៨ ខែកក្កដា ឆ្នាំ ២០១៣ នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺ លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ។ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនពីក្រោមសាលសវនាការនេះ ដែលរៀបចំនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០០នាទី)*